# របៀបប្រើប្រាស់ទំព័របៃតង



ផ្នែកនេះមានផ្តល់ព័តិមានអំពីថ្នាំពេទ្យនៅក្នុងសៀវភៅ ។ បើអ្នកចង់ប្រើថ្នាំបុរាណក្នុងស្រុកភូមិរបស់អ្នក ចូរទៅពិគ្រោះយោបល់ជាមួយគ្រូព្យាបាលថ្នាំបុរាណ ដើម្បីឱ្យគាត់ជួយអ្នកផ្សំថ្នាំបុរាណដែលត្រូវនឹងបញ្ហាជំងឺរបស់អ្នក ។ ថ្នាំបុរាណមានច្រើនប្រភេទ ហើយខុសៗគ្នាពីកន្លែងមួយទៅកន្លែងមួយទៀត ដូច្នេះថ្នាំបុរាណដែលធ្លាប់ប្រើនៅតំបន់មួយ ប្រហែលជាគ្មានលក់ ឬ ប្រហែលជាមិនត្រូវនឹងជំងឺនៅតំបន់ផ្សេងទៀតឡើយ ។

## របៀបប្រើថ្នាំដោយសុវត្ថិភាព

**ចូរប្រើថ្នាំនៅពេលណាដែលអ្នកត្រូវការវាតែប៉ុណ្ណោះ ។** មនុស្សជាច្រើនតែងយល់ថា កាលណាពួកគេមិនបានទទួលថ្នាំពេទ្យពេលពួកគេកំពុងឈឺ ពួកគេនឹងមិនធូរស្បើយឡើយ ។ ករណីនេះគឺមិនពិតឡើយ ។ បញ្ហាខ្លះដូចជាជំងឺគ្រុនផ្តាសាយ ការព្យាបាលល្អបំផុតគឺយោងតាមពេលវេលានិងការសំរាកឱ្យបានច្រើន ។ បញ្ហាខ្លះទៀតត្រូវបានដោះស្រាយយ៉ាងល្អបំផុតដោយហូបម្ហូបអាហារមានជីវជាតិឱ្យបានគ្រប់គ្រាន់ និងហូបទឹកស្អាត ។ ចូរកុំជឿចំពោះបុគ្គលិកសុខាភិបាលណាដែលតែងតែចង់ឱ្យអ្នកផឹកថ្នាំច្រើនយ៉ាង ហើយប្លែកៗពីគ្នា ។

**ចូរប្រើថ្នាំឱ្យពេញរយៈពេលដែលបានកំណត់ឱ្យ ។** ថ្វីបើអ្នកចាប់ដឹងថាខ្លួនឯងបានធូរស្រាលហើយក៏ដោយ ចូរបន្តផឹកថ្នាំឱ្យគ្រប់កំណត់ពេលតាមវេជ្ជបញ្ជា ។ ជួនកាលផឹកថ្នាំតិចជាងកំណត់ វាអាចធ្វើឱ្យជំងឺសើរើឡើងវិញ ។ វាក៏អាចបង្កឱ្យថ្នាំនោះស៊ាំ ដែលមានន័យថាថ្នាំដដែលនោះលែងត្រូវនឹងជំងឺរបស់អ្នក ។

**ហាមប្រើថ្នាំពេទ្យលើសកំណត់វេជ្ជបញ្ជា ។** ការប្រើថ្នាំពេទ្យលើសកំណត់វេជ្ជបញ្ជាមិនបានធ្វើឱ្យអ្នកធូរស្រាល ឬ ជាសះស្បើយបានលឿននោះទេ ហើយវាប្រហែលជាធ្វើឱ្យអ្នកឈឺកាន់តែធ្ងន់ធ្ងរឡើង ។

**ការយល់ដឹងនិងសំគាល់មើលសញ្ញានៃបញ្ហា ។** ថ្នាំមួយចំនួនអាចធ្វើទុក្ខទោសដល់សុខភាព ឬ បង្កឱ្យប្រតិកម្មថ្នាំ, ពេទ្យនិយមហៅថា **រ៉ែអស្បុងថ្នាំ** ដែលអាចជាគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ (ចូរអានទំព័រ 329) ។

**ចូរស្វែងយល់ឱ្យជ្រៅជ្រះអំពីថ្នាំពេទ្យ ។** ចូរសុំសួរយោបល់ពីវេជ្ជបណ្ឌិត, បុគ្គលិកសុខាភិបាល ឬ អ្នកលក់ថ្នាំក្នុងឱសថស្ថានអំពីថ្នាំពេទ្យដែលអ្នកត្រូវប្រើ ឬ ថ្នាំដទៃទៀតដែលអ្នកត្រូវការ ។ អ្នកក៏អាចរកឃើញព័តិមានអំពីថ្នាំពេទ្យនានានៅបណ្តាទំព័របៃតងក្នុងសៀវភៅនេះ និងសៀវភៅដែលបានបោះពុម្ពដោយមូលនិធិ**ហេសស្ពើរៀន /** Hesperian Foundation (ដូចជាសៀវភៅ**ទីណាដែលស្ត្រីគ្មានវេជ្ជបណ្ឌិត** ឬ សៀវភៅ**ទីណាដែលគ្មានវេជ្ជបណ្ឌិត**) ។

**តាមធម្មតាថ្នាំគ្រាប់សំរាប់លេបតាមមាត់គឺមានសុវត្ថិភាពជាងថ្នាំចាក់** ក្នុងសៀវភៅនេះយើងបានផ្តល់យោបល់ចំពោះថ្នាំដែលលេបតាមមាត់។ ក្នុងករណីដែលអ្នកជំងឺមិនអាចលេបថ្នាំគ្រាប់តាមមាត់បានតែប៉ុណ្ណោះ នោះយើងផ្តល់ព័ត៌មានអំពីថ្នាំដែលត្រូវចាក់។ បើអ្នកត្រូវការថ្នាំចាក់ ចូរទៅជួបនឹងបុគ្គលិកសុខាភិបាល។ ព័ត៌មានស្តីពីវិធីចាក់ថ្នាំដោយសុវត្ថិភាពអាចរកឃើញក្នុងសៀវភៅ **ទីណាដែលស្ត្រីគ្មានវេជ្ជបណ្ឌិត** ពីទំព័រ 542 ដល់ 544។

**ការប្រើថ្នាំមួយមុខគឺមានសុវត្ថិភាព ហើយមិនសូវថ្លៃដូចប្រើថ្នាំចំរុះគ្នាច្រើនមុខ** ប៉ុន្តែថ្នាំខ្លះ ជាពិសេសចំពោះអ្នកផ្ទុកវីរុសហ៊ីវ/អេដស៍ គឺប្រើថ្នាំផ្សំចូលគ្នាស្រាប់ (ថ្នាំមួយគ្រាប់ត្រូវបានផ្សំឡើងដោយសារធាតុថ្នាំពីរ-បីយ៉ាង) គឺមានការងាយស្រួលច្រើន។

## សំខាន់

- បើអាចទៅរួច ចូរអង្គុយ ឬ ឈរក្នុងពេលលេបថ្នាំ។ នៅពេលផឹកថ្នាំម្តងៗ ចូរព្យាយាមផឹកទឹកឱ្យអស់មួយកែវពេញ។
- បើអ្នកក្អួត ហើយអាចឃើញថ្នាំចេញមកជាមួយកំអួត អ្នកត្រូវផឹកថ្នាំនោះជាថ្មីម្តងទៀត។
- បើអ្នកក្អួតក្នុងអំឡុងពេល 3 ម៉ោងបន្ទាប់ពីផឹកថ្នាំពន្យារកំណើត ចូរផឹកវាមួយគ្រាប់ទៀត ដើម្បីធ្វើឱ្យប្រាកដថាអ្នកពិតជាគ្មានផ្ទៃពោះ។

## ការលេបថ្នាំផ្សេងទៀតជាមួយថ្នាំសំរាប់ភាពពិការរបស់អ្នក

បើអ្នកផឹកថ្នាំទៀងទាត់សំរាប់ពិការភាពរបស់អ្នក វាប្រហែលជាមិនអាចប្រើលាយឡំគ្នាបានល្អជាមួយថ្នាំពេទ្យខ្លះទៀតដែលមានចុះក្នុងបញ្ជីថ្នាំក្នុងសៀវភៅនេះ។ ថ្នាំពេទ្យខ្លះអាចធ្វើឱ្យថ្នាំសំរាប់ភាពពិការរបស់អ្នកលែងមានប្រសិទ្ធភាព ឬ ថ្នាំសំរាប់ភាពពិការរបស់អ្នកអាចប្រែប្រួលទៅតាមឥទ្ធិពលនៃថ្នាំឯទៀត។ ឧទាហរណ៍ បើអ្នកប្រើថ្នាំ **ហ្វេនីតូអ៊ីន** (phenytoin) សំរាប់ជំងឺឆ្កួតជ្រូក/ស្កន់ អ្នកមិនគួរប្រើថ្នាំពន្យារកំណើតដែលផ្ទុកអ័រម៉ូន**អេស្ត្រូជែន** និងអ័ម៉ូន**ប្រូជេស្ទីន**ទាំងពីរមុខឡើយ ពីព្រោះបញ្ហាប្រកាច់របស់អ្នកអាចទៅជាធ្ងន់ធ្ងរជាងមុន។ ចូរទៅជួបនិយាយនឹងបុគ្គលិកសុខាភិបាលដែលមានជំនាញ ឬ អ្នកលក់ថ្នាំក្នុងឱសថស្ថានដើម្បីស្វែងរកឱ្យឃើញថា ថ្នាំដែលអ្នកប្រើជាប្រចាំនោះនឹងមានឥទ្ធិពលប្រឆាំងយ៉ាងណាជាមួយថ្នាំថ្មីមួយទៀតដែលអ្នកត្រូវប្រើ ហើយបើមានមែន តើមានថ្នាំប្រភេទផ្សេងទៀតដែលអ្នកអាចប្រើជំនួសវាដែរទេ?

ជាសំណាងល្អ ថ្នាំដែលបានចុះបញ្ជីក្នុងសៀវភៅនេះមិនមានឥទ្ធិពលប្រឆាំងគ្រប់មុខឡើយ។ ចំពោះថ្នាំពីរ-បីយ៉ាងដែលមានឥទ្ធិពលប្រឆាំងគ្នានោះ អ្នកអាចរកឃើញព័ត៌មានសំរាប់ថ្នាំនីមួយៗដែលបានចុះក្រោមចំណងជើង "**ការទាក់ទិនជាមួយឥទ្ធិពលថ្នាំពេទ្យឯទៀត**" ដែលមានសញ្ញាសំគាល់ដូចខាងក្រោមនេះនេះ :-



## ប្រតិកម្មថ្នាំ (រ៉ែអស្សុងថ្នាំ)



មនុស្សមួយចំនួនប្រតិកម្មនឹងថ្នាំមួយជាក់លាក់ ។ កាលណាថ្នាំពេទ្យបានផ្តល់ឱ្យបុគ្គលម្នាក់ រាងកាយរបស់នាងធ្វើការឆ្លើយតបចំពោះឥទ្ធិពលថ្នាំនោះ (និយមហៅថា **រ៉ែអស្សុងថ្នាំ**) ។ រ៉ែអស្សុងថ្នាំ ប្រហែលជាធ្វើទុក្ខមិនស្រួលក្នុងខ្លួន (ដូចជាឡើងបន្ទាលត្រអាក, រមាស់ស្បែក ឬ ភ្នែក, ហើមមុខ ឬ បបូរមាត់, ដង្ហើមដង្ហក់ដូចកើតហឺត) ឬ វាប្រហែលជាធ្ងន់ធ្ងរនិងអាចជាគ្រោះថ្នាក់ដល់ជីវិតនាង (ដូចជាស្បែកមានសភាពស្លេកស្លាំង, ត្រជាក់ ឬ បែកញើស, ខ្សោយ, ជីពចរលោតលឿន ឬ សង្វាក់បេះដូងលោតញាប់, ពិបាកដកដង្ហើម, សំពាធឈាមទាប ឬ ក៏សន្លប់) ។

បើបុគ្គលម្នាក់ប្រតិកម្ម(រ៉ែអស្សុង)ថ្នាំយ៉ាងស្រួចស្រាវមួយរំពេចនោះ នាងត្រូវការការសង្គ្រោះជាបន្ទាន់ពីផ្នែកវេជ្ជសាស្ត្រ ។ ចូរផ្តល់ថ្នាំ **អេពីនេហ្វ្រីន** (epinephrine) អានទំព័រ 342 ។

ហាមលេបថ្នាំណាដែលអ្នកអាចមានប្រតិកម្មនឹងវា និងហាមប្រើថ្នាំងទៀតចេញពីអំបូរដូចគ្នានេះ ។ ឧទាហរណ៍ ព័ត៌មានស្តីពីអំបូរថ្នាំផ្សេះ ចូរអានពីទំព័រ 330 ដល់ 331 ។

## ឈ្មោះថ្នាំពេទ្យ




តាមធម្មតាថ្នាំមានឈ្មោះពីរយ៉ាង ។ នៅទូទាំងពិភពលោក ជាទូទៅ**ឈ្មោះដើមពីកំណើតថ្នាំ**គឺដូចគ្នា (ស្តង់ដារវិទ្យាសាស្ត្រទូទាំងពិភពលោកនិយមហៅតាមឈ្មោះដើមពីកំណើតរបស់វា) ។។ ក្រុមហ៊ុនផលិតថ្នាំពេទ្យមួយចំនួនបានផ្តល់ឈ្មោះមួយទៀតដល់ថ្នាំដែលក្រុមហ៊ុនខ្លួនបានផលិតជាម៉ាក/យីហោថ្នាំ ។ ថ្នាំមួយមុខផ្សំពីវត្ថុធាតុដូចគ្នានេះ បានផលិតដោយក្រុមហ៊ុនពីរខុសគ្នានឹងមានឈ្មោះពីរខុសគ្នាដែរ ។ ក្នុងសៀវភៅនេះ យើងប្រើ**ឈ្មោះដើមពីកំណើតថ្នាំ** អ្នកអាចប្រើថ្នាំមួយជំនួសឱ្យថ្នាំមួយទៀត បើ**ឈ្មោះដើមពីកំណើតថ្នាំ**របស់វាដូចគ្នា-នោះអ្នកអាចប្រើថ្នាំម៉ាកណាមួយក៏បានដែរ ។ ម៉ាកថ្នាំមួយចំនួនមានតំលៃថោកជាងម៉ាកថ្នាំមួយចំនួនទៀត ។

## តើត្រូវកំណត់ឱ្យថ្នាំពេទ្យចំនួនប៉ុន្មានដល់អ្នកប្រើប្រាស់?

ថ្នាំពេទ្យស្ទើរតែទាំងអស់ ថ្នាំគ្រាប់សំរាប់លេបតាមមាត់, ថ្នាំសំរាប់ស៊ុលចូលរន្ធគូទ ឬ ស៊ុលចូលរន្ធយោនី, និងថ្នាំសំរាប់ចាក់ គឺត្រូវបានវាស់តាមកំណត់ជា **ក្រាម** (g), **មីលីក្រាម** (mg), **មីក្រូក្រាម** (mcg) ឬ **យូនីត** (u) ។

- 1000 មីលីក្រាម = 1 ក្រាម (មួយពាន់**មីលីក្រាម** គឺស្មើគ្នានឹងមួយ**ក្រាម**) ។
- 1 មីលីក្រាម = 0.001 ក្រាម (មួយ**មីលីក្រាម**គឺស្មើគ្នានឹង សូន្យ-ចុច-សូន្យ-សូន្យ-មួយនៃចំនួនថ្នាំមួយ**ក្រាម**) ។

ថ្នាំមួយចំនួន ដូចជាថ្នាំពន្យារកំណើត គឺថ្លឹងទំងន់តាមកំណត់ជា **មីក្រូក្រាម** (mcg) ឬ **យូនីតក្រូក្រាម** (ucg) ។

- 1 យូនីតក្រូក្រាម = 1 មីក្រូក្រាម = 1/1000 មីលីក្រាម = 0.001 ក្រាម ។
- នេះមានន័យថា ថ្នាំចំនួន 1000 មីក្រូក្រាម ស្មើនឹងចំនួនថ្នាំ 1 មីលីក្រាម ។

ថ្នាំសំរាប់ចាក់ប្រហែលជាត្រូវបានវាស់តាមខ្នាតស្តង់ដារ**យូនីត** (U) ឬ ខ្នាតស្តង់ដារយូនីតអន្តរជាតិ (IU) ។

## ទ្រង់ទ្រាយរបស់ថ្នាំពេទ្យ

ថ្នាំពេទ្យត្រូវបានផលិតទៅតាមទម្រង់ទ្រង់ទ្រាយខុសៗគ្នា ហើយនៅក្នុងសៀវភៅនេះយើងប្រើរូបភាពដើម្បីបង្ហាញពីរបៀបដែលគួរផ្តល់ថ្នាំឱ្យអ្នកប្រើប្រាស់ :-



ចូរផ្តល់ថ្នាំចាក់កាលណាយើងបង្ហាញរូបភាពនេះ។



ចូរផ្តល់ថ្នាំគ្រាប់ ឬ ថ្នាំស៊ុលកាលណាយើងបង្ហាញរូបភាពនេះ។




ចូរផ្តល់ថ្នាំប៉ូម៉ាត ឬ ថ្នាំក្រែមកាលណាយើងបង្ហញរូបភាពនេះ។



ចូរផ្តល់ថ្នាំបន្តក់កាលណាយើងបង្ហាញរូបភាពនេះ។



ចូរផ្តល់ថ្នាំទឹកស៊ីរ៉ូកាលណាយើងបង្ហាញរូបភាពនេះ។

ជាទូទៅ ការផ្តល់ថ្នាំគ្រាប់សំរាប់លេបតាមមាត់គឺប្រសើរបំផុត ដើម្បីចៀសវាងគ្រោះថ្នាក់ដល់សុខភាព។ ប៉ុន្តែក្នុងស្ថានភាពសង្រ្គោះបន្ទាន់ការប្រើថ្នាំចាក់ប្រហែលជាវិធីល្អជាង ពីព្រោះវាជ្រួតជ្រាបលឿនជាងថ្នាំគ្រាប់។

**បំរាម!**




រូបភាពទាំងនេះបង្ហាញឡើងជាមួយពាក្យ **បំរាម!** ចំពោះស្ត្រីកំពុងមានផ្ទៃពោះ ឬ ស្ត្រីដែលបំបៅដោះកូនគឺត្រូវការចំណាំវាយ៉ាងពិសេសបំផុត ពីព្រោះថ្នាំមួយចំនួនគ្មានសុវត្ថិភាពចំពោះពួកគាត់និងទារកឡើយ។

## ប្រភេទនៃថ្នាំពេទ្យ

នៅក្នុងសៀវភៅនេះមានចុះបញ្ជីថ្នាំពេទ្យពីរ-បីប្រភេទខុសៗគ្នា។ ថ្នាំពេទ្យមួយក្រុម គឺថ្នាំផ្សះត្រូវការពន្យល់ណែនាំតាមក្រុមមួយដាច់ដោយឡែកពីថ្នាំផ្សេងៗទៀត។ ចូរស្វែងយល់ឱ្យបានច្បាស់អំពីថ្នាំផ្សះ (អង់ទីប៊ីយូទិក)។

## ថ្នាំផ្សះ (អង់ទីប៊ីយូទិក)

ថ្នាំផ្សះគឺត្រូវប្រើដើម្បីប្រឆាំងនឹងជំងឺដែលបានបង្កដោយបាក់តេរី។ ថ្នាំផ្សះមិនព្យាបាលជំងឺទាំងឡាយណាដែលបានបង្កដោយវីរុសឡើយ ដូចជា ជំងឺគ្រុនផ្តាសាយ, ផ្លើម, ឬ វីរុសហ៊ីវ/អេដស៍។ ថ្នាំផ្សះដែលស្រដៀងគ្នាគឺត្រូវបាននិយាយថា ពួកវាចេញពីអំបូរដូចគ្នា។ ថ្នាំផ្សះចេញពីអំបូរតែមួយ ជារឿយៗអាចប្រើព្យាបាលលើបញ្ហាដូចគ្នាបាន។ ដូច្នេះបើអ្នកមិនអាចរកថ្នាំផ្សះមួយបាន ថ្នាំផ្សះមួយទៀតដែលចេញពីអំបូរដូចគ្នាអាចយកទៅប្រើជំនួសបាន។ បើអ្នកមានប្រតិកម្មចំពោះថ្នាំផ្សះមួយដែលចេញពីអំបូរមួយ អ្នកប្រហែលជាមានប្រតិកម្ម ឬ រ៉ែអស្ស៊ុងចំពោះថ្នាំផ្សះឯទៀតដែលចេញពីអំបូរនោះដែរ ដូច្នេះហាមប្រើថ្នាំផ្សះទាំងឡាយណាដែលចេញពីអំបូរមួយនោះ។

### នេះជាបញ្ជីនៃថ្នាំផ្សះមួយចំនួននិងអំបូររបស់ពួកវា :-



- អំបូរថ្នាំផ្សះប្រភេទ **ប៉េនីស៊ីលីន (Penicillins):-** អាម៉ុកស៊ីស៊ីលីន (amoxicillin), បេនហ្សាទីន ប៉េនីស៊ីលីន (benzathine penicillin), បេនហ្ស៊ីលប៉េនីស៊ីលីន (benzylpenicillin), ឌីក្លូសាកស៊ីលីន (dicloxacillin), ប្រូកាអ៊ីន ប៉េនីស៊ីលីន (procaine penicillin) និងនៅមានឈ្មោះថ្នាំផ្សេងទៀត។
- អំបូរថ្នាំផ្សះប្រភេទ **ម៉ាក្រូលីដ (Macrolides) :-** អាហ្ស៊ីត្រូម៉ីស៊ីន (azithromycin), អេរីត្រូម៉ីស៊ីន (erythromycin), និងនៅមានឈ្មោះថ្នាំផ្សេងទៀត។
- អំបូរថ្នាំផ្សះប្រភេទ **តេត្រាស៊ីគ្លីន (Tetracyclines)** :- ដុកស៊ីស៊ីគ្លីន (doxycycline), តេត្រាស៊ីគ្លីន (tetracycline)។
- អំបូរថ្នាំផ្សះប្រភេទ **ស៊ុលហ្វាស-Sulfas** (ស៊ុលហ្វូណាមីដ-**sulfonamides**):- ស៊ុលហ្វាមេតូសាហ្សុល- sulfamethoxazole (ជាចំណែកនៃថ្នាំ កូទ្រីម៉ុកសាហ្សុល - part of cotrimoxazole) និងនៅមានឈ្មោះថ្នាំផ្សេងទៀត។

- អំបូរថ្នាំផ្សះប្រភេទ **អាមីណូគ្លីកូសៃ** (aminoglycosides):- ជេនតាមីស៊ីន (gentamicin), ស្រិបតូមីស៊ីន (streptomycin), និងនៅមានឈ្មោះថ្នាំផ្សេងទៀត ។
- អំបូរថ្នាំផ្សះប្រភេទ **សេហ្វាឡូស្ព័រិន** (**cephalosporins**):- សេហ្វិចស៊ីម (cefixime), សេហ្វាលិចស៊ីន (cephalexin), និងនៅមានឈ្មោះថ្នាំផ្សេងទៀត ។

ជារឿយៗថ្នាំផ្សះត្រូវបានប្រើយ៉ាងច្រើនហួសហេតុ ។ ចូរប្រើថ្នាំផ្សះតែពេលចាំបាច់ប៉ុណ្ណោះ និងប្រើវាដោយសុវត្ថិភាព ចូរអានទំព័រ 327

## តារាងបញ្ហាសុខភាព

នេះជាតារាងបញ្ជីនៃបញ្ហាសុខភាពបានពិភាក្សាវែកញែកក្នុងសៀវភៅនេះ អាចត្រូវព្យាបាលជាមួយថ្នាំពេទ្យ ។ បញ្ហាជំងឺទាំងឡាយត្រូវបានចុះបញ្ជីទៅតាមលំដាប់អក្សរ**អង់គ្លេស**បង្ហាញនៅគូលោនខាងឆ្វេង ។ គូលោនកណ្តាលគឺលេខនៃទំព័រដែលអ្នកអាចបើកអានអំពីជំងឺនីមួយៗ មុនពេលប្រើថ្នាំពេទ្យណាមួយ ។ គូលោនខាងស្តាំ គឺឈ្មោះថ្នាំពេទ្យដែលអាចប្រើព្យាបាលជំងឺនីមួយៗនៅគូលោនខាងឆ្វេង ។ ដើម្បីរៀនសូត្របន្ថែមទៀតអំពីថ្នាំមួយមុខ ចូរបើកអានត្រង់តារាងថ្នាំពេទ្យចាប់ផ្តើមនៅទំព័រ 333 ។

បើអ្នកមិនច្បាស់ថាត្រូវប្រើថ្នាំណាមួយ ឬ បើថ្នាំពេទ្យដែលអ្នកកំពុងប្រើមើលទៅគ្មានប្រសិទ្ធភាព ចូរទៅពិគ្រោះនឹងបុគ្គលិកសុខាភិបាលដែលមានជំនាញ ឬ អ្នកលក់ថ្នាំពេទ្យក្នុងឱសថស្ថាន ។ ពួកគេអាចជួយអ្នករកថ្នាំពេទ្យឯទៀតដែលមានប្រសិទ្ធភាពជាងមុន និងមានលក់ក្នុងសហគមន៍របស់អ្នក ។

| បញ្ហាជំងឺ/រោគ<br>**PROBLEM** | អានទំព័រ<br>**SEE PAGE** | មើលឈ្មោះថ្នាំ<br>**SEE MEDICINES** |
|---|---|---|
| ប្រតិកម្មថ្នាំយ៉ាងស្រួចស្រាវមួយរំពេច<br>allergic shock (រ៉េអស្យុងថ្នាំខ្លាំងភ្លាមៗ) | 329 | អេពីនេហ្រ្វីន (epinephrine), ឌិចសាមេតាសូន (dexamethasone). |
| រលាកសន្លាក់ឆ្អឹង<br>arthritis | 279 | អាស់ស្ពីរីន (aspirin), អ៊ីប៊ុយប្រូហ្វែន (ibuprofen). |
| បាក់តេរីនៅក្នុងរន្ធយោនី<br>bacterial vaginosis | 133 | មេត្រូនីដាហ្សុល (metronidazole), ក្លាំងដាមីស៊ីន (clindamycin). |
| ធ្លាក់ឈាមតាមរន្ធយោនីក្រោយសម្រាលកូន<br>bleeding from the vagina after childbirth | 247 | អែកហ្គូមេទ្រីន (ergometrine) |
| ទាមឡា<br>Chancroid | 164 | អាហ្ស៊ីត្រូមីស៊ីន (azithromycin), ស៊ីប្រូផ្លូសាកស៊ីន (ciprofloxacin),<br>អេរីត្រូមីស៊ីន (erythromycin) |
| មេរោគក្លាមីដា (រោគប្រមេះទឹកបាយថ្លា)<br>Chlamydia | 160 | អាម៉ុកស៊ីស៊ីលីន (amoxicillin), អាហ្ស៊ីត្រូមីស៊ីន (azithromycin), ដុកស៊ីស៊ីគ្លីន (doxycycline), អេរីត្រូមីស៊ីន (erythromycin), តេត្រាស៊ីគ្លីន (tetracycline) |
| សំពាធឈាមលើសស្រួចស្រាវ<br>dysreflexia | 117 | លីដូកាអ៊ីន ( lidocaine gel - ថ្នាំស្ពឹកប្រភេទលាប), នីហ្វេឌីពីន (nifedipine) |
| ផែនការពន្យារកំណើតសង្គ្រោះបន្ទាន់<br>emergency family planning | 205, 357 | ថ្នាំគ្រាប់ពន្យារកំណើតថាមពលទាប/កំរិតទាប (low-dose birth control pills),<br>ថ្នាំគ្រាប់ការពារកុំឱ្យមានកូនជាបន្ទាន់ (emergency pills) |
| គ្រុនក្តៅ-រោគបង្កក្រោយសម្រាលកូន<br>fever after childbirth | 248 | អំពីស៊ីលីន (ampicillin), ស៊ីប្រូផ្លូសាកស៊ីន (ciprofloxacin), ក្លាំងដាមីស៊ីន (clindamycin), ដុកស៊ីស៊ីគ្លីន (doxycycline), មេត្រូនីដាហ្សុល (metronidazole) |
| គ្រុនក្តៅ-រោគបង្កក្នុងពេលកំពុងសម្រាលកូន<br>fever during labor | 246 | អំពីស៊ីលីន (ampicillin), មេត្រូនីដាហ្សុល (metronidazole),<br>ប្រូកាអ៊ីន ប៉េនីស៊ីលីន (procaine penicillin) |
| រោគផ្សិត-ក្នុងមាត់ (ជ្រាំង)<br>fungal infection: mouth (thrush) | 175, 260 | ក្លូទ្រីម៉ាហ្សុល (clotrimazole), នីស្តាទីន (nystatin), ហ្សង់ស្យាន-វីអូឡេ (gentian violet - ទឹកថ្នាំលាប ឬ លាងជំងឺសើរស្បែក ឬ កឿរជ្រាំង) |

| បញ្ហាជំងឺ<br>PROBLEM | អានទំព័រ<br>SEE PAGE | រកមើលឈ្មោះថ្នាំ<br>SEE MEDICINES |
|---|---|---|
| រោគផ្សិត-លើស្បែក<br>fungal infection: skin | 111, 260 | ក្លូទ្រីម៉ាហ្សុល (clotrimazole), ហ្សង់ស្យាន-វីអូឡេ (gentian violet),<br>មីកូណាហ្សុល (miconazole), នីស្តាទីន (nystatin) |
| រោគផ្សិត-ក្នុងរន្ធយោនី<br>fungal infection: vagina | 111 | ហ្សង់ស្យាន-វីអូឡេ (gentian violet), ក្លូទ្រីម៉ាហ្សុល (clotrimazole),<br>មីកូណាហ្សុល (miconazole), នីស្តាទីន (nystatin), ទឹកខ្មេះ (vinegar). |
| រោគប្រមេះ (រោគប្រមេះទឹកបាយ)<br>gonorrhea | 160 | សេហ្វិចស៊ីម (cefixime), ស៊ីប្រូផ្លូសាកស៊ីន (ciprofloxacin),<br>ដុកស៊ីស៊ីគ្លីន (doxycycline), ន័រផ្លូសាកស៊ីន (norfloxacin). |
| ដំបៅបង្កពីជំងឺរើម<br>herpes sores | 165 | អាស៊ីក្លូវីរ (acyclovir). |
| ការពារទល់ជំងឺឱកាសនិយមសំរាប់អ្នកផ្ទុកវីរុសហ៊ីវ<br>infection (prevention) for people with HIV | 177 | កូទ្រីម៉ុកសាហ្សុល (cotrimoxazole). |
| ការព្យាបាលរោគដែលបង្កនៅក្នុងប្លោកនោម<br>infection (treatment) bladder | 105 | អាម៉ុកស៊ីស៊ីលីន (amoxicillin), កូទ្រីម៉ុកសាហ្សុល (cotrimoxazole),<br>នីត្រូហ្វូយរ៉ង់តូអ៊ីន (nitrofurantoin). |
| ការព្យាបាលរោគដែលបង្កនៅក្នុងដោះ<br>infection (treatment) breast | 260 | ឌីក្លូសាកស៊ីលីន (dicloxacillin), អេរីត្រូមីស៊ីន (erythromycin). |
| ការព្យាបាលរោគដែលបង្កក្រោយពេលសម្រាលកូន<br>infection (treatment) after childbirth | 248 | ស៊ីប្រូផ្លូសាកស៊ីន (ciprofloxacin), ដុកស៊ីស៊ីគ្លីន (doxycycline),<br>មេត្រូនីដាហ្សុល (metronidazole), តេត្រាស៊ីគ្លីន (tetracycline). |
| ការព្យាបាលរោគដែលបង្កក្នុងភ្នែក<br>infection (treatment) eye | 99 | អេរីត្រូម៉ៃស៊ីន ជាប្រូម៉ាតដាក់ភ្នែក (erythromycin eye ointment),<br>តេត្រាស៊ីគ្លីន ជាប៉ូម៉ាតដាក់ភ្នែក (tetracycline eye ointment). |
| ការព្យាបាលរោគដែលបង្កក្នុងតម្រងនោម<br>infection (treatment) kidney | 106 | អាម៉ុកស៊ីស៊ីលីន (amoxicillin), សេហ្វិចស៊ីម (cefixime), ស៊ីប្រូផ្លូសាកស៊ីន<br>(ciprofloxacin), កូទ្រីម៉ុកសាហ្សុល (cotrimoxazole), ន័រផ្លូសាកស៊ីន (norfloxacin) |
| ការព្យាបាលរោគដែលបង្កលើស្បែក<br>infection (treatment) skin | 114 | អំពីស៊ីលីន (ampicillin), ឌីក្លូស៊ីស៊ីលីន (dicloxicillin), ដុកស៊ីស៊ីគ្លីន (doxycycline),<br>ប៉េនីស៊ីលីន (penicillin), អេរីត្រូមីស៊ីន (erythromycin), តេត្រាស៊ីគ្លីន (tetracycline) |
| ការថែទាំភ្នែកទារកទើបនឹងកើត<br>newborn eye care | 99, 343 | អេរីត្រូមីស៊ីន ជាប្រូម៉ាតដាក់ភ្នែក (erythromycin eye ointment),<br>តេត្រាស៊ីគ្លីន ជាប៉ូម៉ាតដាក់ភ្នែក (tetracycline eye ointment). |
| ឈឺចុកចាប់, គ្រុនក្តៅ និង ហើមពីតិចទៅខ្លាំង<br>pain, fever, and swelling mild to moderate | 93 | អាស់ស្ពីរីន (aspirin), ប៉ារ៉ាសេតាម៉ុល (paracetamol),<br>អ៊ីប៊ុយប្រូហ្វែន (ibuprofen). |
| រលាកអាងត្រគាក<br>pelvic inflammatory disease (PID) | 161 | អាម៉ុកស៊ីស៊ីលីន(amoxicillin), អាហ្ស៊ីត្រូមីស៊ីន(azithromycin), តេត្រាស៊ីគ្លីន<br>(tetracycline), ស៊ីប្រូផ្លូសាកស៊ីន (ciprofloxacin), ក្លាំងដាមីស៊ីន (clindamycin),<br>ដុកស៊ីស៊ីគ្លីន (doxycycline), អេរីត្រូមីស៊ីន (erythromycin),<br>មេត្រូនីដាហ្សុល (metronidazole), សេហ្វិចស៊ីម (cefixime) |
| ការទប់ស្កាត់ជំងឺរលាកសួតសំរាប់អ្នកជំងឺអេដស៍<br>pneumonia prevention, for people with AIDS | 177 | កូទ្រីម៉ុកសាហ្សុល (cotrimoxazole) |
| ដំបៅ, ដំបៅដែលក្លាយ<br>sores, infected | 114 | ឌីក្លូសាកស៊ីលីន (dicloxacillin), ដុកស៊ីស៊ីគ្លីន (doxycycline),<br>ប៉េនីស៊ីលីន (penicillin) អេរីត្រូមីស៊ីន (erythromycin),<br>ហ្សង់ស្យាន-វីយ៉ូឡេ (gentian violet). |
| ដំបៅ, ដំបៅដែលក្លាយនៅលើប្រដាប់ភេទ<br>sores, infected on the genitals | 163 | អាហ្ស៊ីត្រូមីស៊ីន (azithromycin), ដុកស៊ីស៊ីគ្លីន (doxycycline), បេនហ្សាទីន-<br>ប៉េនីស៊ីលីន (benzathine penicillin), ស៊ីប្រូផ្លូសាកស៊ីន (ciprofloxacin),<br>អេរីត្រូមីស៊ីន (erythromycin), តេត្រាស៊ីគ្លីន (tetracycline). |

| | | |
|---|---|---|
| រោគស្វាយ<br>syphilis | 163 | បេនហ្សាទីន ប៉េនីស៊ីលីន (benzathine penicillin), ដុកស៊ីស៊ីគ្លីន (doxycycline), អេរីត្រូម៉ីស៊ីន (erythromycin), តេត្រាស៊ីគ្លីន (tetracycline). |
| តេតាណូសលើទារកទើបនឹងកើត<br>tetanus in newborn | 251 | បេនហ្ស៊ីលប៉េនីស៊ីលីន (benzylpenicillin). |
| ជាតិពុលក្នុងឈាម/ប្រកាច់ ( ព្រាយក្រឡាភ្លើង)<br>toxemia/seizures | 246 | ឌីយ៉ាហ្សេប៉ាម (diazepam). |
| ទ្រីកូម៉ូណាស៍ ( ប្រភេទមួយនៃជំងឺកាមរោគ)<br>trichomonas | 159 | ក្លាំងដាម៉ីស៊ីន (clindamycin), មេត្រូនីដាហ្សុល (metronidazole). |
| ឫសដុះលើប្រដាប់ភេទ ( ជំងឺសេមាន់)<br>warts on the genitals | 165 | ប៉ូដូហ្វីលីន (podophyllin), ត្រៃក្លរ៉ូសេទិច អាស៊ីត (trichloroacetic acid) |
| រលាក ឬ ដំបៅស្បូន ( រោគបង្កក្នុងស្បូន)<br>womb infection | 248 | អាម៉ុកស៊ីស៊ីលីន (amoxicillin), អំពីស៊ីលីន (ampicillin), ស៊ីប្រូផ្លុសាកស៊ីន (ciprofloxacin), ដុកស៊ីស៊ីគ្លីន (doxycycline), មេត្រូនីដាហ្សុល (metronidazole), ប៉េនីស៊ីលីន (penicillin), ន័រផ្លុសាកស៊ីន (norfloxacin), ប្រូកាអ៊ីន ប៉េនីស៊ីលីន (procaine penicillin), តេត្រាស៊ីគ្លីន (tetracycline). |
| ផ្សិតយីស, ជ្រាំង ( អំបូរផ្សិតដំបែ)<br>yeast, thrush | 111 | ក្លូទ្រីម៉ាហ្សុល (clotrimazole), ហ្សង់ស្យាន-វីយ៉ូឡេ (gentian violet), មីកូណាហ្សុល (miconazole), នីស្តាទីន (nystatin), ទឹកខ្មេះ (vinegar). |

## តារាងថ្នាំពេទ្យ

ថ្នាំ **អាសេតាមីណូហ្វេន** ឬ **ប៉ារ៉ាសេតាម៉ុល** (អាប៉ាប, ប៉ាណាដុល, តេមប្រា, ទីលីណុល និងថ្នាំឯទៀត)
**Acetaminophen or paracetamol** (*APAP, Panadol, Tempra, Tylenol,* others)

**អាសេតាមីណូហ្វេន** ឬ **ប៉ារ៉ាសេតាម៉ុល** ជាម៉ាកឈ្មោះពីរសំរាប់ថ្នាំតែមួយដូចគ្នា ត្រូវបានប្រើបន្ថយការឈឺចាប់ និងគ្រុនក្តៅល្មមៗ ។ ចូរអាន ***ប៉ារ៉ាសេតាម៉ុល*** ត្រង់ទំព័រ 350 ។

ថ្នាំ **អាស៊ីក្លូវីរ (ហ្សូវីរ៉ាក់) = Acyclovir (*Zovirax*)**

**បំរាម!**



- ថ្នាំ **អាស៊ីក្លូវីរ** ជាថ្នាំសំលាប់វីរុស ប្រើប្រឆាំងជំងឺរើមដែលបង្កឱ្យកើតពងបែកដំឈឺចាប់លើប្រដាប់ភេទនិងរន្ធគូទ, និងក្នុងមាត់ ។
- **សំខាន់ :- អាស៊ីក្លូវីរ** មិនធ្វើឱ្យរើមជាសះស្បើយលែងកើតមកវិញឡើយ ប៉ុន្តែវាជួយបន្ថយមិនឱ្យឈឺចាប់ខ្លាំង និងជួយមិនឱ្យរើមរាលដាល ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ពេលលេបថ្នាំនេះ ជួនកាលវាអាចធ្វើទុក្ខឱ្យឈឺក្បាល, វិលមុខ, ចង្អោរ, និងក្អួត ។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំគ្រាប់ចំណុះពី 200, 400 ឬ 800 មីលីក្រាម ឬ ជាថ្នាំប៉ូម៉ាតចំណុះ 5% ក្នុងកូនទីបមួយ ។ ថ្នាំគ្រាប់មានប្រសិទ្ធភាព ហើយធម្មតាថោកជាងថ្នាំប៉ូម៉ាត ។ ចូរផឹកទឹកឱ្យច្រើនពេលលេបថ្នាំនេះ ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-** ចំពោះជំងឺរើមលើប្រដាប់ភេទ ( អានទំព័រ 165) លេបចំណុះ 200 មីលីក្រាម 5 ដងក្នុងមួយថ្ងៃ សំរាប់ពី 7 ទៅ 10 ថ្ងៃ **ឬ** លាបថ្នាំប៉ូម៉ាត 6 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ ។ ចូរលាងដៃជាបន្ទាន់ក្រោយពីលាបថ្នាំប៉ូម៉ាតម្តងៗ ។



**បំរាម :-** ហាមលេបថ្នាំនេះ បើអ្នកមានបញ្ហាតម្រងនោម ។ ស្ត្រីមានផ្ទៃពោះគួរប្រយ័ត្ន ឬ ហាមប្រើថ្នាំនេះ ។

ថ្នាំ **អាដ្រេណាលីន** ឬ **អេពីនេហ្វ្រីន = Adrenaline** or **Epinephrine**

ថ្នាំ **អាដ្រេណាលីន** ឬ **អេពីនេហ្វ្រីន** ជាឈ្មោះពីរសំរាប់ថ្នាំតែមួយ ។ វាត្រូវបានប្រើបន្សាបប្រតិកម្មថ្នាំធ្ងន់ធ្ងរ ឬ រ៉េអស្យុងស្រួចស្រាវមួយរំពេច និងជួយបន្ថយរោគហឺតដែលកំពុងធ្វើទុក្ខខ្លាំង ។ ចូរអាន **អេពីនេព្រីន** ត្រង់ទំព័រ 342 ។

**ថ្នាំអាម៉ុកស៊ីស៊ីលីន** (អាម៉ុកស៊ីហ្វារ, អាម៉ុកស៊ីល, ហ៊ីម៉ុក, មេហ្គាម៉ុក, ស៊ូម៉ុកស៊ីល) = **Amoxicillin** (*Amoxifar, Amoxil, Himox, Megamox, Sumoxil*)

- **អាម៉ុកស៊ីស៊ីលីន** ជាថ្នាំផ្សះនៃអំបូរថ្នាំ **ប៉េនីស៊ីលីន** (Penicillin) ប្រើព្យាបាលជំងឺ/ដំបៅជាច្រើនប្រភេទ។ វាមិនសូវមានប្រយោជន៍ដូចពីមុនទេ ដោយសារតែជំលោះប្រឆាំងនឹងថ្នាំមានឥទ្ធិពលខ្លាំងក្លា។
- **<u>សំខាន់ :-</u>** ថ្នាំ **អាម៉ុកស៊ីស៊ីលីន** ត្រូវលេបជាមួយអាហារ។ បើអ្នកមិនបានធូរស្រាលពីជំងឺក្នុងរវាង 3 ថ្ងៃ ចូរទៅរកផ្នែកវេជ្ជសាស្ត្រឱ្យជួយសង្គ្រោះ។ អ្នកប្រហែលជាត្រូវការថ្នាំផ្សេងខុសពីនេះ។
- **<u>ឥទ្ធិពលថ្នាំធ្វើទុក្ខ :-</u>** រាគ, ឡើងកន្ទួល, ចង្អោរ, ក្អួត។ វាអាចបង្កឱ្យស្ត្រីកើតរោគផ្សិតយីស ឬ កន្ទួលស្បែកលើគូទរបស់ទារក ឬ ក្មេងតូច។
- **<u>ថ្នាំនេះតែងផលិតជា :-</u>** ថ្នាំគ្រាប់ចំណុះពី 250 និង 500 មីលីក្រាម ។



- **<u>វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-</u>**

⇒ រលាកប្លោកនោម (អានទំព័រ 105), ប្រើចំណុះ 500 មីលីក្រាម, 3 ដងក្នុងមួយថ្ងៃ សំរាប់ 3 ថ្ងៃ។

⇒ មេរោគក្លាមីដា, លេបចំណុះ 500មីលីក្រាម, 3 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ។

⇒ ការប្រើថ្នាំផ្សំលាយគ្នា សំរាប់រោគធ្លាក់សពីរន្ធយោនី, ចូរអានទំព័រ 162។

⇒ រលាកតម្រងនោម (អានទំព័រ 106), លេបចំណុះ 500 មីលីក្រាម, 3 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ។

⇒ រលាកស្បូនក្រោយពីសម្រាលកូន, ប្រើចំណុះ 1 ក្រាម, 3 ដងក្នុងមួយថ្ងៃ សំរាប់ 10 ថ្ងៃ (ប្រើថ្នាំឯទៀតរួមផ្សំផងដែរ, អានទំព័រ 248)។

- **<u>ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-</u>**

⇒ រលាកប្លោកនោម ឬ តម្រងនោម :- ថ្នាំ cefixime, ciprofloxacin, cotrimoxazole, nitrofurantoin, (norfloxacin)។

⇒ រលាកស្បូនក្រោយពីសម្រាលកូន :- ថ្នាំ Ampicillin, ciprofloxacin, doxycycline, metronidazole។



**បំរាម :-** ហាមប្រើ បើអ្នកមានប្រតិកម្ម(រ៉េអស្យុង)ថ្នាំនៃអំបូរ **ប៉េនីស៊ីលីន**។

---

**ថ្នាំអំពីស៊ីលីន** (អំស៊ីល, អំពីស៊ីន, អូមនីប៉េន, ប៉េនព្រីទីន, ប៉ូលីស៊ីលីន) = **Ampicillin** (*Amcil, Ampicin, Omnipen, Penbritin, Polycillin*)

- ថ្នាំ **អំពីស៊ីលីន** ជាថ្នាំផ្សះនៃអំបូរថ្នាំ **ប៉េនីស៊ីលីន** (Penicillin) ត្រូវបានប្រើព្យាបាលជំងឺ/ដំបៅជាច្រើនប្រភេទ។ វាមិនសូវមានប្រយោជន៍ដូចពីមុន ដោយសារតែជំលោះប្រឆាំងនឹងថ្នាំមានឥទ្ធិពលខ្លាំងក្លា។
- **<u>សំខាន់ :-</u>** ថ្នាំ **អំពីស៊ីលីន** ត្រូវលេបមុនហូបអាហារ។ បើអ្នកមិនចាប់ធូរស្រាលក្នុងរវាង 3 ថ្ងៃ ទៅរកផ្នែកវេជ្ជសាស្ត្រឱ្យជួយ។ អ្នកប្រហែលជាត្រូវការថ្នាំផ្សេងខុសពីនេះ។
- **<u>ឥទ្ធិពលថ្នាំធ្វើទុក្ខ :-</u>** អាចបង្កធ្វើទុក្ខមិនស្រួលក្នុងពោះ, រាគ និង កន្ទួលលើស្បែក (ឡើងបន្ទាលត្រអាក)។
- **<u>ថ្នាំនេះតែងផលិត:-</u>** ថ្នាំគ្រាប់ ឬ គ្រាប់រាងមូលទ្រវែង, ចំណុះ 250 និង 500មីលីក្រាម។



- **<u>វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-</u>**

⇒ រលាកពេលកំពុងសម្រាលកូន, លេបចំណុះ 2 ក្រាម, 4 ដងក្នុងមួយថ្ងៃ សំរាប់ពី 7 ទៅ 10ថ្ងៃ។

⇒ រលាកស្បូនពេលកំពុងមានផ្ទៃពោះ, ប្រើចំណុះ 500មីលីក្រាម, 4 ដងក្នុងមួយថ្ងៃ ទាល់តែអ្នកអាចទៅរកផ្នែកវេជ្ជសាស្ត្រាជួយព្យាបាល។

⇒ រលាកក្រោយពេលសម្រាលកូន (អានទំព័រ 248) ឱ្យអ្នកជំងឺលេបថ្នាំចំណុះ 2 ក្រាម, 4 ដងក្នុងមួយថ្ងៃ ទាល់តែគ្រុនក្តៅជាដាច់ក្នុងរវាង 48 ម៉ោង។ ចូរឱ្យថ្នាំផ្សះផ្សេងទៀតដល់អ្នកជំងឺផងដែរ។

- **<u>ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-</u>**

⇒ រលាក/ដំបៅស្បូនក្នុងពេលកំពុងមានផ្ទៃពោះ :- ថ្នាំ metronidazole ។

⇒ រលាក/ដំបៅស្បូនក្រោយពេលសម្រាលកូន : ថ្នាំ amoxicillin, ciprofloxacin, doxycycline ។



**បំរាម :-** ហាមប្រើថ្នាំ **អំពីស៊ីលីន** បើអ្នកមានប្រតិកម្ម (រ៉េអស្យុង)ថ្នាំនៃអំបូរ **ប៉េនីស៊ីលីន** ។

ថ្នាំអាស់ស្ពីរីន (អាសេទីលសាលីស៊ីលលីក អាស៊ីត, អេ-អេស-អេ) = **Aspirin (acetylsalicylic acid, ASA )**

**ប្រយ័ត្ន!**



- ថ្នាំ **អាស់ស្ពីរីន** ធ្វើការប្រឆាំងនឹងរោគហើម, ឈឺចាប់ - រួមទាំងឈឺសន្លាក់ឆ្អឹង និងជំងឺគ្រុនក្តៅ ។
- **សំខាន់ :-** ព្យាយាមលេបថ្នាំ **អាស់ស្ពីរីន** ជាមួយម្ហូបអាហារ ឬ ទឹកដោះគោ ឬ ទឹកមួយកែវធំ ។ **អាស់ស្ពីរីន** ត្រូវបានប្រើដើម្បីជួយបន្ថយការឈឺចាប់សន្លាក់ឆ្អឹងនៃជំងឺរលាកសន្លាក់ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** អាចបង្កធ្វើទុក្ខមិនស្រួលក្នុងពោះ, ឈឺក្នុងក្រពះ ឬ បង្កបញ្ហាធ្លាក់ឈាម ។
- **រោគសញ្ញានៃការប្រើថ្នាំនេះលើសកំណត់ :-** ហ៊ឹងរោទិ៍ក្នុងត្រចៀក, ឈឺក្បាល, វិលមុខ, ច្របូកច្របល់, និងដង្ហើមលឿន ។
- **ជារឿយៗថ្នាំនេះផលិត :-** ជាថ្នាំគ្រាប់ចំណុះពី 300 និង 600 មីលីក្រាម, និងចំណុះផ្សេងៗគ្នា ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

⇒ ឈឺចាប់, ហើម ឬ គ្រុនក្តៅ, លេបចំណុះពី 300 ទៅ 600មីលីក្រាម, ហាមផឹកលើសពី 6 ដង ក្នុងមួយថ្ងៃដែលជាតម្រូវការ ។

- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**

⇒ ឈឺចាប់ ឬ គ្រុនក្តៅ :- **ប៉ារ៉ាសេតាម៉ុល** (paracetamol) ។

⇒ ឈឺចាប់, គ្រុនក្តៅ ឬ ហើម :- **អ៊ីប៊ុយប្រូហ្វែន** (ibuprofen) ។



- **ការទាក់ទិនជាមួយឥទ្ធិពលថ្នាំពេទ្យឯទៀតក្នុងពេលប្រើថ្នាំលាយចំរុះគ្នា :-**

⇒ ជាមួយថ្នាំ **វ៉ាល់ប្រូអ៊ីក អាស៊ីត** (valproic acid) :- ឥទ្ធិពលថ្នាំ **វ៉ាល់ប្រូអ៊ីក អាស៊ីត** អាចកើនឡើងខ្ពស់ ។

⇒ ជាមួយថ្នាំ **ហ្វេនីតូអ៊ីន** (phenytoin) :- ឥទ្ធិពលថ្នាំ **ហ្វេនីតូអ៊ីន** អាចកើនឡើងខ្ពស់ ។



**ប្រយ័ត្ន :-** ស្ត្រីមិនគួរប្រើថ្នាំ **អាស់ស្ពីរីន** នៅក្នុងរវាង 3 ខែចុងក្រោយនៃការមានផ្ទៃពោះ ។ បុគ្គលណាដែលកើតដំបៅក្រពះ ឬ មានបញ្ហាធ្លាក់ឈាមមិនគួរប្រើថ្នាំ **អាស់ស្ពីរីន** ឡើយ ។ ហាមប្រើមុនពេលវះកាត់ ។ ហាមប្រើ បើអ្នកបំបៅដោះកូននៅអំឡុងសប្តាហ៍ដំបូងនៃជីវិតទារក ។ ហាមឱ្យថ្នាំនេះដល់កុមារ ។ បើមានហ៊ឹងក្នុងត្រចៀក (រោគសញ្ញាដំបូងនៃការពុលថ្នាំ) ឈប់ប្រើ **អាស់ស្ពីរីន** ទាល់តែសំលេងហ៊ឹងនោះបាត់ទៅវិញ ។ បន្ទាប់មកចាប់ផ្តើមប្រើវាឡើងវិញ ប៉ុន្តែត្រូវប្រើចំណុះទាបជាងមុន ។

ថ្នាំ **អាហ្ស៊ីត្រូម៉ីស៊ីន** (ហ្ស៊ីត្រូម៉ាក) = **Azithromycin (*Zithromax*)**

- **អាហ្ស៊ីត្រូម៉ីស៊ីន** ជាថ្នាំផ្សះនៃអំបូរថ្នាំ **ម៉ាក្រូលីដ** (macrolide), ប្រើព្យាបាលជំងឺកាមរោគជាច្រើន ។ វាមានតំលៃថ្លៃ និងជារឿយៗពិបាករកទិញ ប៉ុន្តែវាធ្វើការយ៉ាងមានប្រសិទ្ធភាពប្រឆាំងនឹងកាមរោគ កាលដែលថ្នាំផ្សះឯទៀតគ្មានប្រសិទ្ធភាពដូចវា ។
- **សំខាន់ :-** លេបវា**មួយម៉ោងមុន**ពេលហូបអាហារ ឬ **ពីរម៉ោង**ក្រោយពីហូបម្ហូបអាហារ ។ **អាហ្ស៊ីត្រូម៉ីស៊ីន** ជាថ្នាំដ៏វិសេសសំរាប់ព្យាបាលកាមរោគដែលបង្កឱ្យធ្លាក់ស ឬ ដំបៅប្រដាប់ភេទ ។ វាជាការល្អសំរាប់ព្យាបាលកាមរោគ កាលណាថ្នាំឯទៀតគ្មានប្រសិទ្ធភាពចំពោះជំងឺ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** រាគ, ចង្អោរ, ក្អួត, ឈឺចាប់ក្នុងពោះ ។
- **ជារឿយៗថ្នាំនេះផលិត :-** ជាថ្នាំគ្រាប់ទ្រវែងចំណុះ 250 មីលីក្រាម ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

⇒ មេរោគក្លាមីដា, ជំងឺទាមឡា ឬ រោគរលាកអាងត្រគាត, ចូរលេបចំណុះ **1** ក្រាម តែម្តងដងគត់ ។

- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**

⇒ មេរោគក្លាមីដា :- **អាម៉ុកស៊ីស៊ីលីន** (amoxicillin), **ដុកស៊ីស៊ីគ្លីន** (doxycycline), **អេរីត្រូម៉ីស៊ីន** (erythromycin), **តេត្រាស៊ីគ្លីន** (tetracycline) ។

⇒ ជំងឺទាមឡា :- **ស៊ីប្រូផ្លូសាកស៊ីន** (ciprofloxacin), **អេរីត្រូម៉ីស៊ីន** (erythromycin) ។

⇒ រោគរលាកអាងត្រគាក :- ចូរអានទំព័រ 162 ។



**ប្រយ័ត្ន :-** ហាមប្រើ បើអ្នកប្រតិកម្ម (រ៉ៃអស្សុង) ចំពោះថ្នាំ **អេរីត្រូម៉ីស៊ីន** និងថ្នាំផ្សះឯទៀតនៃអំបូរថ្នាំ **ម៉ាក្រូលីដ** ។

**ថ្នាំបេនហ្សាទីន ប៉េនីស៊ីលីន** (ប៊ីស៊ីលីន អ៊ិល-អេ, ប៉េនណាឌ័រ អ៊ិល-អេ)= **Benzathine penicillin** (***Bicillin L-A, Penadur L-A***)

- **ថ្នាំបេនហ្សាទីន ប៉េនីស៊ីលីន** ជាថ្នាំផ្សះដែលធ្វើសកម្មភាពរយៈពេលវែងនៃអំបូរថ្នាំ **ប៉េនីស៊ីលីន** (penicillin) ព្យាបាលរោគស្វាយ, ដំបៅត្រង់ប្រដាប់ភេទ, និងជំងឺដែលបង្កពីមេរោគផ្សេងៗ។
- **សំខាន់ :-** វាជាថ្នាំចាក់ ត្រូវចាក់ចូលសាច់ដុំធំជានិច្ច។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ចំពោះមនុស្សមួយចំនួន :- រមាស់ដុំៗ ឬ កន្ទួលស្បែក។
- **កម្រនឹងកើតឡើង :-** ប្រតិកម្មដ៏គ្រោះថ្នាក់ហៅថា រ៉េអស្សុងយ៉ាងស្រួចស្រាវ។ ក្រោយពីចាក់ថ្នាំ **ប៉េនីស៊ីលីន** ភ្លាម បើអ្នកជំងឺមានអាការៈស្លេកស្លាំងមួយរំពេច (បែកញើសត្រជាក់), ខ្សោយ, សម្ពាធលេះដូងកន្ទ្រាក់ ឬ លោតញាប់ខ្លាំង, ពិបាកដកដង្ហើម, សន្លប់បាត់ស្មារតី។ ត្រូវចាក់ថ្នាំ **អេពីនេហ្វ្រីន** (Epinephrine) ភ្លាមតែម្តងឱ្យអ្នកជំងឺ, អានទំព័រ 342។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំម្សៅនិងមានអង្គធាតុរាវលាយចាក់ឱ្យអ្នកជំងឺ ក៏រិត 1.2 ឬ 2.4 លានយូនីត, ចំណុះ 5 មីលីលីត្រក្នុងកូនដបនីមួយៗ។



- **វិធីប្រើថ្នាំចំពោះសំរាប់ជំងឺ/រោគ :-**

⇒ រោគស្វាយ បើមានដំបៅ, ចាក់តែម្តងគត់ ក៏រិត 2.4 លានយូនីត ចូលក្នុងសាច់ដុំធំ។ បើបានធ្វើតេស្តឈាម ឬ ដំបៅនោះបានបាត់ទៅវិញ, ត្រូវចាក់ថ្នាំមួយអាទិត្យម្តងៗ ឱ្យបាន 3 អាទិត្យជាប់គ្នា។

- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**

⇒ រោគស្វាយ :- **ដុកស៊ីស៊ីគ្លីន** (doxycycline), **តេត្រាស៊ីគ្លីន** (tetracycline), **អេរ៉ីត្រូមីស៊ីន** (erythromycin) ។



**បំរាម :-** កាលណាចាក់ថ្នាំ **ប៉េនីស៊ីលីន**, អ្នកត្រូវតែមានថ្នាំ **អេពីនេហ្វ្រីន** ស្តុកទុកក្បែរខ្លួន។ ចូរសំគាល់មើលរោគសញ្ញាប្រតិកម្មថ្នាំ និងរ៉េអស្សុងស្រួចស្រាវ ដែលវាអាចចាប់ផ្តើមក្នុងរវាង 30 នាទី។

ថ្នាំ **បេនហ្ស៊ីលប៉េនីស៊ីលីន (សេលីនិច, ហាយ-ដូ-ប៉េន, ប៉េនីស៊ីលីន ជី ប៉ូតាស្យូម ឬ សូដ្យូម)**
**Benzylpenicillin (*Celinex, Hi-Do-Pen*, penicillin G potassium or sodium)**

- ថ្នាំ **បេនហ្ស៊ីលប៉េនីស៊ីលីន** ជាថ្នាំផ្សះនៃអំបូរថ្នាំ **ប៉េនីស៊ីលីន** (penicillin) ប្រើព្យាបាលជំងឺ/ដំបៅធ្ងន់ធ្ងរជាច្រើន។
- **សំខាន់ :-** ចូរត្រៀមជានិច្ចដើម្បីព្យាបាលករណីប្រតិកម្មថ្នាំ (អានទំព័ 329)។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ចំពោះស្ត្រីអាចបង្កឱ្យកើតរោគផ្សិតយីស ឬ កុមារអាចឡើងរោលកន្ទួលស្បែកដូច ទឹកនោមរោល។
- **ជារឿយៗថ្នាំតែងផលិតជា :-** ថ្នាំម្សៅនិងមានអង្គធាតុរាវសំរាប់លាយចាក់នៃក៏រិត 1 ឬ 5 លានយូនីត ក្នុងកូនដបនីមួយៗ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

⇒ ជំងឺតេតាណូសក្នុងទារកទើបនឹងកើត ត្រូវចាក់ចូលសាច់ដុំតែម្តងគត់ គឺវាស់ចំណុះថ្នាំទៅតាមទំងន់ទារក ក៏រិត 100, 000 យូនីត គឺស្មើទំងន់ទារកមួយគីឡូក្រាម ហើយយកទារកទៅកន្លែកវេជ្ជសាស្ត្រឱ្យជួយព្យាបាល។



**បំរាម :-** សំគាល់មើលរោគសញ្ញាប្រតិកម្មថ្នាំ និងសញ្ញានៃប្រតិកម្មធ្ងន់ធ្ងរភ្លាមៗ។ ហាមផ្តល់ថ្នាំនៃអំបូរ **ប៉េនីស៊ីលីន** ឱ្យអ្នកជំងឺណាដែលប្រតិកម្មនឹងវា។

ថ្នាំ **សេហ្វិចស៊ីម (ស៊ូប្រាក្ស) = Cefixime (*Suprax*)**

- **សេហ្វិចស៊ីម** ជាថ្នាំផ្សះនៃអំបូរថ្នាំ **សេហ្វាឡូស្ព័រីន** (cephalosporin) ប្រើព្យាបាលរោគជាច្រើនរួមមាន រោគប្រមេះ, រលាកអាងត្រគាក និង រលាកតម្រងនោម ។
- **សំខាន់ :-** ចូរសំគាល់មើលរោគសញ្ញាប្រតិកម្ម (រ៉េអស្សុង) ថ្នាំ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ធ្វើទុក្ខមិនស្រួលក្នុងពោះ, រាគអាចម៍, ឈឺក្បាល ។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំគ្រាប់ចំណុះពី 200 **ឬ** 400 មីលីក្រាម **ឬ** ថ្នាំទឹកមានកំរិត 100 មីលីក្រាម ក្នុងកូនដបទីមួយៗនៃចំណុះ 5 មីលីលីត្រ



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**
  - ⇒ ប្រមេះ, លេបចំណុះ 400មីលីក្រាម, តែម្តងគត់ ។
  - ⇒ ការប្រើថ្នាំលាយចំរុះគ្នាដើម្បីព្យាបាលរោគធ្លាក់សពីរន្ធយោនី ឬ រលាកអាងត្រគាក, អានទំព័រ 162 ។
  - ⇒ រលាកតម្រងនោម លេបចំណុះ 500មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ សំរាប់ 10 ថ្ងៃ ។
- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**
  - ⇒ ប្រមេះ :- **ស៊ីប្រូផ្លូសាកស៊ីន** (ciprofloxacin), **ដុកស៊ីស៊ីគ្លីន** (doxycycline), **ន័រផ្លូសាកស៊ីន** (norfloxacin) ។
  - ⇒ រលាកតម្រងនោម :- **ស៊ីប្រូផ្លូសាកស៊ីន**(ciprofloxacin), **កូទ្រីម៉ុសាហ្សុល** (cotrimoxazole) ។



**បំរាម :-** ចំពោះបុគ្គលមានបញ្ហាថ្លើមគួរត្រូវប្រយ័ត្នពេលកំពុងប្រើថ្នាំ **សេហ្វិចស៊ីម** ។ ហាមប្រើ បើអ្នកប្រតិកម្មចំពោះថ្នាំផ្សះនៃអំបូរ **សេហ្វាឡូស្ព័រីន** ។

---

**បំរាម!**



ថ្នាំស៊ីប្រូផ្លូសាកស៊ីន (ស៊ីឡូសាន, ស៊ីប្រូ, ស៊ីប្រូបេយ៍) = **Ciprofloxacin (*Ciloxan, Cipro, Ciprobay*)**

- ថ្នាំ **ស៊ីប្រូផ្លូសាកស៊ីន** ជាថ្នាំផ្សះខ្លាំងមួយនៃអំបូរថ្នាំ **គីនណូឡូន** (quinolone) ប្រើព្យាបាលរោគស្បែក និងរលាកតម្រងនោម, និងកាមរោគខ្លះទៀតដូចជា ប្រមេះ, ទាមឡា, និងរលាកអាងត្រគាត ។
- **សំខាន់ :-** ចូរហូបទឹកឱ្យច្រើន ។ អ្នកអាចហូបអាហារពេលកំពុងប្រើថ្នាំ **ស៊ីប្រូផ្លូសាកស៊ីន**, តែត្រូវតែចៀសវាងហូបចំណីអាហារផលិតពីជាតិទឹកដោះគោ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ចង្អោរ, រាគ, ក្អួត, ឈឺក្បាល ។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំគ្រាប់ចំណុះ 250, 500 **ឬ** 750 មីលីក្រាម ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**
  - ⇒ ប្រមេះ, លេបចំណុះ 500មីលីក្រាម, តែម្តងគត់ ។ (បើប្រើថ្នាំលាយចំរុះគ្នាព្យាបាលរោគធ្លាក់សពីរន្ធយោនី អានទំព័រ 162) ។
  - ⇒ ទាមឡា, លេបចំណុះ 500 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ សំរាប់ 3 ថ្ងៃ ។
  - ⇒ រលាកអាងត្រគាត, អានទំព័រ 162 ។
  - ⇒ ជំងឺ/ជំងឺចៅក្រោយពីសម្រាលកូន, លេបចំណុះ 500 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ ។
  - ⇒ រលាកតម្រងនោម, លេបចំណុះ 500 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ សំរាប់ 10 ថ្ងៃ ។
- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**
  - ⇒ រោគប្រមេះ :- លេបថ្នាំ **សេហ្វិចស៊ីម** (cefixime) ។
  - ⇒ ជំងឺទាមឡា :- លេបថ្នាំ **អាហ្ស៊ីត្រូម៉ីស៊ីន** (azithromycin), **អេរ៊ីត្រូម៉ីស៊ីន** (erythromycin) ។
  - ⇒ រោគរលាកតម្រងនោម :- លេបថ្នាំ **សេហ្វិចស៊ីម** (cefixime), **កូទ្រីម៉ុសាហ្សុល** (cotrimoxazole) ។



**បំរាម :-** ថ្នាំនេះប្រតិកម្មនឹងជាតិកាហ្វេអ៊ីន (កាហ្វេ, សុកូឡា, ភេសជ្ជៈជាតិហ្គាស) ។ ថ្នាំនេះធ្វើឱ្យឥទ្ធិពលកាហ្វេអ៊ីនឡើងខ្លាំង ហាមប្រើថ្នាំនេះជាមួយអាហារជាតិទឹកដោះគោ ។ ស្ត្រីមានគភ៌, ស្ត្រីបំបៅដោះកូន ឬ អាយុក្រោម 16 ឆ្នាំ ហាមប្រើថ្នាំនេះ ។

ថ្នាំ **ក្លាំងដាម៉ីស៊ីន (គ្លីអូស៊ីន, ដាឡាស៊ីន) = Clindamycin (*Cleocin, Dalasin*)**

**បំរាម!**



- **ក្លាំងដាម៉ីស៊ីន** ជាថ្នាំផ្សះនៃអំបូរថ្នាំ **ឡាំងកូសាមីដ** (lincosamide) ប្រើព្យាបាលរោគនៃរន្ធយោនី, អាងត្រគាក, និងស្បែក ។
- **សំខាន់ :-** ការប្រើថ្នាំនេះជាមួយថ្នាំ **អេរីត្រូម៉ីស៊ីន** ឬ ថ្នាំ **ក្លរ៉ាំមហ្វេនីកុល** អាចធ្វើឱ្យថ្នាំទាំងពីរមិនសូវមានប្រសិទ្ធភាព ។
  បើអ្នកមានឈាមរដូវនៅអំឡុងពេលប្រើថ្នាំក្រែមនេះ ហាមប្រើសំឡីអនាម័យមូលទ្រវែងដែលរុកចូលក្នុងរន្ធយោនី ពីព្រោះជាតិថ្នាំក្រែមជ្រៀបចូលសំឡីអនាម័យ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ចង្អោរ, ក្អួត, និងរាគ អាចកើតឡើងពីរ-បីសប្តាហ៍ក្នុងពេលកំពុងប្រើថ្នាំនេះ ។ បើថ្នាំ **ក្លាំងដាម៉ីស៊ីន** ធ្វើឱ្យអ្នកកើតកន្ទួលរមាស់ស្បែក ឈប់ប្រើវា ហើយទៅជួបបុគ្គលិកសុខាភិបាលរបស់អ្នក ។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំគ្រាប់រាងមូលទ្រវែងចំណុះពី 25, 75 ឬ 150 និង 300 មីលីក្រាម ។ ឬ ជាថ្នាំក្រែមចំណុះ 2% ក្នុងកូនទីបតូចមួយ ។

---




- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**
  - ⇒ បាក់តេរីក្នុងរន្ធយោនី, លេបចំណុះ 300 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ ។ ឬ
    ស៊ុលថ្នាំក្រែមចំណុះ 5% ចូលឱ្យជ្រៅក្នុងរន្ធយោនីរៀងរាល់យប់ ពេលចូលដេកឱ្យបាន 7 យប់ ។
  - ⇒ ទ្រីកូម៉ូណាស លេបចំណុះ 300 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ ។
  - ⇒ ការប្រើថ្នាំលាយចំរុះគ្នាដើម្បីព្យាបាលរោគធ្លាក់សពីរន្ធយោនី ឬ រលាកអាងត្រគាក, អានទំព័រ 162 ។
- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**
  - ⇒ បាក់តេរីក្នុងរន្ធយោនី :- ថ្នាំ **មេត្រូនីដាហ្សុល** (metronidazole) ។

---



**បំរាម :-** ការប្រើថ្នាំនេះលើសពី 30 ថ្ងៃ អាចឈានទៅកើតរោគជ្រាំង និងរោគផ្សិតយីស ហើយវាអាចបង្កទុក្ខទោសដល់អ្នកដែលមានបញ្ហាតម្រងនោម ឬ បញ្ហាថ្លើម ។ ថ្នាំក្រែមសំរាប់ដាក់ចូលរន្ធយោនីអាចធ្វើឱ្យផុយស្រោមអនាម័យដល់ទៅ 3 ថ្ងៃ ក្រោយពីប្រើក្រែមនោះ បើអ្នកបំបៅដោះកូន ហើយថ្នាំនេះធ្វើឱ្យកូនតូចរាគអាចម៍ ចូរឈប់ប្រើវា ។

---

ថ្នាំ **ក្លូទ្រីម៉ាហ្សុល (ខននេស្តេន, ហ្គីណេ-ឡូទ្រីមីន, ម៉ីសេឡិច) = Clotrimazole (*Canesten, Gyne-Lotrimin, Mycelex*)**

- **ក្លូទ្រីម៉ាហ្សុល** ជាថ្នាំប្រឆាំងរោគផ្សិត ប្រើព្យាបាលរោគផ្សិតយីស និងរោគផ្សិតឯទៀតកើតក្នុងរន្ធយោនី, មាត់, និងលើស្បែក ។
- **សំខាន់ :-** ចៀសវាងរួមភេទឱ្យបាន 3 ថ្ងៃ ក្រោយពីប្រើថ្នាំ **ក្លូទ្រីម៉ាហ្សុល** សំរាប់រោគក្នុងរន្ធយោនី ។ វាអាចធ្វើផុយស្រោមអនាម័យ និងស្រោមអនាម័យរាងដូចត្រឡោក ។ អ្នកត្រូវប្រយ័ត្នកុំឱ្យថ្នាំនេះចូលភ្នែក និងឈប់ប្រើថ្នាំ **ក្លូទ្រីម៉ាហ្សុល** បើវាធ្វើអ្នកមានអាការៈរោលរលាក ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** រោលរលាកក្រហាយ, ធ្វើទុក្ខមិនស្រួលពោះ [ជាមួយថ្នាំ **ឡូហ្ស៊ិរង** (lozenges)] ។
- **ជារឿយៗថ្នាំនេះផលិត :-** ជាថ្នាំក្រែម, ចំណុះពី 1%, 2%, 10% ។ ស៊ុលចំណុះ 100 មីលីក្រាម, 200 មីលីក្រាម, និង 500មីលីក្រាម ។
  ស៊ុលថ្នាំ **ឡូហ្ស៊ិរង** ចំណុះ 10 មីលីក្រាម ។

---




- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**
  - ⇒ ផ្សិតយីសនៃរន្ធយោនី :-
    - ♦ ស៊ុលថ្នាំក្រែមចំណុះ 100មីលីក្រាម ឬ 1 % :- ស៊ុលមួយបំពង់ ឬ ចំណុះ 5 ក្រាម ចូលឱ្យជ្រៅក្នុងរន្ធយោនីរាល់ៗយប់ឱ្យបាន 7 យប់ ។
    - ♦ ស៊ុលថ្នាំក្រែមចំណុះ 200 មីលីក្រាម ឬ 2% :- ស៊ុលមួយបំពង់ ឬ ចំណុះ 5 ក្រាម ចូលឱ្យជ្រៅក្នុងរន្ធយោនីរាល់ៗយប់ឱ្យបាន 3 យប់ ។
    - ♦ ផ្សិតយីសនៃមាត់ ( ជ្រាំង) :- ចូរបៀមថ្នាំ **ឡូហ្ស៊ិរង**, ម្តងមួយគ្រាប់, 5 ដងក្នុងមួយថ្ងៃ សំរាប់ 14 ថ្ងៃ ។ ចូរបៀមជញ្ជក់ថ្នាំ **ឡូហ្ស៊ិរង** ក្នុងមាត់, ហាមទំពារ ឬ លេបវាទាំងមូល ។
    - ♦ រោគលើស្បែក :- លាបថ្នាំក្រែមតិចៗលើកន្លែងដែលស្បែកកើតជំងឺឱ្យបាន 2 ដងក្នុងមួយថ្ងៃ សំរាប់ ពី 2 ទៅ 8 អាទិត្យ ។
- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**
  - ⇒ ថ្នាំទឹកពណ៌ស្វាយ **ហ្សង់ស្យាន-វីយ៉ូឡេ** (Gentian violet), ថ្នាំ **នីស្តាទីន** (nystatin), ថ្នាំ **មីកុនហ្សាអុល** (miconzaole) ។

**ថ្នាំកូទ្រីម៉ុកសាហ្សុល ( ទ្រីមេតូព្រីម + សុលហ្វាមេតូសាហ្សុល) [អាហ្សូហ្គានតាណុល, បាក់ទ្រីម, កុបទីន, ហ្គានតាណុល, ប៉ូឡូហ្គ្រីម, សេបត្រា, សុលហ្វាទ្រីម, ធីអ៊ីមភី/អេសអ៊ីមអិច, ទ្រីមប៉ិច, និងថ្នាំផ្សេងទៀត]**

**Cotrimoxazole (trimethoprim + sulfamethoxazole) [*AzoGantanol, Bactrim, Coptin, Gantanol, Pologrim, Septra, Sulfatrim, TMP/SMX, Trimpex,* others]**

**បំរាម!**



- ថ្នាំ **កូទ្រីម៉ុកសាហ្សុល** ជាថ្នាំផ្សះពីរមុខដែលបានផ្សំចូលគ្នាស្រាប់ ( មួយមុខពីអំបូរថ្នាំ **សុលហ្វា** (sulfa)) ប្រើព្យាបាលជំងឺរលាកប្លោកនោម និងរលាកតម្រងនោម, ធ្លាក់សពីរន្ធយោនីដែលបង្កពីរោគប្រមេះ និងជំងឺទាមឡា ។ វាក៏ជួយទប់ស្កាត់មិនឱ្យអ្នកជំងឺរាគអាចម៍ និងរលាកសួត និងរួមទាំងជំងឺឯទៀតសំរាប់អ្នកផ្ទុកវីរុសហ៊ីវ ។
- **សំខាន់ :-** ចូរផឹកទឹកឱ្យច្រើន នៅរយៈពេលកំពុងផឹកថ្នាំនេះ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ឈប់ប្រើ បើវាបង្កប្រតិកម្មដូចជារមាស់ ឬ កន្ទួលស្បែក ។ វាក៏អាចបង្កអាការៈចង្អោរ និងក្អួត ។ រោគសញ្ញានៃការប្រើថ្នាំលើសកំណត់គឺ ចង្អោរ, ក្អួត, រាគ, ច្របូកច្របល់ និងបែកញើស ។
- **ជារឿយៗថ្នាំនេះផលិត :-** ជាថ្នាំគ្រាប់ចំណុះ 120 មីលីក្រាម ( **សុលហ្វាមេតូសាហ្សុល** 100 មីលីក្រាម+ **ទ្រីមេតូព្រីម** 20 មីលីក្រាម) ។
ថ្នាំគ្រាប់ចំណុះ 480 មីលីក្រាម ( **សុលហ្វាមេតូសាហ្សុល** 400 មីលីក្រាម + **ទ្រីមេតូព្រីម** 80 មីលីក្រាម) -ហៅថា "ថាមពលទោល" ។
ថ្នាំគ្រាប់ចំណុះ 960 មីលីក្រាម ( **ទ្រីមេតូព្រីម** 160 មីលីក្រាម + **សុលហ្វាមេតូសាហ្សុល** 800 មីលីក្រាម) -ហៅថា "ថាមពលទ្វេដង" ។
ថ្នាំទឹកចំណុះ 240 មីលីក្រាម ( **ទ្រីមេតូព្រីម** 40 មីលីក្រាម + **សុលហ្វាមេតូសាហ្សុល** 200 មីលីក្រាម-ក្នុងកូនដបទីមួយៗចំណុះ 5 មីលីលីត្រ ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

⇒ រលាកប្លោកនោម លេបចំណុះ 480 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃសំរាប់ 3 ថ្ងៃ ។

⇒ រលាកតម្រងនោម លេបម្តង 2 គ្រាប់នៃចំណុះ 480 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃសំរាប់ 10 ថ្ងៃ ។

⇒ ការទប់ស្កាត់ជំងឺរលាកសួតនិងរាគអាចម៍ចំពោះអ្នកផ្ទុកវីរុសហ៊ីវ លេបម្តង 2 គ្រាប់នៃចំណុះ 480 មីលីក្រាម រៀងរាល់ថ្ងៃ ។

⇒ រាគមូលជាឈាមសំរាប់អ្នកជំងឺអេដស៍ លេបម្តង 2 គ្រាប់នៃចំណុះ 480 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃសំរាប់ 10 ថ្ងៃ ។

⇒ រលាកសួតចំពោះអ្នកជំងឺអេដស៍ លេបម្តង 4 គ្រាប់នៃចំណុះ 480មីលីក្រាម, 1 ថ្ងៃ 3 ដងសំរាប់ 21 ថ្ងៃ ។

- **ថ្នាំឯទៀតដែលអាចប្រើការបានសំរាប់ជំងឺ/រោគ :-**

⇒ រលាកប្លោកនោមនិងរលាកតម្រងនោម :- **សេហ្វីចស៊ីម** (cefixime), **ស៊ីប្រូផ្លូសាកស៊ីន** (ciprofloxacin), **នីត្រូហ្វុយរ៉ង់តូអ៊ីន** (nitrofurantoin) ។

⇒ រាគអាចម៍ចំពោះអ្នកជំងឺអេដស៍ :- **ន័រផ្លូសាកស៊ីន** (norfloxacin), **មេត្រូនីដាហ្សុល** (metronidazole) ។



- **ការទាក់ទិនជាមួយឥទ្ធិពលថ្នាំពេទ្យឯទៀត :-**

⇒ ជាមួយថ្នាំ **ហ្វេនីតូអ៊ីន** (phenytoin) :- ក៏រិតថ្នាំ **ហ្វេនីតូអ៊ីន** អាចឡើងខ្ពស់និងធ្វើទុក្ខខ្លាំង ដែលបង្កឱ្យអ្នកជំងឺពិបាកទប់ចលនារាងកាយ ( ញ័រញ៉ូរខ្លាំង) ឬ ចលនាភ្នែក ( ភ្នែកវិលក្រលើតក្រលាប់) និងច្របូកច្របល់ ។

⇒ ជាមួយថ្នាំ **ដាបសុន** (dapsone):- ក៏រិតថ្នាំ **ទ្រីមេតូពីន** (trimethopin) អាចឡើងខ្ពស់ និងកើនការរងគ្រោះនៃជំងឺស្លេកស្លាំង ។



**បំរាម :-** ស្ត្រីដែលស្ថិតក្នុង 3 ខែចុងក្រោយនៃការមានផ្ទៃពោះ ហាមប្រើថ្នាំនេះ ។ ហាមប្រើថ្នាំ **កូទ្រីម៉ុកសាហ្សុល** បើអ្នកប្រតិកម្មចំពោះអំបូរថ្នាំផ្សះ **សុលហ្វា** ។

ថ្នាំ **ឌីយ៉ាហ្សេប៉ាម ( អានស៊ីយ៉ូនីល, កមប៉ុស, វ៉ាល់លីយ៉ូម )** = **Diazepam (*Anxionil, Calmpose, Valium*)**

**ហាម!**



- **ឌីយ៉ាហ្សេប៉ាម** ជាថ្នាំរំងាប់ចិត្ត និងជួយទប់ស្កាត់បញ្ហាប្រកាច់ ។ វាក៏ជួយឱ្យជំងឺថប់បារម្ភបានធូរស្រាល ហើយជួយឱ្យអ្នកជំងឺដេកលក់ស្រួល ។
- **សំខាន់ :-** **ឌីយ៉ាហ្សេប៉ាម** ជាថ្នាំដែលធ្វើឱ្យអ្នកប្រើញៀន ។ ហាមប្រើរួមគ្នាជាមួយថ្នាំឯទៀតដែលធ្វើឱ្យអ្នកងងុយដេក, ល្ងិតល្ងៃ, ជាពិសេសជាតិស្រវឹង ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ ( រោគសញ្ញាប្រើច្រើនហួសកំណត់ ) :-** ងងុយដេកល្ងិតល្ងៃខ្លាំង, បាត់បង់ការទប់ជំហរខ្លួន, ច្របូកច្របល់ ។
- **ជារឿយៗថ្នាំនេះផលិត :-** ជាថ្នាំគ្រាប់ចំណុះពី 5 ទៅ 10 មីលីក្រាម, ឬ ជាថ្នាំទឹកសំរាប់ចាក់ ( បាញ់ចូលរន្ធគូទ, ប្រើស៊ីរ៉ាំងគ្មានម្ជុល ) ចំណុះ 5 មីលីក្រាម ក្នុងកូនដបចំណុះ 1 មីលីលីត្រ, ឬ 10 មីលីក្រាមក្នុងកូនដបចំណុះ 2 មីលីលីត្រ ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

  ⇒ បើស្ត្រីប្រកាច់ក្នុងពេលកំពុងមានផ្ទៃពោះ ត្រូវបាញ់ថ្នាំទឹក **ឌីយ៉ាហ្សេប៉ាម** ចូលរន្ធគូទចំណុះ 20 មីលីក្រាម, **ប្រើស៊ីរ៉ាំងគ្មានម្ជុល** ។ បើត្រូវការ, 10 នាទីក្រោយមក ចូរបាញ់ចូលរន្ធគូទម្តងទៀត, ប្រើចំណុះ 15 មីលីក្រាម ក្រោយពីប្រកាច់រួចហើយ ។



**ហាម :-** ការប្រើថ្នាំ **ឌីយ៉ាហ្សេប៉ាម** ញឹកញាប់ ឬ ប្រើចំណុះច្រើនលើសកំណត់ក្នុងអំឡុងពេលមានផ្ទៃពោះអាចបណ្តាលឱ្យទារកកើតមកខូចទ្រង់ទ្រាយពីកំណើត ។ ថ្នាំនេះជ្រាបតាមទឹកដោះម្តាយផងដែរ ដូច្នេះស្ត្រីដែលបំបៅដោះកូនគួរតែចៀសវាងប្រើថ្នាំនេះ លើកលែងតែករណីសង្គ្រោះបន្ទាន់ប៉ុណ្ណោះ ។

ថ្នាំ **ឌីក្លូសាកស៊ីលីន** = **Dicloxacillin**

- **ឌីក្លូសាកស៊ីលីន** ជាថ្នាំផ្សះនៃអំបូរថ្នាំ **ប៉េនីស៊ីលីន** (penicillin) ប្រើព្យាបាលជំងឺដោះ និងស្បែក ។
- **សំខាន់ :-** បើអ្នកប្រើថ្នាំនេះ ចូរត្រៀមព្យាបាលចំពោះបញ្ហាប្រតិកម្ម/រ៉េអស្យុងថ្នាំ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ចង្អោរ, ក្អួត, រាគ ។ ចំពោះស្ត្រីអាចកើតផ្សិតយីស ឬ ទារក/ក្មេងតូចអាចឡើងកន្ទួលរមាស់លើស្បែកគូទ ។
- **ជារឿយៗថ្នាំនេះផលិត :-** ថ្នាំគ្រាប់រាងមូលទ្រវែង, ចំណុះពី 125 ទៅ 250 និង 500 មីលីក្រាម, ឬ ជាថ្នាំទឹកចំណុះ 62.5 មីលីក្រាម ក្នុងកូនដបចំណុះ 5 មីលីលីត្រ ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

  ⇒ ដោះ ឬ ស្បែក, ចូរលេបចំណុះ 500 មីលីក្រាម, 4 ដងក្នុងមួយថ្ងៃ, ពី 7 ទៅ 10 ថ្ងៃ ។
- **ថ្នាំឯទៀតដែលអាចប្រើព្យាបាលជំងឺ/រោគ :-** ថ្នាំ **សេហ្វាឡេស៊ីន** (cephalexin), **អេរីត្រូម៉ៃស៊ីន** (erythromycin), **ប៉េនីស៊ីលីន** (penicillin) ។



**ហាម :-** ហាមប្រើថ្នាំ **ឌីក្លូសាកស៊ីលីន** បើអ្នកប្រតិកម្ម/រ៉េអស្យុងនឹងថ្នាំអំបូរ **ប៉េនីស៊ីលីន** ។




ថ្នាំ **ដុកស៊ីស៊ីគ្លីន ( ប៊ីអូកូលីន, ដូរីក្ស, ម៉ូណូដុក, វីប្រាម៉ីស៊ីន, វីប្រា-តាប្ស)**
**Doxycycline (*Biocolyn, Doryx, Monodox, Vibramycin, Vibra-Tabs*)**

- **ដុកស៊ីស៊ីគ្លីន** ជាថ្នាំផ្សះនៃអំបូរថ្នាំ **តេត្រាស៊ីគ្លីន** (tetracycline) ប្រើព្យាបាលជំងឺ/ដំបៅជាច្រើនរួមមាន ជំងឺកាមរោគ, អាងត្រគាក និង ស្បែក ។
- **សំខាន់ :-** ហាមលេបជាមួយទឹកដោះគោ, ផលិតផលជាតិទឹកដោះគោ ឬ ថ្នាំក្រពះ**អានតាស៊ីដ** (antacids) ។ ហាមលេបមុនពេលទំលាក់ខ្លួនដេក ។ ចូរអង្គុយលេបថ្នាំជាមួយទឹកឱ្យច្រើនដើម្បីការពារបញ្ហារោលក្រហាយ ពីព្រោះថ្នាំនេះអាចបង្កបញ្ហានោះ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** រាគ ឬ មិនស្រួលក្នុងពោះ ។ មនុស្សខ្លះកើតកន្ទួលស្បែកក្រោយពីស្ថិតក្រោមកំដៅថ្ងៃ ។ ចំពោះស្ត្រីអាចកើតផ្សិតយើស, ចំពោះទារក ឬ ក្មេងតូចអាចឡើងរោលកន្ទួលលើកំប៉េះគូទ ។
- **ជារឿយៗថ្នាំនេះផលិត :-** ជាថ្នាំគ្រាប់ចំណុះ 50 និង 100 មីលីក្រាម ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

⇒ មេរោគក្លាមីដា, លេបចំណុះ 100 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ ។

⇒ រោគស្វាយ ពេលដំបៅត្រង់ប្រដាប់ភេទនៅឃើញនៅឡើយ, លេបចំណុះ 100 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ សំរាប់ 14 ថ្ងៃ ។

⇒ ការប្រើថ្នាំលាយចំរុះគ្នា សំរាប់រោគធ្លាក់សពីរន្ធយោនី ឬ រលាកអាងត្រគាក អានទំព័រ 162 ។

⇒ ដំបៅគ្រែ ឬ ជំងឺស្បែកផ្សេងទៀត, លេបចំណុះ 100 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ សំរាប់ 14 ថ្ងៃ ។

⇒ រលាក/ដំបៅក្រោយពីសម្រាលកូន, លេបចំណុះ 100 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ ទាល់តែជំងឺគ្រុនក្តៅជាដាច់ក្នុងរវាង 2 ថ្ងៃពេញ ។

- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**

⇒ រោគស្វាយ :- **បេនហ្សាទីន ប៉េនីស៊ីលីន** (benzathine penicillin), **អេរីត្រូម៉ីស៊ីន** (erythromycin), **តេត្រាស៊ីគ្លីន** (tetracycline) ។

⇒ រោគប្រមេះ :- **សេហ្វិចស៊ីម** (cefixime), **ស៊ីប្រូផ្លូសាកស៊ីន** (ciprofloxacin) ។

⇒ មេរោគក្លាមីដា :- **អាម៉ុកស៊ីស៊ីលីន** (amoxicillin), **អាហ្ស៊ីត្រូម៉ីស៊ីន** (azithromycin), **អេរីត្រូម៉ីស៊ីន** (erythromycin), **តេត្រាម៉ីស៊ីន** (tetracycline). ។

⇒ រោគស្បែក :- **ឌីក្លូសាស៊ីលីន** (dicloxacillin), **អេរីត្រូម៉ីស៊ីន**(erythromycin) , **ប៉េនីស៊ីលីន** (penicillin) , **តេត្រាស៊ីគ្លីន** (tetracycline) ។

⇒ រលាក/ដំបៅក្រោយពីសម្រាលកូន :- **អំពីស៊ីលីន** (ampicillin) , **ស៊ីប្រូផ្លូសាកស៊ីន** (ciprofloxacin), **មេត្រូនីដាហ្សុល** (metronidazole) ។



**បំរាម :-** ស្ត្រីមានផ្ទៃពោះ និងស្ត្រីដំបៅដោះកូន ហាមប្រើថ្នាំ **ដុកស៊ីស៊ីគ្លីន** ។ ហាមប្រើថ្នាំ **ដុកស៊ីស៊ីគ្លីន** ដែលត្រូវកំដៅថ្ងៃ ឬ ផុតថ្ងៃកំណត់ ។

ថ្នាំ **អេពីនេហ្វ្រីន** ឬ **អាដ្រេណាលីន (អាដ្រេណាលីន) = Epinephrine** or **Adrenaline (*Adrenalin*)**

- **អេពីនេហ្វ្រីន** និង **អាដ្រេណាលីន** ជាឈ្មោះពីរសំរាប់ថ្នាំតែមួយ ។ វាប្រើព្យាបាលបញ្ហារ៉ែអស្ស៊ុងថ្នាំ ឬ ប្រតិកម្មថ្នាំយ៉ាងធ្ងន់ធ្ងរ, ឧទាហរណ៍ ប្រតិកម្មថ្នាំយ៉ាងធ្ងន់ធ្ងរភ្លាមៗបង្កមកពីថ្នាំ **ប៉េនីស៊ីលីន** បន្ទាប់ពីបានប្រើវាហើយមួយសន្ទុះ ។
- **សំខាន់ :-** ចូរវាស់ស្ទង់សម្ពាធជីពចរ មុនពេលចាក់ថ្នាំ ។ ហាមផ្តល់ថ្នាំនេះឱ្យអ្នកជំងឺលើសពី 3 ដូស ។ បើសម្ពាធជីពចរលោតលើសពី 30 ដង ក្នុងមួយវិនាទី ក្រោយពីចាក់ថ្នាំលើកទីមួយ ឈប់ចាក់ថ្នាំឱ្យអ្នកជំងឺទៀត ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ខ្លាច, ដេកមិនលក់, សរសៃប្រសាទធ្វើទុក្ខ, តានតឹងខួរក្បាល, ឈឺក្បាល, វិលមុខខ្លាំង, សម្ពាធបេះដូងកើនឡើងញាប់ ។
- **រោគសញ្ញាប្រើថ្នាំច្រើនលើសកំណត់ :-** សំពាធឈាមឡើងខ្ពស់, សម្ពាធបេះដូងលោតលឿន, ដាច់សរសៃឈាមក្នុងខួរក្បាល ។
- **ជារឿយៗថ្នាំនេះផលិត :-** ថ្នាំអំពូលសំរាប់ចាក់ចំណុះ **1** មីលីក្រាម ក្នុងអំពូលចំណុះ **1** មីលីលីត្រ ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

⇒ បញ្ហារ៉ែអស្ស៊ុងថ្នាំកំរិតមធ្យម ឬ ប្រតិកម្មស្រួចស្រាវ, ចាក់ថ្នាំចំណុះ ½ មីលីក្រាម (½ មីលីលីត្រ) ចាក់ចូលក្រោមស្បែកដើមដៃ (ហាមចាក់ចូលសាច់ដុំ) ។ បើចាំបាច់ក្នុងរវាងពី 20 ទៅ 30 នាទីក្រោយមក ត្រូវចាក់ថ្នាំនេះលើកទីពីរឱ្យអ្នកជំងឺ និងក្នុងរវាងពី 20 ទៅ 30 នាទីក្រោយ ត្រូវចាក់ថ្នាំនេះលើកទីបីទៀត ។



**បំរាម :- ចូរប្រយ័ត្ន** ហាមចាក់ថ្នាំនេះឱ្យអ្នកជំងឺលើសពីចំនួនកំណត់ ។ ចូរចៀសវាងចាក់ថ្នាំត្រង់កំប៉េះគូទ ចូរចាក់ត្រង់ដើមដៃផ្នែកក្រោយ ចូរចាក់ថ្នាំចូលក្រោមស្បែក (ហាមចាក់ចូលសាច់ដុំ) ។

ថ្នាំ **អ៊ីរហ្គូមេទ្រីន ម៉ាលីត, មេធីលលើហ្គូណូវីន ម៉ាលីត (អាណ៊ឺរហេជ, អ៊ីរហ្គូណូវីន, អ៊ីរហ្គូត្រេត, មេធើរហ្គីន, មេធីលលើហ្គូណូវីន)**
Ergometrine maleate, methylergonovine maleate **(*Anurhage, Ergonovine, Ergotrate, Methergine,* methylergonovine)**

- ថ្នាំ **អ៊ីរហ្គូមេទ្រីន** បង្កឱ្យស្បូនរមួលរឹតរួតនិងសរសៃឈាមរបស់វា, ប្រើដើម្បីទប់ឈាមកុំឱ្យធ្លាក់ខ្លាំងក្រោយពីសម្រាលកូន ។ ថ្នាំ **អ៊ីរហ្គូមេទ្រីន** និងថ្នាំ **មេធីលលើហ្គូណូវីន** គឺជាថ្នាំតែមួយ ។ បន្ទាប់ពីផ្តល់ថ្នាំនេះដល់ស្ត្រីហើយ ចូរនាំនាងទៅរកផ្នែកវេជ្ជសាស្ត្រឱ្យជួយ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ចង្អោរ, ក្អួត, វិលមុខខ្លាំង, បែកញើស ។
- **ជារឿយៗថ្នាំនេះផលិត :-** ជាថ្នាំគ្រាប់ចំណុះ 0.2 មីលីក្រាម ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

⇒ ឈាមធ្លាក់ខ្លាំងក្រោយពីសម្រាលកូន, បន្ទាប់ពីទងសុកបានធ្លាក់ចេញក្រៅ ឱ្យអ្នកជំងឺលេបមួយគ្រាប់តាមមាត់ (ចំណុះ 0.2 មីលីក្រាម) រៀងរាល់ពី 6 ទៅ 12 ម៉ោងតាមតម្រូវការ ។



**បំរាម :-** ហាមប្រើថ្នាំ **អ៊ីរហ្គូមេទ្រីន** ដើម្បីឱ្យស្ត្រីចាប់ផ្តើមឈឺពោះ ឬ បង្ខំឱ្យឈឺពោះលឿន ឬ បង្កមូលហេតុពន្លូតកូន ។ ហាមឱ្យថ្នាំនេះមុនពេលទារកកើត ឬ មុនពេលទងសុកធ្លាក់ចេញក្រៅ ។

ថ្នាំ **អេរីត្រូមីស៊ីន ( អ៊ី.អ៊ី.អេស, អ៊ី-មីស៊ីន, អ៊ីរី-ម៉ាក្ស, អ៊ីធ្រីល, អាយឡូសូន, អាយឡូទៃស៊ីន)**
Erythromycin (***E.E.S, E-Mycin, Ery-max, Ethril, Ilosone, Ilotycin***)

- **អេរីត្រូមីស៊ីន** ជាថ្នាំផ្សះនៃអំបូរថ្នាំ **ម៉ាក្រូលីដ** (macrolide) ប្រើព្យាបាលជំងឺ/ដំបៅជាច្រើនរួមមាន កាមរោគ និងដំបៅស្បែក ។ ស្ត្រីដែលកំពុងមានផ្ទៃពោះអាចប្រើថ្នាំបានដោយសុវត្ថិភាព ហើយវាងាយរកបានស្ទើរគ្រប់ទីកន្លែង ។
- **សំខាន់ :- អេរីត្រូម៉ៃស៊ីន** ធ្វើការយ៉ាងល្អ កាលបើបានលេបវា 1 ម៉ោងមុនហូបអាហារ ឬ 2 ម៉ោងក្រោយពីហូបអាហារ ។ បើករណីនេះធ្វើឱ្យអ្នកមិនស្រួលពោះខ្លាំង ចូរលេបវាជាមួយអាហារបន្តិចបន្តួច ។ ហាមកិនបំបែកគ្រាប់ថ្នាំ ។ ជារឿយៗ គ្រាប់ថ្នាំត្រូវបានស្រោបពីក្រៅដោយជាតិផ្អែម ការពារកុំឱ្យជាតិទឹកក្នុងក្រពះរំលាយថ្នាំមុនពេលវាចាប់ធ្វើការ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-**អាចមិនស្រួលក្នុងពោះ ឬ បណ្តាលឱ្យចង្អោរ, ក្អួត, រាគអាចម៍ ។
- **ជារឿយៗថ្នាំនេះផលិត :-** ជាថ្នាំគ្រាប់រាងមូល ឬ គ្រាប់រាងមូលទ្រវែងចំណុះពី 200, 250, 500 មីលីក្រាម ។ ឬ ជាថ្នាំប៉ូម៉ាត 1% ឬ ជាថ្នាំម្សៅសំរាប់លាយនឹងអង្គធាតុទឹកចំណុះ 125 មីលីក្រាម ក្នុងមួយកូនដបចំណុះ 5 មីលីលីត្រ ។




- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

⇒ មេរោគក្លាមីដា, លេបចំណុះ 500 មីលីក្រាម, 4 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ ។

⇒ ថ្នាំផ្សំលាយគ្នាដើម្បីព្យាបាលរោគធ្លាក់សពីរន្ធយោនី ឬ រលាកអាងត្រគាក, អានទំព័រ 162 ។

⇒ ទាមឡា, លេបចំណុះ 500 មីលីក្រាម, 4 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ ។

⇒ រោគស្វាយ, លេបចំណុះ 500 មីលីក្រាម, 4 ដងក្នុងមួយថ្ងៃ សំរាប់ 15 ថ្ងៃ ។

⇒ ជំងឺដោះ, លេបចំណុះ 500 មីលីក្រាម, 4 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ ។

⇒ ដំបៅគ្រែ ឬ ជំងឺស្បែកផ្សេងៗ, លេបចំណុះ 250 មីលីក្រាម, 4 ដងក្នុងមួយថ្ងៃ សំរាប់ពី 7 ទៅ 10 ថ្ងៃ ។

⇒ ឈឺភ្នែក ( ភ្នែកក្រហម ឬ រលាកលើត្របកភ្នែក) ដាក់ថ្នាំប៉ូម៉ាតបន្តិចចូលក្នុងត្របកភ្នែកក្រោម ឱ្យបានពី 2 ទៅ 3 ដង ក្នុងមួយថ្ងៃ សំរាប់ 2 ទៅ 3 ថ្ងៃ ។

⇒ ការថែទាំភ្នែកទារកទើបនឹងកើត ចូរដាក់ថ្នាំប៉ូម៉ាតនៃចំណុះ 1% បន្តិចចូលក្នុងភ្នែកម្ខាងៗ ប្រមាណ 2 ម៉ោងក្រោយពេលកើតភ្លាម ។

- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**

⇒ មេរោគក្លាមីដា :- **អាម៉ុកស៊ីស៊ីលីន** (amoxicillin), **អាហ៊ីត្រូមីស៊ីន** (azithromycin), **ដុកស៊ីស៊ីគ្លីន** (doxycycline), **តេត្រាស៊ីគ្លីន** (tetracycline) ។

⇒ ទាមឡា :- **អាហ៊ីត្រូមីស៊ីន** (azithromycin), **ស៊ីប្រូផ្លូសាកស៊ីន** (ciprofloxacin) ។

⇒ រោគស្វាយ :- **បេនហ្សាទីន ប៉េនីស៊ីលីន** (benzathine penicillin), **ដុកស៊ីស៊ីគ្លីន** (doxycycline), **តេត្រាស៊ីគ្លីន** ។

⇒ ជំងឺដោះ :- **ឌីក្លូសាកស៊ីលីន** (dicloxacillin) ។

⇒ ជំងឺស្បែក :- **សេហ្វាលិចស៊ីន** (cephalexin), **ឌីក្លូសាកស៊ីលីន**, **ដុកស៊ីស៊ីគ្លីន**, **ប៉េនីស៊ីលីន** (penicillin), **តេត្រាស៊ីគ្លីន** ។

⇒ ការថែទាំភ្នែកទារកទើបនឹងកើត :- ថ្នាំប៉ូម៉ាត **តេត្រាស៊ីគ្លីន** សំរាប់ដាក់ចូលក្នុងភ្នែក ។



**បំរាម :-** ហាមប្រើ **អេរីត្រូមីស៊ីន** បើអ្នកប្រតិកម្មនឹងថ្នាំអំបូរ **ម៉ាក្រូលីដ** ។

ថ្នាំទឹក **ហ្សង់ស្យាន-វីយ៉ូឡេ ( គ្រីស្តាល់-វីយ៉ូឡេ, មេទីលរ៉ូសានីលីនីយ៉ូម ក្លរ៉ាយ)**
Gentian violet **(*Crystal Violet,* methylrosanilinium chloride)**

- **ហ្សង់ស្យាន-វីយ៉ូឡេ** ជាប្រភេទថ្នាំទឹកមានពណ៌ស្វាយ ប្រើសំរាប់លាងសំលាប់មេរោគសើស្បែក ឬ កៀវជ្រាំងមាត់ និងកំចាត់រោគក្នុងរន្ធយោនី ។
- **សំខាន់ :-** ក្រោយពីប្រើវាកៀវមាត់ទារក ចូរឱ្យទារកដេកផ្កាប់មុខតែបែរមុខទារកទៅចំហៀង ធ្វើដូច្នេះទារកមិនលេបវាចូលពោះច្រើនពេក ។ ថ្នាំទឹក**ហ្សង់ស្យាន-វីយ៉ូឡេ** នឹងដាមពណ៌ស្វាយប្រឡាក់ស្បែកនិងខោអាវ ។
- **<u>ឥទ្ធិពលថ្នាំធ្វើទុក្ខ</u> :-** ការប្រើរយៈពេលយូររាប់អាទិត្យអាចបង្កឱ្យរោលរលាកស្បែក ។ ចូរប្រើលាងដំបៅ ឬ លាបលើស្បែកដាច់រលាត់អាចធ្វើឱ្យស្បែកឡើងជាំពណ៌ស្វាយពេលជាសះស្បើយ ។
- **<u>ជារឿយៗថ្នាំនេះផលិត</u> :-** ជាថ្នាំទឹកចំណុះ 0.5%, 1%, 2% ក្នុងកូនដបនីមួយៗ ។ ថ្នាំម្សៅលាយអាកុលស្រាប់ចំណុះ 0.5% ក្នុងកូនដបនីមួយៗ ។ ឬ ជាថ្នាំម្សៅគ្រីស្តាល់ គឺ **1** ស្លាបព្រាកាហ្វេត្រូវលាយជាមួយទឹកកន្លះលីត្រ ដើម្បីផ្សំជាថ្នាំទឹកដែលមានចំណុះ 2% ។

- **<u>វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ</u> :-**

⇒ ផ្សិតឃីសក្នុងរន្ធយោនី, យកសំឡីស្អាតមួយដុំជ្រលក់ក្នុងទឹកថ្នាំ **1%** ហើយញាត់ចូលរន្ធយោនីឱ្យជ្រៅ ទុកវាឱ្យពេញមួយយប់, ធ្វើបែបនេះឱ្យបាន 3 យប់ជាប់ៗគ្នា ។ អ្នកត្រូវតែយកសំឡីចេញពីរន្ធយោនីរាល់ៗព្រឹក កុំភ្លេចឱ្យសោះ ។

⇒ ផ្សិតឃីសក្នុងមាត់ ( ជ្រាំង) កៀវជ្រាំង ឬ ក្តុលមាត់ជាមួយទឹកថ្នាំចំណុះ **1%** ក្តុលមាត់ឱ្យបាន **1** នាទី 2 ដងក្នុងមួយថ្ងៃ, ប៉ុន្តែហាមលេបវា ។

⇒ ដំបៅស្បែក, ដំបូងប្រើសាប៊ូ និងទឹកស្អាតលាងដំបៅស្អាត ហើយជូតដំបៅឱ្យស្ងួត ។ បន្ទាប់មកយកទឹកថ្នាំលាបលើស្បែក, មាត់ ឬ បរបេយោនី, 3 ដងក្នុងមួយថ្ងៃសំរាប់ 5 ថ្ងៃ ។

⇒ ដំបៅស្បែកសំរាប់អ្នកជំងឺអេដស៍, ដំបូងប្រើសាប៊ូ និងទឹកស្អាតលាងដំបៅឱ្យស្អាត ហើយជូតដំបៅឱ្យស្ងួត ។ បន្ទាប់មកយកទឹកថ្នាំមកលាបស្បែក, មាត់ ឬ បរបេយោនី, 2 ដងក្នុងមួយថ្ងៃ ទាល់តែដំបៅ ឬ កន្ទួលរមាស់ទាំងនោះបាត់ទៅវិញ ។

- **<u>ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ</u> :-**

⇒ ដំបៅស្បែក :- ថ្នាំផ្សះប៉ូម៉ាត (antibiotic ointments), ថ្នាំទឹក **អ៊ីអូឌីន** (iodine) សំរាប់លាប ឬ លាងដំបៅ/កន្ទួលរមាស់ ។

⇒ ជ្រាំងមាត់ :- ប្រើក្រូចឆ្មារកៀវជ្រាំងមាត់ ( ហាមប្រើចំពោះទារក), ថ្នាំ **នីស្តាទីន** (nystatin) ។

⇒ ផ្សិតឃីសក្នុងរន្ធយោនី :- ថ្នាំ **នីស្តាទីន** (nystatin), ថ្នាំ **មីកូណូហ្សុល** (miconozole), ថ្នាំ **ក្លូទ្រីម៉ាហ្សុល** (clotrimazole) ។

**បំរាម :-** ហាមរួមភេទក្នុងអំឡុងពេលប្រើថ្នាំទឹក **ហ្សង់ស្យាន-វីយ៉ូឡេ** ព្យាបាលរោគក្នុងរន្ធយោនី ដើម្បីចៀសវាងចំលងរោគទៅឱ្យដៃគូ/ប្តី ។ ចូរឈប់ប្រើថ្នាំទឹក **ហ្សង់ស្យាន-វីយ៉ូឡេ** បើវាធ្វើទុក្ខឱ្យអ្នករោលក្រហាយ ។ ទុកដាក់វាឱ្យឆ្ងាយពីភ្នែក ។

ថ្នាំ **ហ៊ីដ្រូក័រទីសុន** ឬ **ក័រទីស៊ុល ( អេសហ្សាគ័ត, ហ៊ីយ៉ូកូទីល, សូលូ-ក័រតេហ្វ, ផ្សេងទៀត)**
**Hydrocortisone** or **cortisol (*Eczacort, Hyocotil, Solu-Cortef,* others)**

- ថ្នាំ **ហ៊ីដ្រូក័រទីសុន** ជាថ្នាំក្រែមលាបកំចាត់រោគហើម និងកំចាត់ស្បែករមាស់, ប្រើព្យាបាលស្បែកកន្ទួលរមាស់ ។ វាមានប្រយោជន៍សំរាប់ព្យាបាលជំងឺឫសដូងបាតផងដែរ ។
- **សំខាន់ :-** ហាមបិទបង់ ឬ ស្បែពីលើថ្នាំក្រែម ។ ស្ត្រីបំបៅដោះកូន និងស្ត្រីមានផ្ទៃពោះអាចប្រើថ្នាំក្រែមដោយសុវត្ថិភាព ប៉ុន្តែត្រូវប្រយ័ត្នពេលប្រើថ្នាំគ្រាប់ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** បើប្រើថ្នាំក្រែមលើសពី 10ថ្ងៃ អាចបង្កឱ្យស្បែកស្តើង ឬ សំលាកស្បែក ។
- **ជារឿយៗថ្នាំនេះផលិត :-** ថ្នាំក្រែម ឬ ជាថ្នាំប៉ូម៉ាតក្នុងថាមពលច្រើនយ៉ាង, ជារឿយៗចំណុះ 1% ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

⇒ រោគកន្ទួល, រមាស់ ឬ រោគឫសដូងបាត ចូរលាបថ្នាំក្រែមលើស្បែកកើតជំងឺ, ឱ្យបានពី 3 ទៅ 4 ដង ក្នុងមួយថ្ងៃ ។

ថ្នាំ **អ៊ីប៊ុយប្រូហ្វែន ( អាកទីប្រូហ្វែន, អេដវ៉ិល, ជេនព្រីល, ម៉ូទ្រីន, នូព្រីន, រូហ្វែន, ផ្សេងទៀត)**
**Ibuprofen (*Actiprofen, Advil, Genpril, Motrin, Nuprin, Rufen,* others)**

**បំរាម!**



- ថ្នាំ **អ៊ីប៊ុយប្រូហ្វែន** ធ្វើការបំបាត់ការឈឺចាប់, ហើម, និងគ្រុនក្តៅ ។ វាមានប្រយោជន៍ក្នុងការបន្ធូរបន្ថយភាពមិនស្រណុកពេលកំពុងធ្លាក់ឈាមរដូវ, ឈឺចាប់ដោយជំងឺរលាកសន្លាក់ឆ្អឹង និងជំងឺអេដស៍ ។
- **សំខាន់ :-** បើលេបជាមួយអាហារខ្លះៗ ថ្នាំនេះមិនសូវបង្កឱ្យឈឺក្រហាយក្នុងក្រពះ, ជាពិសេសផលិតផលទឹកដោះគោក៏បានដែរ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** អាចបណ្តាលឱ្យឈឺក្រហាយក្នុងក្រពះ ឬ ឈឺក្នុងពោះ, ហ៊ឹងត្រចៀក, ក្អៀនអាចម៍ ។
- **ជារឿយៗថ្នាំនេះផលិត :-** ជាថ្នាំគ្រាប់ចំណុះ 200 មីលីក្រាម និងលើសពីនេះ ឬ ជាថ្នាំទឹកចំណុះ 100 មីលីក្រាម ក្នុងកូនដបចំណុះ 5 មីលីលីត្រ ។




- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-** ផឹកម្តងៗពីចំណុះ 200 ទៅ 400មីលីក្រាម, 4 ទៅ 6 ដងក្នុងមួយថ្ងៃ ។
  ហាមកុំឱ្យលើសចំណុះ 2400 មីលីក្រាមក្នុងមួយថ្ងៃ ។
- **ថ្នាំឯទៀតដែលអាចប្រើការបានសំរាប់ជំងឺ/រោគ :-**

⇒ ការឈឺចាប់, ហើម និងគ្រុនក្តៅ :- **អាស់ស្ពីរីន** (aspirin) ។

⇒ ការឈឺចាប់ និង គ្រុនក្តៅ :- **អាសេតាមីណូហ្វេន** (acetaminophen) ។



- **ការទាក់ទិនជាមួយឥទ្ធិពលថ្នាំពេទ្យឯទៀត :-**

⇒ ជាមួយថ្នាំ **ហ្វេនីតូអ៊ីន** (phenytoin) អាចបណ្តាលឱ្យកើតបញ្ហាថ្លើម ។



**បំរាម :-** ចៀសវាងប្រើថ្នាំ **អ៊ីប៊ុយប្រូហ្វែន** ក្នុងអំឡុងមួយសប្តាហ៍មុន ឬ ក្រោយពីមានការវះកាត់ ។
ចូរចៀសវាងប្រើថ្នាំនេះនៅរវាង 3 ខែចុងក្រោយនៃការមានផ្ទៃពោះ ។

ថ្នាំ **លីដូកាអ៊ីន ( តូពីកាអ៊ីន, ស៊ីឡូកាអ៊ីន) = Lidocaine (*Topicaine, Xylocaine*)**

- ថ្នាំ **លីដូកាអ៊ីន** (lidocaine gel) ជាថ្នាំខាប់អន្ទិលៗដូចចៅហួយលាបលើស្បែកដើម្បីការពារ និងបន្ថយការឈឺចាប់ដែលបង្កពីបញ្ហារោលក្រហាយលើស្បែក, ស្បែករលាកភ្លើង, ស្បែកដាច់រលាត់ និងសត្វល្អិតទិច/ខាំ ។ ថ្នាំ **លីដូកាអ៊ីន** ជាប្រភេទថ្នាំស្ពឹក ។
- **<u>ឥទ្ធិពលថ្នាំធ្វើទុក្ខ</u> :-** ស្បែកប្រែពណ៌ ( វានឹងបាត់ទៅវិញយ៉ាងលឿន), ពងទឹកលើស្បែក ។
- **<u>ជារឿយៗថ្នាំនេះផលិត</u> :-** ជាថ្នាំប៉ូម៉ាត ចំណុះពី 2% ទៅ 4% ក្នុងមួយទីបៗ ។



---

- **<u>វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ</u> :-**

⇒ វាជួយទប់ស្កាត់ជំងឺសំពាធឈាមលើសស្រួចស្រាវ, ស៊ុលវាបន្តិចចូលរន្ធគូទមុនពេលខ្ទេះអាចម៍ក្មៀនចេញពីរន្ធគូទ ដោយប្រើម្រាមដៃ ។ ឬ ស៊ុលវាបន្តិចចូលរន្ធនោម មុនពេលសិកទុយោចូលរន្ធនោមដើម្បីបូមទឹកនោម ។

ថ្នាំ **មេបេនដាហ្សុល (វ៊ើរម៉ុក) = Mebendazole *(Vermox)*** **បំរាម!**



- ថ្នាំ **មេបេនដាហ្សុល** ជាថ្នាំកំចាត់រោគព្រូនជាច្រើនប្រភេទរួមទាំង ព្រូនទំពក់ ។
- **<u>ឥទ្ធិពលថ្នាំធ្វើទុក្ខ</u>** :- បង្កឱ្យឈឺពោះស្ទំៗ ឬ រាគអាចម៍ ប៉ុន្តែមិនធ្វើទុក្ខទូទៅឡើយ ។
- **<u>ជារឿយៗថ្នាំនេះផលិត</u> :-** ថ្នាំគ្រាប់, មានចំណុះ 100 មីលីក្រាម ។



---

- **<u>វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ</u> :-**

⇒ ព្រូនទំពក់, លេបចំណុះ 100 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ សំរាប់ 3 ថ្ងៃ ។

- **<u>ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ</u> :-** ថ្នាំ **អាល់បេនដាហ្សុល** (albendazole) ។

---



**បំរាម:-** ស្ត្រីមានផ្ទៃពោះហាមប្រើថ្នាំនេះ ។ ហាមឱ្យក្មេងក្រោម 2 ឆ្នាំ ផឹកថ្នាំនេះ ។

ថ្នាំ **មេត្រូនីដាហ្សុល (ផ្លេកជីល, មេតូប្រូតូស្តាត, មេត្រូ, មេត្រូស៊ីន, សាទ្រីក)**
Metronidazole (***Flagyl, Methoprotostat, Metro, Metroxyn, Satric***)

**បំរាម!**



- ថ្នាំ **មេត្រូនីដាហ្សុល** ប្រើព្យាបាលរោគរលាកអាងត្រគាក, រលាករន្ធយោនីនិងស្បែក, និងរាគមូលបង្កពីបាក់តេរី-អាមីប ។
- **សំខាន់ :-** ដៃគូ/ប្ដីរបស់អ្នកត្រូវតែព្យាបាលផងដែរ ។ ហាមផឹកគ្រឿងស្រវឹងពេលកំពុងប្រើថ្នាំ **មេត្រូនីដាហ្សុល** ។ វាអាចធ្វើឱ្យអ្នកចង្អោរ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** អ្នកប្រើដឹងថាក្នុងមាត់មានរសជាតិលោហៈ, ទឹកនោមពណ៌ក្រម៉ៅ, ចង្អោរ ឬ គានតឹងក្នុងពោះ និងឈឺក្បាល ។
- **ថ្នាំនេះតែងផលិត :-** ថ្នាំគ្រាប់, ចំណុះពី 200, 250, 400, និង 500 មីលីក្រាម ឬ ជាថ្នាំស៊ុលចំណុះពី 375 ទៅ 500 មីលីក្រាម ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**
  - ⇒ រលាកស្បូនក្រោយពីកើតកូនហើយ, លេបម្ដងចំណុះ 500 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃទាល់តែគ្រុនក្ដៅបាត់ទៅវិញបាន 2 ថ្ងៃ ។
  - ⇒ បាក់តេរីនៅក្នុងរន្ធយោនី ឬ រោគទ្រីកូម៉ូណាស៍, លេបចំណុះ 2 ក្រាម, តែម្ដងគត់, ចំពោះស្ត្រីមានផ្ទៃពោះ កុំលេបវាចំណុះនេះ ។
  - ⇒ បើអ្នកជាស្ត្រីមានផ្ទៃពោះ, លេបម្ដងពីចំណុះ 400 ទៅ 500 មីលីក្រាម 2 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ ។
  - ⇒ ចំពោះការប្រើថ្នាំលាយចំរុះគ្នាដើម្បីព្យាបាលរោគធ្លាក់សពីរន្ធយោនី ឬ រលាកអាងត្រគាក ចូរអានទំព័រ 162 ។
  - ⇒ រាគមូលលាយឈាមចំពោះអ្នកជំងឺអេដស៍, មាន ឬ គ្មានគ្រុនក្ដៅក៏ដោយ លេបម្ដងចំណុះ 500 មីលីក្រាម 3 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ ។
- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**
  - ⇒ រាគចំពោះអ្នកជំងឺអេដស៍, ថ្នាំ **កូទ្រីម៉ុកសាហ្សុល** (cotrimoxazole), **ន័រផ្លូសាកស៊ីន** (norfloxacin) ។



**បំរាម :-** ចូរឈប់លេបវា បើអ្នកដឹងថាស្ពឹកៗក្នុងខ្លួន ។ ចៀសវាងប្រើថ្នាំ **មេត្រូនីដាហ្សុល** នៅអំឡុង 3 ខែដំបូងនៃការមានផ្ទៃពោះ ។ បើអ្នកចាំបាច់ត្រូវប្រើវា ហាមផឹកចំណុះ 1 ដូសធំ (ចំនួនថ្នាំច្រើន) នៅអំឡុងពេលមានផ្ទៃពោះ ។ បើអ្នកបំបៅដោះកូន អាចផឹកចំណុះ 1 ដូសធំបានដោយសុវត្ថិភាព ។ បុគ្គលដែលមានជំងឺថ្លើមដូចជា ខាន់លឿង ហាមប្រើថ្នាំនេះ ។

ថ្នាំ **មីកូណាហ្សុល (ដាក់តារីន, ហ្វង់តូពិច, មីកាទីន, ម៉ូនីស្តាត)**
**Miconazole (*Daktarin, Fungtopic, Micatin, Monistat*)**

**បំរាម!**



- ថ្នាំ **មីកូណាហ្សុល** ជាថ្នាំកំចាត់រោគផ្សិត ប្រើព្យាបាលផ្សិតយីស និងរោគផ្សិតផ្សេងៗទៀតក្នុងរន្ធយោនី ឬ លើស្បែក ។
- **សំខាន់ :-** បើថ្នាំ**មីកូណាហ្សុល** ធ្វើឱ្យអ្នករលាកក្រហាយ ឈប់ប្រើវា ។ ពេលកំពុងប្រើថ្នាំ**មីកូណាហ្សុល** ចៀសវាងរួមភេទឱ្យបាន 4 ទៅ 5 ថ្ងៃ ដើម្បីកុំឱ្យចំលងរោគទៅដៃគូ/ប្ដី ។ ចូរទុកដាក់វាឱ្យឆ្ងាយពីភ្នែក ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** រលាកក្រហាយ ។
- **ថ្នាំនេះតែងផលិត :-** ថ្នាំក្រែមចំណុះ 2%, ចូរស៊ុលចំណុះ 100 និង 200 មីលីក្រាម ។




- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**
  - ⇒ ផ្សិតយីសនៃរន្ធយោនី :-
    - ♦ ស៊ុលថ្នាំក្រែម 5 ក្រាម, ចូលរន្ធយោនីឱ្យជ្រៅ រាល់ៗយប់សំរាប់ 7 យប់ ។ ឬ
    - ♦ ស៊ុលថ្នាំក្រែម 100 មីលីក្រាម, ចូលរន្ធយោនីឱ្យជ្រៅ រាល់ៗយប់សំរាប់ 7 យប់ ។ ឬ
    - ♦ ស៊ុលថ្នាំក្រែម 200 មីលីក្រាម, ចូលរន្ធយោនីឱ្យជ្រៅ រាល់ៗយប់សំរាប់ 3 យប់ ។
  - ⇒ ផ្សិតយីសកើតលើស្បែក :- លាបថ្នាំក្រែមលើស្បែកកើតរោគ, 2 ដងក្នុងមួយថ្ងៃ រៀងរាល់ថ្ងៃទាល់តែរោគនោះជាដាច់ ។
- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**
  - ⇒ សំរាប់រោគផ្សិតយីសគ្រប់យ៉ាង **ហ្សង់ស្យាន-វីអូឡេ** (gentian violet), **នីស្តាទីន** (nystatin), **ក្លូទ្រីម៉ាហ្សុល** (clotrimazole) ។



**បំរាម :-** ហាមប្រើថ្នាំ **មីកូណាហ្សុល** នៅអំឡុងពេលមានផ្ទៃពោះ 3 ខែដំបូង ។

ថ្នាំ **នីហ្វេឌីពីន ( អាដាឡាត់, នេឡាពីន, នីហ្វេកាដ, នីហ្វេដ, ប្រូការឌីយ៉ា)** =
**Nifedipine (*Adalat, Nelapine, Nifecard, Nifed, Procardia*)**

- ថ្នាំ **នីហ្វេឌីពីន** ជាថ្នាំប្រើបញ្ចុះសំពាធឈាមលើសបានយ៉ាងឆាប់រហ័ស ។
- **សំខាន់ :-** ហាមផឹកទឹកទំពាំងបាយជូរជាមួយថ្នាំ **នីហ្វេឌីពីន** ។ វាធ្វើឱ្យថ្នាំគ្មានប្រសិទ្ធភាព ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ឈឺក្បាល, វិលមុខ, រោលស្បែក, មុខឡើងក្រហម១ ។
- **ថ្នាំនេះតែងផលិត :-** ថ្នាំគ្រាប់រាងមូលទ្រវែងទន់១ ឬ គ្រាប់រឹង, ចំណុះ 10 មីលីក្រាម ។



- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

⇒ សំរាប់សំពាធឈាមឡើងខ្លាំងជាបន្ទាន់ ដែលបង្កពីជំងឺសំពាធឈាមលើសស្រួចស្រាវតែប៉ុណ្ណោះ :-

- ♦ ថ្នាំគ្រាប់រាងមូលទ្រវែងទន់១, ចូរខាំគ្រាប់ថ្នាំឱ្យធ្លាយ ហើយលេបវា ឬ ចោះវាធ្លាយ ហើយដាក់វាក្រោមអណ្តាត ។
- ♦ ថ្នាំគ្រាប់រឹង, ចូរកិនថ្នាំឱ្យម៉ត់ ហើយលាយទឹកស្អាតឱ្យថ្នាំខាប់បុិ១ ហើយយកថ្នាំនោះដាក់ក្រោមអណ្តាត ឬ ទំពារគ្រាប់ថ្នាំឱ្យបែក ហើយលេបវាជាមួយទឹកបន្តិច ។



- **ការទាក់ទិនជាមួយឥទ្ធិពលថ្នាំពេទ្យឯទៀត :-**

⇒ ជាមួយថ្នាំ **ការបាម៉ាហ្សេពីន** (carbamazepine), **ហ្វេណូបាប៊ីតាល់** (Phenobarbital) ឬ **ហ្វេនីតូអ៊ីន** (phenytoin) :- ថ្នាំទាំងនេះអាចគ្មាន ប្រសិទ្ធភាពនៅរយៈពេលកំពុងប្រើថ្នាំ **នីហ្វេឌីពីន** ។



**បំរាម :-** ថ្នាំ **នីហ្វេឌីពីន** គួរត្រូវប្រើចំពោះតែជំងឺសំពាធឈាមលើសស្រួចស្រាវប៉ុណ្ណោះ ដោយបុគ្គលដែលមានរបួសសរសៃប្រសាទឆ្អឹងខ្នង ( អានទំព័រ 117) ។ ថ្នាំ **នីហ្វេឌីពីន** មិនត្រូវយកទៅប្រើចំពោះជំងឺសំពាធឈាមលើសប្រចាំកាយធម្មតា, ដំណើរឈាមឡើង ឬ បញ្ហាបេះដូងឡើយ ។

ថ្នាំ **នីត្រូហ្វុយរ៉ង់តូអ៊ីន ( ហ្វុយរ៉ាដង់ទីន, ម៉ាក្រូប៊ីដ, ម៉ាក្រូដង់ទីន)** =
**Nitrofurantoin (*Furadantin, Macrobid, Macrodantin*)**

**បំរាម!**



- ថ្នាំ **នីត្រូហ្វុយរ៉ង់តូអ៊ីន** ជាថ្នាំផ្សះដែលត្រូវប្រើព្យាបាលរោគក្នុងប្លោកនោម ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ចង្អោរ ឬ ក្អួត, ឈឺក្បាល, ផោម ។ ចូរផឹកថ្នាំនេះជាមួយចំណីអាហារ ឬ ទឹកដោះគោ ដើម្បីបន្ថយអាការៈធ្វើទុក្ខទាំងនេះ ។
- **រោគសញ្ញានៃការប្រើថ្នាំលើសកំណត់ :-** ក្អួត, ឈឺដើមទ្រូង ។ ទឹកនោមមានពណ៌លឿងចាស់ ឬ ពណ៌កាហ្វេ ។
- **ថ្នាំនេះតែងផលិត :-** ជាថ្នាំគ្រាប់ចំណុះពី 25, 50, ឬ 100 មីលីក្រាម ឬ ថ្នាំទឹកស៊ីរ៉ូមានចំណុះ 25 មីលីក្រាម/5 មីលីលីត្រ ។





- **វិធីប្រើថ្នាំសំរាប់ជំងឺ/រោគ :-**

⇒ ព្យាបាលរោគក្នុងប្លោកនោម, លេបម្តងចំណុះ 100 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ សំរាប់ 3 ថ្ងៃ ។

- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**

⇒ ព្យាបាលរោគក្នុងប្លោកនោម អាចប្រើថ្នាំ **អាម៉ុកស៊ីស៊ីន** (amoxicillin), **កូទ្រីម៉ុកសាហ្សុល** (cotrimoxazole), **ន័រផ្លូសាកស៊ីន** (norfloxacin) ។



**បំរាម :-** បុគ្គលដែលមានបញ្ហាតម្រងនោម ហាមប្រើថ្នាំនេះ ។ ស្ត្រីដែលស្ថិតក្នុងអំឡុងពេល 3 ខែចុងក្រោយនៃការមានផ្ទៃពោះ ហាមប្រើថ្នាំនេះ ។

ថ្នាំ **ន័រផ្លូសាកស៊ីន (លិចស៊ីន័រ, ន័រ៉ុកស៊ីន, អ៊ុយរីត្រាស៊ីន)** = Norfloxacin **(*Lexinor, Noroxin, Uritracin*)** **បំរាម!**



- ថ្នាំ **ន័រផ្លូសាកស៊ីន** ជាថ្នាំផ្សំនៃអំបូរថ្នាំ **គីនណូឡូន** (quinolone) ប្រើព្យាបាលរោគប្រមេះ, រោគក្នុងប្លោកនោម និងតម្រងនោម ព្រមទាំងជំងឺរាគធ្ងន់ធ្ងរ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** អាចបង្កឱ្យឈឺក្បាលតិចតួច និងកើនឥទ្ធិពលកាហ្វេអ៊ីន ។ ចូរលេប **1** ម៉ោងមុនហូបអាហារ ឬ **2** ម៉ោងក្រោយពីហូបអាហារ ។
- **ជារឿយៗថ្នាំនេះផលិត :-** ថ្នាំគ្រាប់មានចំណុះ 400 មីលីក្រាម ។



- **វិធីប្រើថ្នាំសំរាប់ព្យាបាលជំងឺ/រោគ :-**

⇒ រោគក្នុងប្លោកនោម, លេបម្តងចំណុះ 400 មីលីក្រាម 2 ដងក្នុងមួយថ្ងៃ សំរាប់ 3 ថ្ងៃ ។

⇒ រោគក្នុងតម្រងនោម, លេបម្តងចំណុះ 400 មីលីក្រាម 2 ដងក្នុងមួយថ្ងៃ សំរាប់ 10 ថ្ងៃ ។

⇒ រោគប្រមេះ, លេបចំណុះ 800 មីលីក្រាម តែម្តងគត់ ។

⇒ ជំងឺរាគចំពោះអ្នកជំងឺអេដស៍, លេបចំណុះ 400 មីលីក្រាម តែម្តងគត់ ។

- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-**

⇒ រោគក្នុងប្លោកនោម, អាចប្រើថ្នាំ **អាម៉ុកស៊ីស៊ីលីន** (amoxicillin), **កូទ្រីម៉ុកសាហ្សុល** (cotrimoxazole), **នីត្រូហ្វុយរ៉ង់តូអ៊ីន** (nitrofurantoin) ។

⇒ រោគក្នុងតម្រងនោម អាចប្រើថ្នាំ**អាម៉ុកស៊ីស៊ីលីន, សេហ្វិចស៊ីម** (cefixime), **ស៊ីប្រូផ្លូសាកស៊ីន** (ciprofloxacin), **កូទ្រីម៉ុកសាហ្សុល ។**

⇒ រោគប្រមេះ អាចប្រើថ្នាំ **សេហ្វិចស៊ីម, ស៊ីប្រូផ្លូសាកស៊ីន, ដុកស៊ីស៊ីគ្លីន** (doxycyline).

⇒ ជំងឺរាគចំពោះអ្នកជំងឺអេដស៍ អាចប្រើថ្នាំ **កូទ្រីម៉ុកសាហ្សុល, មេត្រូនីដាហ្សុល** (metronidazole).



**បំរាម :-** ចូរផឹកទឹកឱ្យច្រើនពេលលេបថ្នាំនេះ ។ ហាមប្រើថ្នាំនេះក្នុងពេលកំពុងប្រើថ្នាំ **អានតាស៊ីត** (antacids) ឬ វីតាមីនផ្ទុកជាតិស័ង្កសី ឬ ជាតិដែក ។ បើអ្នកមានប្រតិកម្មចំពោះថ្នាំ **ន័រផ្លូសាកស៊ីន** ឬ ថ្នាំ **គីនណូឡូន** ហាមប្រើវា ។ ស្ត្រីមានផ្ទៃពោះ, ស្ត្រីបំបៅដោះកូន និងក្មេងស្រីក្រោម 16 ឆ្នាំ ហាមប្រើថ្នាំ **ន័រផ្លូសាកស៊ីន** ។

---

ថ្នាំ **នីស្តាទីន (ឌឺម៉ូឌិច, ម៉ីកូស្តាទីន, នីលស្តាត, នីស្តាត)** = Nystatin **(*Dermodex, Mycostatin, Nilstat, Nystat*)**

- ថ្នាំ **នីស្តាទីន** ជាថ្នាំបំបាត់រោគផ្សិតយីស ប្រើព្យាបាលជ្រាំងក្នុងមាត់, រោគផ្សិតក្នុងទ្វារមាស ឬ លើស្បែក ។
- **សំខាន់ :-** ថ្នាំ **នីស្តាទីន** ធ្វើការកំចាត់តែរោគប្រភេទ**ផ្សិតយីសកង់ឌីដា**ប៉ុណ្ណោះ ខណៈដែលថ្នាំ **មីកូណាហ្សុល** (miconazole) ធ្វើការកំចាត់រោគផ្សិតផ្សេងៗទៀត ។ ថ្នាំ **ក្លូទ្រីម៉ាហ្សុល** (clotrimazole) ប្រហែលជាមានតំលៃថោក និងងាយប្រើប្រាស់ ។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំគ្រាប់សំរាប់ស៊ុល, ចំណុះ 100,000 យូនីត ។ ថ្នាំ **ឡូហ្សិង** (lozenges) សំរាប់លេប, ចំណុះ 200,000 យូនីត ។ ថ្នាំក្រែម, ចំណុះ 100,000 យូនីតក្នុងមួយក្រាម ។ ថ្នាំទឹកចំណុះ 100,000 យូនីតក្នុងមួយមីលីលីត្រ ។



- **វិធីប្រើថ្នាំសំរាប់ព្យាបាលជំងឺ/រោគ :-**

⇒ រោគក្នុងមាត់ ឬ បំពង់ក, ថ្នាំទឹកបៀមក្នុលមាត់ម្តងៗចំណុះ 1 មីលីលីត្រ, បៀមទុកក្នុងមាត់ឱ្យបាន **1** នាទី ហើយលេបវា, អនុវត្តបែបនេះ 3 ទៅ 4 ដងក្នុងមួយថ្ងៃ, ធ្វើដូចនេះឱ្យបាន 5 ថ្ងៃជាប់ៗគ្នា ។

⇒ រោគលើស្បែក រក្សាម្តុំស្បែកកើតរោគឱ្យស្ងួត ហើយលាបថ្នាំក្រែម 3 ដងក្នុងមួយថ្ងៃ ទាល់តែស្បែករោលនោះបាត់ទៅវិញ ។

⇒ រោគក្នុងទ្វារមាស ដាក់ថ្នាំក្រែមចូលក្នុងទ្វារមាស 2 ដងក្នុងមួយថ្ងៃ សំរាប់ពី 10 ទៅ 14 ថ្ងៃ ឬ ប្រើថ្នាំស៊ុលចំណុះ 100,000 យូនីត ពេលចូលដេកយប់, ស៊ុលចូលជ្រៅក្នុងទ្វារមាស សំរាប់ 14 យប់ ។

- **ថ្នាំឯទៀតដែលអាចប្រើការបានចំពោះជំងឺ/រោគ :-** ថ្នាំ **មីកូណាហ្សុល, ក្លូទ្រីម៉ាហ្សុល, ទឹកខ្មេះ** ឬ ទឹកថ្នាំ **ហ្សង់ស្យាន-វីអូឡេ** ។



**បំរាម :-** បើថ្នាំ **នីស្តាទីន** បង្កឱ្យអ្នករោលរោកស្បែក ឈប់ប្រើវា ។ ចៀសវាងរួមរ័ក្សក្នុងពេលកំពុងប្រើថ្នាំ **នីស្តាទីន** ធ្វើបែបនេះអ្នកមិនចំលងរោគដល់ដៃគូ/ប្តី ។

ថ្នាំ **អាសេតាមីណូហ្វេន** ឬ **ប៉ារ៉ាសេតាម៉ុល ( អាប៉ាប, ប៉ាណាដុល, តេមប្រា, ទីលីណុល និងថ្នាំងទៀត)**
Acetaminophen or paracetamol or **(*APAP, Panadol, Tempra, Tylenol,* others)**

- ថ្នាំ **អាសេតាមីណូហ្វេន** ឬ **ប៉ារ៉ាសេតាម៉ុល** ជាឈ្មោះពីរសំរាប់ថ្នាំតែមួយ ប្រើបន្ថយការឈឺចាប់ និងគ្រុនក្តៅល្មមៗ ។ វាជាថ្នាំបំបាត់ការឈឺចាប់មានសុវត្ថិភាព ។ បុគ្គលកើតដំបៅក្រពះអាចប្រើថ្នាំនេះជំនួសថ្នាំ **អាស្ពីរីន** (aspirin) ឬ **អ៊ីប៊ុយប្រូហ្វេន** (ibuprofen) ព្រោះវាមិនបង្កឱ្យឈឺក្រពះ ។ ស្ត្រីមានផ្ទៃពោះអាចប្រើថ្នាំ **ប៉ារ៉ាសេតាម៉ុល** ហើយកុមារក៏អាចប្រើបាន ប៉ុន្តែត្រូវប្រើវាត្រឹមចំណុះទាបជាងមនុស្សពេញវ័យ ។
- **សំខាន់ :-** ថ្នាំ **ប៉ារ៉ាសេតាម៉ុល** មិនព្យាបាលជំងឺឱ្យជាសះស្បើយឡើយ វាគ្រាន់តែជួយបន្ថយការឈឺចាប់ ឬ ក្តៅខ្លួនប៉ុណ្ណោះ ។ ការសំខាន់នោះគឺត្រូវរកមូលហេតុឈឺចាប់ ឬ ក្តៅខ្លួនឱ្យឃើញ ហើយព្យាបាលវាឱ្យជាសះស្បើយ ។
- **រោគសញ្ញានៃការប្រើថ្នាំលើសកំណត់ :-** ចង្អោរ, ក្អួត, ឈឺចាប់ក្នុងពោះ ។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំគ្រាប់ចំណុះពី 100, 325 និង 500 មីលីក្រាម ។ ថ្នាំទឹកចំណុះពី 120 និង 160មីលីក្រាមនៃកូនដបចំណុះ 5 មីលីលីត្រ ឬ ថ្នាំស៊ុលចំណុះពី 80, 120, 300, 325, ឬ 650 មីលីក្រាម ។ ឬ ថ្នាំបន្តក់ចំណុះ 80 មីលីក្រាមក្នុងកូនដបចំណុះ 0.8 មីលីលីត្រ ។



- **វិធីប្រើថ្នាំសំរាប់ព្យាបាលជំងឺ/រោគ :-**

⇒ ការឈឺចាប់ និងគ្រុនក្តៅល្មមៗ, ផឹកម្តងចំណុះពី 500 ទៅ 1000 មីលីក្រាម, រៀងរាល់ពី 4 ទៅ 6 ម៉ោង តាមត្រូវការ ។

- **ថ្នាំងទៀតដែលអាចប្រើព្យាបាលជំងឺ/រោគ :-**

⇒ ការឈឺចាប់, ក្តៅខ្លួន ឬ ហើម :- ថ្នាំ **អាស្ពីរីន** ឬ **អ៊ីប៊ុយប្រូហ្វេន** អាចប្រើបាន ប៉ុន្តែហាមប្រើពេលកំពុងមានផ្ទៃពោះ ។



**បំរាម :-** ហាមប្រើបើអ្នកមានក្រិនថ្លើម ឬ ខូចប្លោកនោម ។ វាអាចបង្កឱ្យខូចខាតកាន់តែខ្លាំង កាលណាអ្នកប្រើវាទៀងទាត់ក្នុងពេលផឹក និងក្រោយពេលផឹកគ្រឿងស្រវឹង ។

ថ្នាំ **ប៉េនីស៊ីលីន ( បេនតាពិន វី-ខេ, ពិនវី-ខេ, ហ្វេណូស៊ីមេទីល ប៉េនីស៊ីលីន)**
Penicillin **(*Bentapen VK, PenVee K,* phenoxymethyl penicillin)**

- ថ្នាំ **ប៉េនីស៊ីលីន** ជាថ្នាំផ្សះប្រើព្យាបាលរោគមាត់, ធ្មេញ, ស្បែក, ស្បូន, និងជំងឺជាច្រើនទៀត ។ គួរឱ្យស្តាយ ការប្រឆាំងនឹងថ្នាំ **ប៉េនីស៊ីលីន** បានកើតឡើងយ៉ាងច្រើន ហើយវាលែងសូវមានប្រយោជន៍ដូចពីមុន ។
- **សំខាន់ :-** ចូរឃ្លាំមើលប្រតិកម្មថ្នាំ និង រ៉ែអស្មុងថ្នាំស្រួចស្រាវ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** កើតរោលកន្ទួលលើស្បែក ។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំគ្រាប់ចំណុះពី 250 ទៅ 500 មីលីក្រាម ។ ថ្នាំទឹកចំណុះពី 125 ទៅ 250 មីលីក្រាម ក្នុងកូនដបចំណុះ 5 មីលីលីត្រ ។



- **វិធីប្រើថ្នាំសំរាប់ព្យាបាលជំងឺ/រោគ :-**

⇒ រោគលើស្បែក ឬ ដំបៅ, លេបចំណុះ 250 មីលីក្រាម 4 ដងក្នុងមួយថ្ងៃសំរាប់ 10 ថ្ងៃ ។

⇒ រលាកស្បូនក្រោយពីសម្រាលកូន, លេបចំណុះ 250 មីលីក្រាម ( ស្មើនឹងចំណុះ 400,000យូនីត) 4 ដងក្នុងមួយថ្ងៃសំរាប់ 7 ថ្ងៃ ។

- **ថ្នាំងទៀតដែលអាចប្រើការបានសំរាប់ជំងឺ/រោគ :-**

⇒ រលាកស្បូនក្រោយពីសម្រាលកូន ប្រើថ្នាំ**អាម៉ុកស៊ីស៊ីលីន** (amoxicillin), **អំពីស៊ីលីន** (ampicillin), **ស៊ីប្រូផ្លូសាកស៊ីន** (ciprofloxacin), **ដុកស៊ីស៊ីគ្លីន** (doxycycline), **មេត្រូនីដាហ្សុល** (metronidazole) ។

⇒ រោគលើស្បែក ឬ ដំបៅ ប្រើថ្នាំ **ឌីក្លូស៊ីស៊ីលីន** (dicloxicillin), **ដុកស៊ីស៊ីគ្លីន, អេរីត្រូម៉ីស៊ីន** (erythromycin), **តេត្រាស៊ីគ្លីន** (tetracycline) ។



**បំរាម :-** ហាមប្រើ បើអ្នកមានប្រតិកម្ម ឬ រ៉ែអស្មុងចំពោះថ្នាំណាមួយក្នុងអំបូរថ្នាំ **ប៉េនីស៊ីលីន** ។

បំរាម!



ថ្នាំ **ប៉ូដូហ្វីលីន ( កុនឌីលុច, ប៉ូដូកុន-25, ប៉ូដូហ្វីលុម រេស៊ីន)**
Podophyllin (***Condylox, Podocon-25,* podophylom resin**)

- ថ្នាំ **ប៉ូដូហ្វីលីន** ជាថ្នាំទឹកសំរាប់លាបឱ្យចំលើឫសដុះលើប្រដាប់ភេទ ( រោគសេមាន់) ដើម្បីធ្វើឱ្យវារួញ ។
- **សំខាន់ :-** ថ្នាំ **ប៉ូដូហ្វីលីន** គឺងាយរលាកស្បែកដែលគ្មានជំងឺ ។ ចូរប្រើចំនួនតិចពេលលាបវាម្តងៗ ( 1/2 មីលីលីត្រ ឬ តិចជាងនេះ) ។ មុនពេលលាបថ្នាំ **ប៉ូដូហ្វីលីន** លើឫស ចូរប្រើក្រមួនប្រេងកាត **វ៉ាស៊ីសលីន** (vaseline) លាបស្បែកដែលគ្មានជំងឺជុំវិញឫសនោះ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ងាយលរលាកស្បែកខ្លាំងណាស់ ចូរប្រយ័ត្នកុំឱ្យវាហៀរទៅលើស្បែកដែលល្អស្អាត ។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំទឹកចំណុះពី 10% ទៅ 25% ។



- **វិធីប្រើថ្នាំសំរាប់ព្យាបាលជំងឺ/រោគ :-** យកសំឡីត្បារត្រចៀក ឬ រុំសំឡី ឬ រុំកំណាត់ទន់ស្អាតមួយចំរៀកតូច ជាមួយចុងឈើចាក់ធ្មេញ ឬ ជើងធូប, យកវាជ្រលក់ក្នុងទឹកថ្នាំ ហើយលាបឱ្យចំលើឫស ។ 4 ម៉ោងក្រោយ ចូរលាងតំបន់ឫសឱ្យស្អាតជាមួយទឹកនិងសាប៊ូ ។ ប្រើថ្នាំនេះ 1 អាទិត្យម្តង សំរាប់ 4 អាទិត្យ ។
- **ថ្នាំឯទៀតដែលអាចប្រើការបានសំរាប់ជំងឺ/រោគ :-**

⇒ ឫសដុះលើប្រដាប់ភេទ, ប្រើថ្នាំ **ទ្រីក្លរ៉ាសេទិច** (trichloracetic) ឬ **អាស៊ីត ប៊ីក្លរ៉ាសេទិច** (bichloracetic acid) ។



**បំរាម :-** ហាមលាបថ្នាំនេះលើឫសដែលចេញឈាម, ខ្មៅពីកំណើត, ប្រជ្រុយដុះ, ឫសមានដុះរោម ឬ ដាក់វាក្នុងមាត់ ។ ឈប់ប្រើវាទៀត បើមានរលាកស្បែកធ្ងន់ធ្ងរកើតឡើង ។ ហាមប្រើថ្នាំនេះ បើអ្នកកំពុងមានផ្ទៃពោះ ឬ បំបៅដោះកូន ។

បំរាម!



ថ្នាំ **ប្រូបេនីស៊ីដ ( បេនេមីដ, ប្រូបាឡាន)** = Probenicid (***Benemid, Probalan***)

- ថ្នាំ **ប្រូបេនីស៊ីដ** ត្រូវបានប្រើលាយគ្នានឹងថ្នាំផ្សះខ្លះនៃអំបូរថ្នាំ **ប៉េនីស៊ីលីន** (penicillin) ដើម្បីធ្វើឱ្យជាតិថ្នាំ **ប៉េនីស៊ីលីន** ស្ថិតនៅក្នុងរាងកាយបានយូរ ។ ករណីនេះធ្វើឱ្យការព្យាបាលមានប្រសិទ្ធភាព ។
- **សំខាន់ :-** ហាមផ្តល់ថ្នាំ **ប្រូបេនីស៊ីដ** ដល់ក្មេងអាយុក្រោម 2 ឆ្នាំ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ជួនកាលធ្វើឱ្យឈឺក្បាល, ចង្អោរ ឬ ក្អួត ។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំគ្រាប់ចំណុះ 500 មីលីក្រាម ។



- **វិធីប្រើថ្នាំសំរាប់ព្យាបាលជំងឺ/រោគ :-**

⇒ លេបម្តងចំណុះពី 500 មីលីក្រាម ទៅ 1 ក្រាម រាល់ពេលអ្នកប្រើថ្នាំផ្សះនៃអំបូរថ្នាំ **ប៉េនីស៊ីលីន** ។



**បំរាម :-** ប្រើឱ្យប្រយ័ត្នប្រយែងបំផុតក្នុងពេលកំពុងមានផ្ទៃពោះ និងបំបៅដោះកូន ឬ បើអ្នកមានកើតជំងឺក្រពះ ។

ថ្នាំ**ប្រូកាអ៊ីន ប៉េនីស៊ីលីន** (**បេនហ្ស៊ីលប៉េនីស៊ីលីន ប្រូកាអ៊ីន, ប៊ីស៊ីលីន ស៊ី-អរ, គ្រីស្ទីស៊ីលីន, ឌុយរ៉ាស៊ីលីន អេ-អេស, ប៉ហ្វីហ្សេប៉េន អេ-អេស, វីស៊ីលីន**)
Procaine penicillin (***Benzylpenicillin Procaine, Bicillin C-R, Crysticillin, Duracillin AS, Penadur, Pfizepen AS, Wycillin***)

- ថ្នាំ**ប្រូកាអ៊ីន ប៉េនីស៊ីលីន** ជាថ្នាំផ្សះប្រើព្យាបាលរោគរលាកសួត និងជំងឺជាច្រើនដូចជា ដំបៅគ្រែ និងប្រមេះ ដែលវាមិនប្រឆាំងថ្នាំ **ប៉េនីស៊ីលីន**។
- **សំខាន់ :-** ពេលប្រើវាជាមួយថ្នាំ **ប្រូបេនីស៊ីដ** (probenicid) អានទំព័រ 351, ចំនួនថ្នាំ **ប៉េនីសស៊ីលីន** (penicillin) កើនឡើងក្នុងឈាម និងមានឥទ្ធិពលយូរ បែបនេះធ្វើឱ្យការព្យាបាលមានប្រសិទ្ធភាពល្អ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** អាចបង្កឱ្យស្ត្រីកើតរោគផ្សិតយីស ហើយចំពោះទារក ឬ ក្មេងតូច អាចកើតរោលកន្ទួលលើកំប៉េះគូថ។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំម្សៅលាយវត្ថុរាវច្រកកូនដបតូចៗសំរាប់ចាក់ ពីចំណុះ 300,000 និង 400,000 និង 600,000 យូនីត។ ថ្នាំម្សៅសំរាប់លាយចាក់, ចំណុះ **1** ក្រាម = **1** លានយូនីត។

---

- **វិធីប្រើថ្នាំសំរាប់ព្យាបាលជំងឺ/រោគ :-**

⇒ ក្តៅខ្លួននៅអំឡុងពេលមានផ្ទៃពោះ ចាក់ម្តងចំណុះ **1.2** លានយូនីត, ចាក់ថ្នាំនេះចូលសាច់ដុំ រៀងរាល់ 12 ម៉ោងម្តងៗ ពេលអ្នកកំពុងយកអ្នកជំងឺទៅព្យាបាលនៅមន្ទីរពេទ្យ។

- **ថ្នាំឯទៀតដែលអាចប្រើការបានសំរាប់ជំងឺ/រោគ :-**

⇒ ក្តៅខ្លួននៅអំឡុងពេលមានផ្ទៃពោះក៏អាចប្រើថ្នាំ **អំពីស៊ីលីន** (ampicillin), **មេត្រូនីដាហ្សុល** (metronidazole)។

---

**បំរាម :-** ថ្នាំ**ប្រូកាអ៊ីន ប៉េនីស៊ីលីន** អាចបង្កឱ្យរោគហឺតធ្វើទុក្ខ ចំពោះមនុស្សដែលកើតហឺត។ ហាមប្រើថ្នាំនេះជាមួយថ្នាំ **តេត្រាស៊ីគ្លីន** (tetracycline)។ ហាមប្រើថ្នាំ **ប្រូកាអ៊ីន ប៉េនីស៊ីលីន** បើអ្នករ៉េអស្សុងចំពោះថ្នាំផ្សះក្នុងអំបូរ **ប៉េនីស៊ីលីន**។ ហាមចាក់ថ្នាំនេះចូលសរសៃជាដាច់ខាត។

ថ្នាំ **តេតាណូស តុកសូអ៊ីដ** (**តេតាវ៉ាក្ស**) = tetanus toxoid ***(Tetavax)***

- ថ្នាំ **តេតាណូស តុកសូអ៊ីដ** ជាថ្នាំវ៉ាក់សាំងដែលផ្តល់ឱ្យដើម្បីការពារជំងឺតេតាណូស។ វាត្រូវបានផ្តល់ឱ្យនៅអំឡុង ឬ ក្រោយពេលមានផ្ទៃពោះ ឬ ក្រោយពីរលូតកូន។ បើស្ត្រីទទួលបានថ្នាំវ៉ាក់សាំងនេះចំនួន 2 ដង (ជាការល្អបើបានចាក់ 3 ដង) នៅពេលកំពុងមានផ្ទៃពោះ វានឹងជួយទប់ស្កាត់មិនឱ្យទារកទើបនឹងកើតឆ្លងជំងឺដ៏សាហាវនេះ។
- **សំខាន់ :-** វ៉ាក់សាំងការពារជំងឺតេតាណូស គួរត្រូវផ្តល់ឱ្យដល់មនុស្សគ្រប់គ្នា តាំងពីនៅវ័យកុមារភាពឡើងទៅ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** ឈឺចាប់, ឡើងក្រហម, ឡើងកំដៅខ្លួន, ហើមតិចតួច។
- **ថ្នាំនេះតែងផលិតជា:-** ថ្នាំទឹកសំរាប់ចាក់ចំណុះ 4, 5 ឬ 10 យូនីតក្នុងកូនដបចំណុះ 0.5 មីលីលីត្រ។

---

- **វិធីប្រើថ្នាំសំរាប់ព្យាបាលជំងឺ/រោគ :-** អ្នកត្រូវចាក់វ៉ាក់សាំងនេះឱ្យបាន 5 ដង បន្ទាប់ពីនោះត្រូវចាក់រៀងរាល់ 10 ឆ្នាំម្តង ដើម្បីឱ្យសុខភាពអ្នកមានសុវត្ថិភាពពេញមួយជីវិត។
- **ចំពោះការចាក់ថ្នាំវ៉ាក់សាំងម្តងៗ :-** ត្រូវចាក់ **1** ម្ជុលនៃចំណុះ **0.5** មីលីលីត្រ ចូលក្នុងសាច់ដុំដើមដៃក្បែរស្មា។

ថ្នាំ តេត្រាស៊ីគ្លីន ( **អាក្រូម៉ីស៊ីន, ស៊ូម៉ីស៊ីន, តេរ៉ាម៉ីស៊ីន, តេរ៉ាស៊ីន, អុយនីម៉ីស៊ីន**)

**Tretracycline (Achromycin, Sumycin, Terramycin, Theracine, Unimycin)**

**បំរាម!**



- ថ្នាំ **តេត្រាស៊ីគ្លីន** ជាថ្នាំផ្សះនៃអំបូរ **តេត្រាស៊ីគ្លីន** ។ វាប្រើព្យាបាលរោគជាច្រើនរួមមាន ក្លាមីដា, ស្វាយ, រលាកអាងត្រគាក, រោគក្នុងប្លោកនោម និង តម្រងនោម ។ ថ្នាំ **ដុកស៊ីស៊ីគ្លីន** ក៏អាចប្រើបានដែរសំរាប់រោគដូចគ្នាទាំងនេះ វាថោក និងងាយស្រួលលេប, ចូរអានទំព័រ 341 ។
- **សំខាន់ :-** ថ្នាំ **តេត្រាស៊ីគ្លីន** មិនជួយបំបាត់ជំងឺផ្តាសាយ ឬ ទប់ស្កាត់ជំងឺកាមរោគឡើយ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :-** បើអ្នកស្ថិតក្រោមកំដៅថ្ងៃ ថ្នាំ **តេត្រាស៊ីគ្លីន** អាចធ្វើឱ្យស្បែករលាកខ្លួល វាក៏អាចបង្កឱ្យរាគអាចម៍ ឬ ឆ្អល់ពោះផងដែរ ។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំគ្រាប់រាងមូលទ្រវែងចំណុះពី 100, 250 ឬ 500 មីលីក្រាម ។ ឬ ថ្នាំប៉ូម៉ាត ចំណុះ 1% ក្នុងកូនទីបនីមួយៗ ។




- **វិធីប្រើថ្នាំសំរាប់ព្យាបាលជំងឺ/រោគ :-**
  - ⇒ មេរោគក្លាមីដា, លេបចំណុះ 500 មីលីក្រាម 4 ដងក្នុងមួយថ្ងៃ សំរាប់ 7 ថ្ងៃ ។
  - ⇒ រោគស្វាយ, លេបចំណុះ 500 មីលីក្រាម 4 ដងក្នុងមួយថ្ងៃ សំរាប់ 14 ថ្ងៃ ។
  - ⇒ រលាកអាងត្រគាក, លេបចំណុះ 500 មីលីក្រាម 4 ដងក្នុងមួយថ្ងៃ ទាល់តែរោគនេះជាដាច់បានប្រមាណ 2 ថ្ងៃ ។ ( ចំពោះការប្រើថ្នាំផ្សំលាយគ្នាសំរាប់រោគរលាកអាងត្រគាក ឬ ធ្លាក់សពីរន្ធយោនី, ចូរអានទំព័រ 162) ។
  - ⇒ រោគស្បែក, លេបចំណុះ 250 មីលីក្រាម 4 ដងក្នុងមួយថ្ងៃ សំរាប់ 14 ថ្ងៃ ។
  - ⇒ ចំពោះការថែទាំភ្នែកទារកទើបនឹងកើត, ដាក់ថ្នាំប៉ូម៉ាតបន្តិចចូលក្នុងភ្នែកម្ខាងៗ តែម្តងគត់ ក្រោយពីទារកកើតភ្លាមក្នុងថ្ងៃដំបូង ។
- **ថ្នាំឯទៀតដែលអាចប្រើការបានសំរាប់ជំងឺ/រោគ :-**
  - ⇒ មេរោគក្លាមីដា, ប្រើថ្នាំ **អាហ្ស៊ីត្រូម៉ីស៊ីន** (azythromycin), **ដុកស៊ីស៊ីគ្លីន** (doxycycline), **អេរីត្រូម៉ីស៊ីន** (erythromycin) ។
  - ⇒ រោគស្វាយ, ប្រើថ្នាំ **បេនហ្សាទីន ប៉េនីស៊ីលីន** (benzathine penicillin), **ដុកស៊ីស៊ីគ្លីន, អេរីត្រូម៉ីស៊ីន** ។
  - ⇒ រលាកអាងត្រគាក, ចូរអានទំព័រ 162 ។
  - ⇒ រោគស្បែក, ប្រើថ្នាំ **សេហ្វាលិចស៊ីន** (cephalexin), **ឌីក្លូស៊ីស៊ីលីន** (dicloxicillin), **ដុកស៊ីស៊ីគ្លីន** , **ប៉េនីស៊ីលីន** (penicillin), **អេរីត្រូម៉ីស៊ីន** ។
  - ⇒ ការថែទាំភ្នែកទារក, ប្រើថ្នាំប៉ូម៉ាត **អេរីត្រូម៉ីស៊ីន** (erythromycin ointment) ។



**បំរាម :-** ហាមលេបថ្នាំ **តេត្រាស៊ីគ្លីន** អំឡុងពេលមួយម៉ោងនៃការហូបចំណីអាហារដែលផលិតពីជាតិទឹកដោះគោ ឬ ថ្នាំក្រពះ **អានតាស៊ីត** (antacids) ។ ហាមប្រើថ្នាំ **តេត្រាស៊ីគ្លីន** ដែលស្ថិតក្រោមកំដៅថ្ងៃយូរ ឬ ហួសថ្ងៃកំណត់ ។ ស្ត្រីមានផ្ទៃពោះ ឬ ស្ត្រីបំបៅដោះកូន ហាមប្រើថ្នាំ **តេត្រាស៊ីគ្លីន** ។

ថ្នាំ **ទ្រីក្លរ៉ូសេទិច អាស៊ីត ( ធី-ស៊ី-អេ ), ប៊ីក្លរ៉ូសេទិច អាស៊ីត ( ប៊ី-ស៊ី-អេ )**
**Trichloroacetic acid (TCA), bichloroacetic acid (BCA)**

- ថ្នាំ **ទ្រីក្លរ៉ូសេទិច អាស៊ីត** ឬ **ប៊ីក្លរ៉ូសេទិច អាស៊ីត** មួយណាក៏បាន អាចប្រើព្យាបាលឫសដុះលើប្រដាប់ភេទ ( រោគសេមាន់ ) ។
- **សំខាន់ :-** ដំបូងយកក្រមួនប្រេងកាត**វ៉ាស៊ីលីន** (vaseline) លាបលើស្បែកគ្មានជំងឺជុំវិញឫសនោះ ។ បន្ទាប់មកលាប **ទ្រីក្លរ៉ូសេទិច អាស៊ីត** ឱ្យចំលើឫសនោះ ។ វានឹងមានអាការៈឈឺផ្សារប្រមាណពី 15 ទៅ 30 នាទី ។ បើ **ទ្រីក្លរ៉ូសេទិច អាស៊ីត** ហៀរទៅលើស្បែកល្អ ចូរលាងវាចេញជាមួយទឹកនិងសាប៊ូ ។ អ្នកអាចរោយម្សៅកូនង៉ែត ឬ ម្សៅ**បេកឃីង-សូដា** (baking soda) លើស្បែកដែលប្រឡាក់ជាតិ **ទ្រីក្លរ៉ូសេទិច អាស៊ីត** ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ :- ទ្រីក្លរ៉ូសេទិច អាស៊ីត** នឹងធ្វើឱ្យស្បែកល្អឈឺផ្សារ ឬ ខូចស្បែក បើវាហៀរទៅលើស្បែកល្អ ។
- **ថ្នាំនេះតែងផលិតជា :-** ថ្នាំទឹកមានថាមពលចំណុះរវាង 10 % និង 35 % ។



- **វិធីប្រើថ្នាំសំរាប់ព្យាបាលជំងឺ/រោគ :-**

⇒ លាបឱ្យចំលើឫសតែប៉ុណ្ណោះ, 1 អាទិត្យលាបម្តង, ប្រើពី 1 ទៅ 3 អាទិត្យតាមត្រូវការ ។

- **ថ្នាំឯទៀតដែលអាចប្រើការបានសំរាប់ជំងឺ/រោគ :-** ថ្នាំ **ប៉ូដូហ្វីលីន (**podophyllin) អាចប្រើជំនួសបាន បើគ្មានថ្នាំ **ទ្រីក្លរ៉ូសេទិច អាស៊ីត** ឬ **ប៊ីក្លរ៉ូសេទិច អាស៊ីត** ។



**បំរាម :-** ចូរប្រើវាឱ្យប្រយ័ត្នប្រយែងបំផុត ។ វាអាចធ្វើស្នោកស្បែកដែលនាំឱ្យសំលាកស្បែក ។

# ថ្នាំលេបសំរាប់ពន្យារកំណើត (ថ្នាំគ្រាប់លេបការពារមិនឱ្យមានកូន)



**ការទាក់ទងរវាងឥទ្ធិពលថ្នាំលេបសំរាប់ពន្យារកំណើតជាមួយថ្នាំពេទ្យផ្សេងៗ :-** ថ្នាំពេទ្យខ្លះបានផ្សំចូលគ្នាស្រាប់ ដើម្បីផលិតជាថ្នាំមួយគ្រាប់ៗ ដែលវាក្លាយទៅជាថ្នាំលេបសំរាប់ការពារកុំឱ្យមានកូន (ថ្នាំផ្ទុកជាតិអ័រម៉ូនពីរយ៉ាងគឺ **អេស្ត្រូជែន** និង **ប្រូជេស្ទីន**) គឺធ្វើការមិនល្អ ឬ គ្មានប្រសិទ្ធភាពទាល់តែសោះ ។ ចូរកុំប្រើថ្នាំលេបសំរាប់ពន្យារកំណើតដែលបានផលិតផ្សំចូលគ្នា បើអ្នកប្រើថ្នាំណាមួយក្នុងចំណោមថ្នាំ 4 យ៉ាងខាងក្រោមនេះទៀងទាត់ :-

- ថ្នាំ **ការបាម៉ាហ្សេពីន (តេហ្គ្រេតុល)**
  Carbamazepine (Tegretol)
- ថ្នាំ **ហ្វេណូបារប៊ីតាល់ (ហ្វេណូបារប៊ីតុន, លូមីណាល់)**
  Phenobarbital (phenobarbitone, Luminal)
- ថ្នាំ **ហ្វេនីតូអ៊ីន (ឌីហ្វេនីលហ៊ីដង់តូអ៊ីន, ឌីឡានទីន)**
  Phenytoin (diphenylhydantoin, Dilantin)
- ថ្នាំ **វ៉ាល់ប្រូអ៊ិក អាស៊ីត (ដេប៉ាគីណេ)**
  Valproic acid *(Depakene)*

ចូរអានទំព័រ 196 ចំពោះព័ត៌មានអំពីថ្នាំលេបសំរាប់ពន្យារកំណើត (និងវិធីសាស្ត្រអ័រម៉ូនផ្សេងៗដើម្បីកុំឱ្យមានកូននៃផែនការគ្រួសារ) ដែលអាចប៉ះពាល់ដល់ពិការភាពរបស់អ្នក ។ ថ្នាំគ្រាប់សំរាប់ពន្យារកំណើតបានផលិតទៅតាមថាមពលចំណុះខុសៗពីគ្នានៃអ័រម៉ូននីមួយៗ និងត្រូវបានលក់ដូរក្រោមម៉ាកថ្នាំ (ឈ្មោះថ្នាំ) ជាច្រើនផ្សេងៗពីគ្នា ។ យើងបានកត់ត្រាម៉ាកថ្នាំតែពីរ-បីយ៉ាងប៉ុណ្ណោះនៅក្នុងតារាងខាងក្រោម ។

តាមធម្មតា ម៉ាកថ្នាំដែលផ្ទុកអ័រម៉ូនទាំងពីរប្រភេទចំនួនតិច គឺជាថ្នាំមានសុវត្ថិភាពបំផុត ហើយធ្វើការយ៉ាងល្អបំផុតសំរាប់ស្ត្រីស្ទើរតែគ្រប់គ្នា ។ ថ្នាំគ្រាប់ "កំរិតទាប ឬ ថាមពលទាប / low-dose" ទាំងនេះ អាចរកឃើញក្នុងក្រុមទី 1, ក្រុមទី 2, និងក្រុមទី 3 ។

**ក្រុមទី 1 - ថ្នាំ ទ្រីហ្វាស៊ិក** (Triphasic pills)

ថ្នាំទាំងនេះផ្ទុកអ័រម៉ូន**អេស្ត្រូជែន** (estrogen) និង **ប្រូជេស្ទីន** (progestin) ចំនួនតិចបានផ្សំចូលគ្នាស្រាប់ វាប្រែប្រួលពេញក្នុងរវាងមួយខែៗ ។ វាជាការសំខាន់ គឺត្រូវលេបថ្នាំទៅតាមលំដាប់លំដោយ ពីព្រោះចំណុះថ្នាំតែងតែប្រែប្រួលក្នុងគ្រាប់ថ្នាំនីមួយៗ ។

**<u>យីហោថ្នាំ (ម៉ាកថ្នាំ) :</u>** **ឡូហ្គីនុន** *(*Logynon) **ស៊ីណូហ្វេស** (Synophase) **ទ្រីស៊ីគ្លិន** (Tricyclen) **ទ្រីន័រឌីអុល** (Trinordiol) **ទ្រីណូវូម** *(Trinovum)* **ទ្រីគីឡារ** *(Triquilar)* **ទ្រីហ្វេស៊ីល** *(Triphasil)*

**ក្រុមទី 2 - ថ្នាំគ្រាប់កំរិតទាប ឬ ថាមពលទាប** (Low dose pills)

ថ្នាំទាំងនេះផ្ទុកអ័រម៉ូន**អេស្ត្រូជែន**ចំនួនតិច (35 មីក្រូក្រាមនៃ**អេស្ត្រូជែន "អេទីនីល អេស្ត្រាឌីអុល** / ethinyl estradiol" ឬ 50 មីក្រូក្រាមនៃ**អេស្ត្រូជែន "មេស្ត្រាណុល** / mestranol") និង **ប្រូជេស្ទីន** នៅក្នុងករណីផ្សំចូលគ្នាមួយដែលរក្សាថាមពលរបស់វាស្មើគ្នាពេញរវាងមួយខែៗ ។

**<u>យីហោថ្នាំ (ម៉ាកថ្នាំ) :</u>**

**ប្រេវីកុន** /*Brevicon* 1 + 35 **ន័រីនីល** /*Norinyl* 1 + 35, 1 + 50 **អូវីសមិន** /*Ovysmen* 1/35 **ន័រីមីន** /*Norimin* **ន័រីដេយ៍** /*Noriday* 1 + 50 **អ័រតូ-ណូវូម** /*Ortho-Novum* 1/35, 1/50 **នេអូកុន** /*Neocon* **ប៉េរ៉ល** /*Perle*

**ក្រុមទី 3 - ថ្នាំគ្រាប់កំរិតទាប ឬ ថាមពលទាប** (Low dose pills)

ថ្នាំទាំងនេះផ្ទុកអ័រម៉ូន**ប្រូជេស្ទីន** ចំនួនច្រើន និងផ្ទុកអ័រម៉ូន**អេស្ត្រូជែន** ចំនួនតិច (30 ឬ 35 មីក្រូក្រាមនៃ**អេស្ត្រូជែន "អេទីនីល អេស្ត្រាឌីអុល** / ethinyl estradiol") ។

**<u>យីហោថ្នាំ (ម៉ាកថ្នាំ) :</u>** **ឡូ-អូវ៉ាល់** / Lo-Ovral **មីក្រូវ៉ឡារ** / Microvlar **ឡូ-ហ្វេមីណាល់** / Lo-Femenal **មីក្រូហ្គីនុន** / Microgynon 30 **ន័រដេតតេ** / Nordette

ដើម្បីធ្វើឱ្យប្រាកដថាថ្នាំលេបសំរាប់ពន្យារកំណើតមានប្រសិទ្ធភាព និងកាត់បន្ថយបញ្ហាធ្លាក់ឈាមខុសពីធម្មតា (ចំនួនឈាមធ្លាក់តិចតួចខុសពីពេលដែលអ្នកធ្លាក់ឈាមរដូវប្រចាំខែ) ចូរលេបថ្នាំឱ្យទៀងទាត់ពេលវេលារៀងរាល់ថ្ងៃ ជាពិសេសថ្នាំផ្ទុកចំនួនអ័រម៉ូនតិច ។ បើអ្នកនៅតែមានធ្លាក់ឈាមខុសធម្មតាក្រោយពីបានលេបថ្នាំសំរាប់ពន្យារកំណើត 3 ឬ 4 ខែ ចូរសាកល្បងលេបម៉ាកថ្នាំដែលបានបង្ហាញនៅក្រុមទី 3 ។ បើឈាមនៅតែធ្លាក់ខុសធម្មតា 3 ខែក្រោយមកទៀត ចូរសាក្បលងប្រើម៉ាកថ្នាំនៅក្រុមទី 4 ដែលបានបង្ហាញដូចខាងក្រោមនេះ ។

ប៉ុន្តែបើស្ត្រីបានបាត់ឈាមរដូវរាប់ខែ ឬ ត្រូវបានរំខានដោយការធ្លាក់ឈាមរដូវតិចតួច គាត់អាចប្តូរម៉ាកថ្នាំផ្ទុកចំនួន**អេស្ត្រូជែន**ច្រើនដែលថ្នាំនេះបានបង្ហាញនៅក្រុមទី 4 ។

ចំពោះស្ត្រីដែលធ្លាក់ឈាមរដូវច្រើនខ្លាំង ឬ ដោះរបស់គាត់ឈឺចាប់ខ្លាំងមុនពេលឈាមរដូវធ្លាក់ ជាការល្អគាត់អាចប្រើម៉ាកថ្នាំផ្ទុកចំនួន**អេស្ត្រូជែន**តិច ប៉ុន្តែផ្ទុកចំនួន**ប្រូជេស្ទីន**ច្រើន ។ ថ្នាំទាំងនេះគឺស្ថិតនៅក្នុងក្រុមទី 3 ។

ស្ត្រីដែលបន្តធ្លាក់ឈាមខុសធម្មតា ឬ បានបាត់ឈាមរដូវនៅពេលលេបម៉ាកថ្នាំពីក្រុមទី 3 ឬ បានមានផ្ទៃពោះនៅអំឡុងពេលគាត់កំពុងប្រើពន្យារកំណើតប្រភេទផ្សេងទៀត គាត់អាចប្តូរមកប្រើថ្នាំពន្យារកំណើតផ្ទុកចំនួន**អេស្ត្រូជែន**ច្រើនជាងមុនបន្តិច ។ ថ្នាំផ្ទុក "កំរិតខ្ពស់ ឬ ថាមពលខ្លាំង / high dose" គឺអាចរកឃើញនៅក្នុងក្រុមទី 4 ។

**ក្រុមទី 4 – ថ្នាំគ្រាប់កំរិតខ្ពស់ ឬ ថាមពលខ្លាំង (High dose pills)**

ថ្នាំ**ផ្ទុកអេស្ត្រូជែន**ចំនួនច្រើន (50 មីក្រូក្រាមនៃ**អេស្ត្រូជែន "អេទីនីល អេស្ត្រាឌីអុល** / ethinyl estradiol") ហើយថ្នាំនេះស្ទើរតែទាំងអស់ក៏មានផ្ទុកចំនួន**ប្រូជេស្ទីន** ច្រើនផងដែរ ។

**យីហោថ្នាំ (ម៉ាកថ្នាំ) :-**

| | | | |
|---|---|---|---|
| | **យូហ្គីនុន** / Eugynon | **នេអូហ្គីនុន** / Neogynon | **អូវរ៉ាល់** / Ovral |
| | **ហ្វេមេណាល់** / Femenal | **ន័រឌីអុល** / Nordiol | **ព្រីមូវឡារ** / Primovlar |

ស្ត្រីដែលបំបៅដោះកូន ឬ ស្ត្រីដែលមិនគួរប្រើថ្នាំពន្យារកំណើតធម្មតា ដោយសារមានជំងឺឈឺក្បាល ឬ មានសំពាធឈាមលើសតិចតួចប្រហែលជាត្រូវប្រើថ្នាំពន្យារកំណើតផ្ទុក**ប្រូជេស្ទីន**តែប៉ុណ្ណោះ ។ ថ្នាំទាំងនេះអាចរកឃើញនៅក្រុមទី 5 គឺហៅថាថ្នាំខ្នាតតូច "mini-pills" ។

**ក្រុមទី 5 – ថ្នាំផ្ទុកប្រូជេស្ទីនមួយមុខគត់ (Progestin-only pills)**

ថ្នាំទាំងនេះក៏បានស្គាល់ថាជាថ្នាំខ្នាតតូច ឬ "ថ្នាំមីនី / mini-pills" ដែលផ្ទុក**ប្រូជេស្ទីន** / progestin តែប៉ុណ្ណោះ ។

**យីហោថ្នាំ (ម៉ាកថ្នាំ) :-**

**ហ្វេមូលិន** / Femulen

**មីក្រូន័រ** / Micronor

**មីក្រូណូវូម** / Micronovum

**ន័រ-ខ្យូឌី** /Nor-Q D

| | |
|---|---|
| **មីក្រូលូត** / Microlut | **នេអូជេស្តុន** / Neogeston |
| **មីក្រូវ៉ាល់** / Microval | **អូវរ៉េតតេ** /Ovrette |
| **នេអូជេស្ត** / Neogest | |

← **ម៉ាកថ្នាំទាំងនេះអាចត្រូវបានប្រើសំរាប់ផែនការគ្រួសារសង្គ្រោះបន្ទាន់ (កុំឱ្យមានកូនជាបន្ទាន់) ផងដែរ ចូរអានទំព័របន្ទាប់នេះ ។**

ថ្នាំផ្ទុក**ប្រូជេស្ទីន**មួយមុខគត់ គួរត្រូវលេបឱ្យទៀងទាត់ម៉ោងរៀងរាល់ថ្ងៃ ទោះបីជាពេលកំពុងធ្លាក់ឈាមរដូវផងដែរ ។ ជាញឹកញាប់ឈាមរដូវតែងធ្លាក់មិនទៀងទាត់ ។

## ផែនការគ្រួសារសង្គ្រោះបន្ទាន់ (ការការពារកុំឱ្យមានកូនជាបន្ទាន់)




វារឿងសមស្របដែលអ្នកត្រូវលេបថ្នាំការពារកុំឱ្យមានកូនជាបន្ទាន់ ទោះបីអ្នកមិនធ្លាប់ប្រើវាតាមធម្មតាសំរាប់ផែនការគ្រួសារក៏ដោយ (អានទំព័រ 355) ។ ថ្នាំនេះមិនប្រតិកម្មប្រឆាំងនឹងថ្នាំសំរាប់ភាពពិការរបស់អ្នកឡើយ ពីព្រោះអ្នកប្រើវាក្នុងរយៈពេលយ៉ាងខ្លី ។

អ្នកអាចប្រើថ្នាំការពារកុំឱ្យមានកូនជាបន្ទាន់ ឬ ថ្នាំពន្យារកំណើតធម្មតាដើម្បីការពារកុំឱ្យមានផ្ទៃពោះក្នុងរវាង 5 ថ្ងៃក្រោយពីរួមរ័ក្សមិនបានការការពារ ។ ចំនួនគ្រាប់ថ្នាំដែលអ្នកត្រូវការ គឺត្រូវពឹងពាក់ទាំងស្រុងលើចំណុះនៃ**អេស្ត្រូជែន** ឬ **ប្រូជេស្ទីន** ដែលផ្ទុកក្នុងគ្រាប់ថ្នាំនីមួយៗ ។ តារាងនេះបានកត់ត្រាថ្នាំតែពីរ-បីម៉ាកប៉ុណ្ណោះនៃប្រភេទថ្នាំនីមួយៗដែលនិយមប្រើទូទៅ ។ ចូរពិនិត្យមើលចំណុះនៃ**អ័រម៉ូន**ផ្ទុកក្នុងគ្រាប់ថ្នាំ មុនពេលអ្នកប្រើវានៅក្នុងពេលការពារកុំឱ្យមានកូនជាបន្ទាន់ ដោយសារម៉ាកថ្នាំខ្លះត្រូវបានប្រើសំរាប់ថ្នាំច្រើនជាងមួយប្រភេទ ។

### វិធីលេបថ្នាំដើម្បីការពារកុំឱ្យមានកូនជាបន្ទាន់នៃផែនការគ្រួសារសង្គ្រោះបន្ទាន់

| ថ្នាំគ្រាប់សំរាប់ផែនការគ្រួសារសង្គ្រោះបន្ទាន់ (ការពារកុំឱ្យមានកូនបានយ៉ាងទាន់ចិត្ត) | លេបលើកទី 1  | លេបលើកទី 2  (12ម៉ោងក្រោយមក) |
|---|---|---|
| ថ្នាំគ្រាប់កំរិតខ្ពស់ ផ្ទុកជាតិ**អេទីនីល អេស្ត្រាឌីអុល** (**អូវរ៉ាល់, អូជេស្ត្រែល**) ចំណុះ 50 មីក្រូក្រាម [High-dose pills containing 50 mcg ethinyl estradiol (Ovral, Ogestrel)] | លេប 2 គ្រាប់ | លេប 2 គ្រាប់ទៀត |
| ថ្នាំគ្រាប់កំរិតទាប ផ្ទុកជាតិ**អេទីនីល អេស្ត្រាឌីអុល** (**ឡូ-ហ្វេមេណាល់, ឡូ/អូវរ៉ាល់, មីក្រូហ្គីនុន, ន័រដេតតេ**) ចំណុះ 30 ឬ 35 មីក្រូក្រាម [Low-dose pills containing 30 or 35 mcg ethinyl estradiol (Lo-Femenal, Lo/Ovral, Microgynon, Nordette)] | លេប 4 គ្រាប់ | លេប 4 គ្រាប់ទៀត |
| ថ្នាំគ្រាប់កំរិតទាបផ្ទុកជាតិ**អេទីនីល អេស្ត្រាឌីអុល** (**អាលេសសេ, លេសស៊ីណា, ឡូតេរ៉ា**) ចំណុះ 20 មីក្រូក្រាម [Low-dose pills containing 20 mcg ethinyl estradiol (Alesse, Lessina, Lutera)] | លេប 5 គ្រាប់ | លេប 5 គ្រាប់ទៀត |
| ថ្នាំពិសេសការពារកុំឱ្យមានកូនជាបន្ទាន់ ផ្ទុកជាតិ**អេទីនីល អេស្ត្រាឌីអុល** និង **លេវ៉ូន័រជេស្ត្រែល** (**តេត្រាហ្គីនុន**) Special emergency pills containing ethinyl estradiol and levonorgestrel Tetragynon)] | លេប 2 គ្រាប់ | លេប 2 គ្រាប់ទៀត |
| ថ្នាំផ្ទុក**ប្រូជេស្ទីន**មួយមុខគត់ (ថ្នាំខ្នាតតូច/ថ្នាំមីនី) ផ្ទុកជាតិ**ឡេវ៉ូន័រជេស្ត្រែល** (**អូវរ៉េតតេ, នេអូជេស្ត**) ចំណុះ 75 មីក្រូក្រាម [Progestin-only pills (mini-pills) containing 75 mcg levonorgestrel (Ovrette, Neogest)] | លេប **40**គ្រាប់ តែម្តងគត់, **ឬ** លេបលើកទីមួយ ចំនួន **20**គ្រាប់ និង 12 ម៉ោងក្រោយមក លេប **20**គ្រាប់ទៀត  | |
| ថ្នាំផ្ទុក**ប្រូជេស្ទីន**មួយមុខគត់ (ថ្នាំខ្នាតតូច/ថ្នាំមីនី) ផ្ទុកជាតិ **ឡេវ៉ូន័រជេស្ត្រែល** (**មីក្រូលូត, មីក្រូវ៉ាល់, ន័រជេស្តុន**) ចំណុះ 30 មីក្រូក្រាម [Progestin-only pills (mini-pills) containing 30 mcg levonorgestrel (Microlut, Microval, Norgeston)] | លេប **50**គ្រាប់តែម្តងគត់, **ឬ** លេបលើកទីមួយ ចំនួន **25**គ្រាប់ និង 12 ម៉ោងក្រោយមក លេប **25** គ្រាប់ទៀត  | |
| ថ្នាំពិសេសការពារកុំឱ្យមានកូនជាបន្ទាន់ ផ្ទុកជាតិ**ឡេវ៉ូន័រជេស្ត្រែល** (**ប៉ុស្ទីន័រ 1**) ចំណុះ 1500 មីក្រូក្រាម [Special emergency pills containing 1500 mcg levonorgestrel (Postinor 1)] | លេប**មួយ**គ្រាប់, តែម្តងគត់ | |
| ថ្នាំពិសេសការពារកុំឱ្យមានកូនជាបន្ទាន់ ផ្ទុកជាតិ **ឡេវ៉ូន័រជេស្ត្រែល** (**ប៉ុស្ទីន័រ, ប៉ុស្ទីន័រ-2, ភ្លាន-បេ, ថ្នាំគ្រាប់ 72, ប៉ុស្ត-ដេយ៍**) ចំណុះ 750 មីក្រូក្រាម [Special emergency pills containing 750 mcg levonorgestrel (Postinor, Postinor-2, Plan B, Pill 72, Post-Day)] | លេប**ពីរ**គ្រាប់, តែម្តងគត់ | |

**នៅក្នុងថ្នាំមួយបន្ទះមានផ្ទុកថ្នាំចំនួន 28 គ្រាប់ ចូរប្រើថ្នាំគ្រាប់ណាមួយក៏បាននៅក្នុងចំណោមថ្នាំ 21 គ្រាប់ដំបូង**សំរាប់ការការពារកុំឱ្យមានកូនជាបន្ទាន់ ។ **ហាមប្រើ**ថ្នាំចំនួន **7 គ្រាប់ចុងក្រោយ** ពីព្រោះគ្រាប់ថ្នាំទាំងនេះគ្មានផ្ទុកអ័រម៉ូនសោះឡើយ ។ ថ្នាំផ្ទុកអ័រម៉ូន**ប្រូជេស្ទីន**តែមួយមុខគត់ និងថ្នាំពិសេសការពារកុំឱ្យមានកូនជាបន្ទាន់មានឥទ្ធិពលធ្វើទុក្ខតិចតួច (ឈឺក្បាលនិងចង្អោរ) ជាងថ្នាំផ្សំអ័រម៉ូនច្រើនប្រភេទចូលគ្នាសំរាប់ផែនការគ្រួសារសង្គ្រោះបន្ទាន់ ។

## ថ្នាំសំរាប់ជំងឺអេដស៍_វិធីព្យាបាលតាមរយៈថ្នាំអង់ទីរ៉េត្រូវីរ៉ាល់ (អាត)

**[Medicines for Aids-antiretroviral therapy (ART)]**

ថ្នាំសំរាប់ជួយទ្រទ្រង់សុខភាពអ្នកកើតអេដស៍ គឺហៅថា ថ្នាំ**អង់ទីរ៉េត្រូវីរ៉ាល់ (អេ-អរ-វី)**[antiretroviral medicines (ARVs)] ។ ថ្នាំទាំងនេះអាចជួយអ្នកកើតអេដស៍ឱ្យរស់នៅបានយូរ និងទ្រទ្រង់សុខភាពបានមាំមួនជាងពីមុន ។ របៀបប្រើវាគឺត្រូវលេបលាយចំរុះគ្នាជាមួយថ្នាំ 3 មុខយ៉ាងតិច វាត្រូវបានហៅថា **វិធីព្យាបាលតាមរយៈថ្នាំអង់ទីរ៉េត្រូវីរ៉ាល់** ឬ **អាត** [AntiRetroviral Therapy, or ART] ។ នៅក្នុងផ្នែកនេះ អ្នកនឹងរកឃើញព័ត៌មានអំពីថ្នាំនិយមប្រើមួយចំនួន ដែលត្រូវប្រើផ្សំចូលគ្នាស្រាប់សំរាប់ថ្នាំ**អាត (គឺជាតិថ្នាំពីរ ឬ បីមុខបានផលិតផ្សំចូលគ្នាស្រាប់ជាគ្រាប់ថ្នាំតែមួយ)** ។ ចូរអាននៅតារាងសំរាប់ថ្នាំនីមួយៗ (ពីទំព័រ 361 ដល់ 362) ដើម្បីស្វែងយល់ឱ្យជ្រៅជ្រះរវាងឥទ្ធិពលថ្នាំសំរាប់អេដស៍ និងឥទ្ធិពលថ្នាំធម្មតាសំរាប់ពិការភាពរបស់អ្នក ក្រែងលោថ្នាំទាំងនេះទាក់ទិនប្រឆាំងគ្នា ។

## ការគាំពារវីរុសហ៊ីវនិងកម្មវិធីអាត

វីរុសហ៊ីវ/អេដស៍ ជាជំងឺមួយស្មុគស្មាញដែលប៉ះពាល់គ្រប់កន្លែងនៃរាងកាយរបស់អ្នក ។ កាលណាអ្នកបានធ្វើតេស្តដឹងភ្លាមថាក្នុងខ្លួនរបស់អ្នកមានផ្ទុកវីរុសហ៊ីវ ចូរស្វែងរកកម្មវិធីគាំពារវីរុសហ៊ីវ កន្លែងដែលបុគ្គលិកសុខាភិបាលមានជំនាញអាចជួបអ្នកទៀងទាត់ និងជួយណែនាំអ្នកឱ្យចេះថែរក្សាសុខភាពបានមាំមួន ។ កម្មវិធីគាំពារវីរុសហ៊ីវអាចផ្តល់ថ្នាំពេទ្យដើម្បីជួយទប់ស្កាត់ និងព្យាបាលជំងឺទាំងឡាយដែលបង្កពីវីរុសហ៊ីវ, ការពិគ្រោះបញ្ហានិងការគាំទ្រផ្សេងៗទៀត ។ ពួកគេអាចជួយអ្នកឱ្យចាប់ផ្តើមប្រើថ្នាំ**អាត** ដែលជួយព្យាបាលអាការៈជំងឺធ្វើទុក្ខ និងផ្លាស់ប្តូរថ្នាំ**អាត**របស់អ្នក បើអ្នកប្រើវាទៅគ្មានប្រសិទ្ធភាព ។ ការទទួលបានថ្នាំពីកម្មវិធី**អាត** គឺអាចទុកចិត្តបាននិងមានតំលៃថោកជាងទិញវាពីប្រភពឯកជន ។

## តើពេលណាត្រូវការប្រើថ្នាំអាត?

មនុស្សដែលបានផ្ទុកវីរុសហ៊ីវ ហើយប្រព័ន្ធការពារជំងឺក្នុងខ្លួននៅខ្លាំងក្លា គាត់មិនត្រូវការប្រើថ្នាំ**អាត**ឡើយ ។ បុគ្គលទាំងឡាយណាដែលបានធ្វើតេស្ត ហើយទទួលលទ្ធផលវេជ្ជមានថាមានផ្ទុកវីរុសហ៊ីវ និងបង្ហាញរោគសញ្ញានៃជំងឺអេដស៍ ឬ ក៏ប្រព័ន្ធការពារជំងឺក្នុងខ្លួនលែងធ្វើការល្អ បុគ្គលនោះត្រូវការប្រើថ្នាំ**អាត** ។ ការធ្វើតេស្តមួយដែលហៅថា ការរាប់**ស៊ីឌី4** (CD4 count) អាចបង្ហាញថាប្រព័ន្ធការពារជំងឺក្នុងខ្លួននៅធ្វើការបានល្អកំរិតណា ។ បើនៅតំបន់ដែលអ្នករស់នៅមានបំរើសេវាធ្វើតេស្តរាប់**ស៊ីឌី4**នេះ និងបើអ្នកបានធ្វើតេស្តនេះហើយ ហើយ**ស៊ីឌី4**របស់អ្នកបានរាប់ទៅបង្ហាញចំនួនក្រោម 200 អ្នកនិងបុគ្គលិកសុខាភិបាលអាចសំរេចចិត្តថា ពេលណាអ្នកគួរតែចាប់ផ្តើមប្រើថ្នាំ**អាត** ។

## មុនពេលចាប់ផ្តើមប្រើថ្នាំអាត ជាការសំខាន់អ្នកត្រូវការពិភាក្សាជាមួយបុគ្គលិកសុខាភិបាលរបស់អ្នក

- ពីមុន តើអ្នកធ្លាប់បានផឹកថ្នាំ **អេ-អរ-វី** ណាមួយដែរឬទេ? វាអាចជះឥទ្ធិពលប៉ះពាល់នឹងថ្នាំដែលអ្នកត្រូវលេបនាពេលនេះ ។
- តើអ្នកមានជំងឺណាមួយ ឬ ស្ថានភាពផ្សេងៗដូចជា ជំងឺរបេង, ដំបៅធ្ងន់ធ្ងរ ឬ គ្រុនក្តៅដែរឬទេ? ជំងឺទាំងនេះអាចត្រូវការការព្យាបាលមុនគេបង្អស់ ។
- តើមានអ្វីខ្លះដែលជាផលប្រយោជន៍, ករណីដែលអាចជាគ្រោះថ្នាក់, និងឥទ្ធិពលធ្វើទុក្ខនៃថ្នាំ**អាត**? ចូរព្យាយាមជួបនិយាយជាមួយបុគ្គលណាដែលកំពុងប្រើថ្នាំ**អាត** ក៏ដូចជាការជួបពិភាក្សាជាមួយបុគ្គលិកសុខាភិបាលរបស់អ្នក ។
- តើអ្នកត្រៀមខ្លួនស្រេចបាច់ហើយឬនៅ ដើម្បីលេបថ្នាំរៀងរាល់ថ្ងៃ, ឱ្យចំម៉ោងកំណត់ទៀងទាត់? ករណីនេះជាការចាំបាច់ណាស់សំរាប់ឱ្យថ្នាំ**អាត**ធ្វើការយ៉ាងមានប្រសិទ្ធភាព ។
- តើអ្នកមានការគាំទ្រពីបុគ្គលណាម្នាក់ដែលអ្នកទុកចិត្ត ឬ ពីក្រុមគាំទ្រនៃអ្នកផ្ទុកវីរុសហ៊ីវ/អេដស៍ ដែលអ្នកអាចទៅពឹងពាក់បានសំរាប់សុំព័ត៌មាន និងការជួយដែរឬទេ?

អ្នកត្រូវស្វែងរកឱ្យស្គាល់ច្បាស់ពិតប្រាកដចំពោះកន្លែងដែលអ្នកត្រូវការការជួយ បើអ្នកមានបញ្ហាក្នុងការទទួលបានថ្នាំ**អាត**, មានបញ្ហាឥទ្ធិពលថ្នាំធ្វើទុក្ខ ឬ ត្រូវការការព្យាបាលសំរាប់បញ្ហាសុខភាពឯទៀត ។

**កុំចាប់ផ្តើម**ប្រើថ្នាំ**អាត**ដោយខ្លួនឯង ។ វាអាចខុសនឹងអាការៈជំងឺរបស់អ្នក ហើយឥទ្ធិពលថ្នាំអាចធ្វើទុក្ខយ៉ាងខ្លាំង ។

**កុំចែក**ថ្នាំ**អេ-អរ-វី** របស់អ្នកជាមួយនរណាម្នាក់ឱ្យសោះ រួមទាំងដៃគូ/ប្តី ឬ កូនក្មេង ។ ការប្រើថ្នាំតិចជាងកំណត់ដូសដែលវេជ្ជបញ្ជាផ្តល់ឱ្យអាចបណ្តាលឱ្យថ្នាំឈប់ធ្វើការ, ហើយវាបង្កទុក្ខទោសដល់អ្នក និងបុគ្គលដែលអ្នកចែកថ្នាំប្រើ ។

**កុំទិញ**ថ្នាំ**អេ-អរ-វី** ពីមនុស្សណាដែលមិនមែនជាផ្នែកនៃការអនុញ្ញាតពីកម្មវិធីគាំពារវីរុសហ៊ីវ ឬ កម្មវិធី**អាត** ។

## ថ្នាំ អេ-អរ-វី ដែលផ្សំចូលគ្នាស្រាប់ (របបថ្នាំអាត)

ថ្នាំ**អេ-អរ-វី** គឺមានប្រសិទ្ធភាពកាលបើប្រើវាដោយការផ្សំចូលគ្នាតែប៉ុណ្ណោះ (ប្រើវាតាមរបបកំណត់ឱ្យ) យ៉ាងតិចណាស់ក៏មានថ្នាំ 3 មុខរួមគ្នាដែរ ។ យើងនឹងបង្ហាញក្នុងតារាងអំពីថ្នាំដែលបានផ្សំចូលគ្នា 4 យ៉ាងដែលនិយមប្រើនៅទំព័រ 360 ហើយបន្ទាប់មកមានផ្តល់ព័ត៌មានអំពីថ្នាំនីមួយៗ ។ កាលណាអ្នកយល់ដឹងបានច្រើនអំពីវីរុសហ៊ីវ និងវិធីពន្យារ ឬ បញ្ឈប់វា, របបថ្នាំនឹងផ្លាស់ប្តូរទៅតាមនោះដែរ ។ ចូរសាកសួរបុគ្គលិកសុខាភិបាលថាតើមានថ្នាំអ្វីខ្លះ ហើយថាតើថ្នាំទាំងនោះប្រើទៅមានប្រសិទ្ធភាពល្អឬទេ នៅតំបន់ដែលអ្នករស់នៅ ។

នៅក្នុងប្រអប់ខាងក្រោមមានរបបថ្នាំដែលបានផ្សំចូលគ្នា 4 យ៉ាង ដែលស្រួលលេបបំផុត ។ ថ្នាំទាំងនេះអាចលេបជាមួយម្ហូបអាហារ ឬ លេបដោយគ្មានម្ហូបអាហារក៏បាន ។ ថ្នាំទាំងនេះងាយរកបាន និងមានតំលៃថោកសមរម្យ ។ របបថ្នាំផ្សំចូលគ្នា (ទាំងអស់មានថ្នាំ 3 យ៉ាង ឬ ជួនកាលមានថ្នាំ 2 យ៉ាងនៃថ្នាំទាំង 3 នោះ) គឺបានផលិតឡើងដោយផ្សំចូលគ្នាស្រាប់ជាថ្នាំតែមួយគ្រាប់ ត្រូវបានហៅថា "ថ្នាំផ្សំចូលគ្នាតាមរបបកំណត់ឱ្យ (fixed dose combination)" ។

### របៀបលេបថ្នាំអាត

- ទោះបីជាអ្នកប្រើថ្នាំផ្សំចូលគ្នានេះបែបណាក៏ដោយ អ្នកត្រូវលេបថ្នាំទាំង 3 យ៉ាងនេះរៀងរាល់ថ្ងៃ, ឱ្យចំម៉ោងកំណត់រាល់ៗថ្ងៃ ។
- បើអ្នកត្រូវផឹកថ្នាំទាំងនេះ 2 ដងក្នុងមួយថ្ងៃ អ្នកត្រូវផឹកវានៅរវាង 12 ម៉ោងដាច់ពីគ្នា ។ ឧទាហរណ៍ បើអ្នកផឹកលើកទីមួយនៅម៉ោង 6 ព្រឹក នោះអ្នកត្រូវផឹកលើកទីពីរនៅម៉ោង 6 ល្ងាច តាមកំណត់នេះជាចាំបាច់ ។ បើអ្នករំយោលពេលឱ្យលើសពី 12 ម៉ោងនៃរវាងពេលដែលត្រូវផឹកថ្នាំទាំងពីរដង នោះអ្នកមានជាតិថ្នាំយ៉ាងតិចនៅក្នុងខ្លួន ហើយអាចបណ្តាលឱ្យថ្នាំប្រតិកម្មប្រឆាំងគ្នា ។
- បើអ្នកភ្លេចមិនបានផឹកថ្នាំតាមម៉ោងកំណត់ ចូរផឹកវានៅក្នុងរង្វង់ពេល 5 ម៉ោង ។ បើវាលើសពី 5 ម៉ោង ចូររង់ចាំឱ្យដល់ម៉ោងពេលនៃការផឹកថ្នាំលើកក្រោយតែម្តង ។
- ចូរកុំឈប់ផឹកថ្នាំណាមួយដែលជាផ្នែកនៃរបបថ្នាំ**អាត** ដោយមិនបានជួបសុំយោបល់ពីបុគ្គលិកសុខាភិបាល ដើម្បីឱ្យដឹងថាតើថ្នាំទាំងនេះគួរតែត្រូវឈប់ផឹកវាដាច់ដោយឡែកពីគ្នា ឬ ឈប់ព្រមគ្នាតែម្តង ។

## ឥទ្ធិពលធ្វើទុក្ខនៃថ្នាំ**អាត**

ថ្នាំ**អាត**បានជួយមនុស្សជាច្រើននាក់ឱ្យមានសុខភាពល្អ ហើយរស់នៅបានយូរជាងមុន ។ ប៉ុន្តែដូចថ្នាំជាច្រើនទៀតដែរ ថ្នាំ **អេ-អរ-វី** អាចបង្កឥទ្ធិពលធ្វើទុក្ខនៅពេលកំពុងប្រើវា ។ មនុស្សជាច្រើនរកឃើញថា នៅខណៈដែលរាងកាយរបស់ខ្លួនបានស៊ាំនឹងជាតិថ្នាំ ឥទ្ធិពលថ្នាំធ្វើទុក្ខនឹងថយចុះ ហើយវាអាចលែងធ្វើទុក្ខទាំងស្រុង ។ ឥទ្ធិពលដែលថ្នាំ**អាត**តែងធ្វើទុក្ខ គឺរាគអាចម៏, អស់កំលាំងខ្លាំង, ឈឺក្បាល, និងមានបញ្ហាក្រពះដូចជា ចង្អោរ, ក្អួត, ឈឺក្នុងពោះ ឬ មានអារម្មណ៏ថាមិនចង់ហូបចំណីអាហារ ។ ថ្វីបើអ្នកមានអារម្មណ៏មិនស្រួលខ្លួនយ៉ាងណាក៏ដោយ ចូរបន្តលេបថ្នាំតាមរបបកំណត់ ឱ្យទាល់តែបុគ្គលិកសុខាភិបាលប្រាប់អ្នកថា ត្រូវឈប់ ឬក៏ត្រូវដូរថ្នាំទាំងនោះ ។

ឥទ្ធិពលថ្នាំធ្វើទុក្ខចំនួនគឺផ្តល់ជាដំណឹងថា អ្នកត្រូវការដូរថ្នាំនោះចេញ ។ ឥទ្ធិពលថ្នាំធ្វើទុក្ខដែលធ្ងន់ធ្ងររួមមាន ឈឺឈឹប១ ឬ ដឹងថាក្តៅរាងក្រហាយ១នៅក្នុងបាតដៃនិងបាតជើង, គ្រុនក្តៅ, រោលកន្ទួលស្បែក, ភ្នែកលឿង, អស់កំលាំងខ្លាំងរួមជាមួយការដង្ហើមដកស្ទើរមិនដល់គ្នា, ជំងឺស្លេកស្លាំង និងមានបញ្ហាឈាមផ្សេង១ ព្រមទាំងបញ្ហាថ្លើម ។ បើអ្នកដឹងខ្លួនថាឥទ្ធិពលថ្នាំធ្វើទុក្ខធ្ងន់ធ្ងរ ចូរទៅជួបបុគ្គលិកសុខាភិបាលជាបន្ទាន់ ។

**របបថ្នាំ អេ-អរ-វី** (ARV regimens) **សំរាប់មនុស្សពេញវ័យនិងវ័យជំទង់ (មិនមែនសំរាប់ក្មេងតូច១)**

**ឌី4ធី** (**ស្តាវូឌីន**), 30 ឬ 40 មីលីក្រាម + **3ធីស៊ី** (**ឡាមីវូឌីន**), 150 មីលីក្រាម + **អ៊ិនវីភី** (**នេវីរ៉ាពីន**), 200 មីលីក្រាម
d4T *(stavudine)*, 30 or 40 mg + 3TC *(lamivudine)*, 150 mg + NVP *(nevirapine)*, 200 mg.
ថ្នាំទាំង 3 យ៉ាងនេះបានផលិតឡើងដោយផ្សំចូលគ្នាជាស្រេចទៅជាថ្នាំតែមួយគ្រាប់ ហៅថា **ទ្រីអូមូន** (Triomune) ។

— **ឬ** —

**ឌី4ធី** (**ស្តាវូឌីន**), 30 ឬ 40 មីលីក្រាម + **3ធីស៊ី** (**ឡាមីវូឌីន**), 150 មីលីក្រាម + **អ៊ីវីអេហ្វ** (**អេហ្វាវីរេន្ស**), 600 មីលីក្រាម, **លេបម្តងគត់ក្នុង 1 ថ្ងៃ**
D4T (stavudine), 30 or 40 mg + 3TC (lamivudine), 150 mg + EVF (efavirenz), 600 mg, one time a day.

— **ឬ** —

**អេហ្ស៊ីធី** (**ហ្ស៊ីឌីវី, ហ្ស៊ីដូវូឌីន**), 300 មីលីក្រាម + **3ធីស៊ី** (**ឡាមីវូឌីន**), 150 មីលីក្រាម + **អ៊ិនវីភី** (**នេវីរ៉ាពីន**), 200មីលីក្រាម
AZT *(ZDV, zidovudine)*, 300 mg + 3TC *(lamivudine)*, 150 mg + NVP *(nevirapine)*, 200 mg.
**អេហ្ស៊ីធី** និង **3ធីស៊ី** បានផលិតឡើងដោយផ្សំចូលគ្នាជាស្រេចទៅជាថ្នាំតែមួយគ្រាប់ ហៅថា **កុមប៊ីវីរ** (Combivir) ។

— **ឬ** —

**អេហ្ស៊ីធី** (**ហ្ស៊ីឌីវី, ហ្ស៊ីដូវូឌីន**), 300មីលីក្រាម + **3ធីស៊ី** (**ឡាមីវូឌីន**), 150មីលីក្រាម + **អ៊ីវីអេហ្វ** (**អេហ្វាវីរេន្ស**), 600មីលីក្រាម, **លេបម្តងគត់ក្នុង 1 ថ្ងៃ**
AZT *(ZDV, zidovudine)*, 300 mg + 3TC *(lamivudine)*, 150 mg + EVF *(efavirenz)*, 600 mg, one time a day.
**អេហ្ស៊ីធី** និង **3ធីស៊ី** បានផលិតឡើងដោយផ្សំចូលគ្នាស្រេចទៅជាថ្នាំតែមួយគ្រាប់ ហៅថា **កុមប៊ីវីរ** (Combivir) ។

## សំខាន់

ថ្នាំ**អាត**មួយចំនួនហាក់ដូចជាបង្កឥទ្ធិពលធ្វើទុក្ខធ្ងន់ធ្ងរជាងថ្នាំមួយចំនួនទៀត ។ ថ្នាំមួយក្នុងចំណោមថ្នាំទាំងនេះគឺ **ស្តាវូឌីន**/stavudine (**ឌី4ធី**/d4T) ។ **អង្គការសុខភាពពិភពលោកបានផ្តល់អនុសាសន៏ថា ថ្នាំដែលមានមូលដ្ឋានចេញពី- ឌី4ធី គួរត្រូវកាត់បន្ថយបន្តិចម្តង១ឈប់ផ្តល់វាឱ្យអ្នកជំងឺប្រើប្រាស់តទៀត តាមរយៈការបំបាត់ថ្នាំនេះចោលទាំងស្រុង ។** នៅតាមបណ្តាប្រទេសជាច្រើន បុគ្គលដែលកើតអេដស៏លែងប្រើប្រាស់ថ្នាំ **ស្តាវូឌីន** ទៀតហើយ ។ នៅតាមប្រទេសមួយចំនួន ករណីនេះមិនអាចបញ្ឈប់បានទាំងស្រុងឡើយ ពីព្រោះមិនមានថ្នាំផ្សេងទៀតផ្តល់ឱ្យអ្នកជំងឺ ឬ ដោយសារថ្នាំផ្សេងទៀតវាថ្លៃពេក ។ បើអ្នកកើតអេដស៏ ហើយអ្នកចង់ប្រើប្រាស់ថ្នាំ**អាត** ចូរជួបពិភាក្សាជាមួយបុគ្គលិកសុខាភិបាលដែលមានជំនាញខាងវីរុសហ៊ីវ/អេដស៏ នៅក្នុងសហគមន៏របស់អ្នកក្រែងលោគេមានថ្នាំផ្សេងទៀតដើម្បីផ្តល់ឱ្យអ្នកប្រើប្រាស់ ។

# ថ្នាំសំរាប់ជួយទ្រទ្រង់សុខភាពអ្នកផ្ទុកវីរុសហ៊ីវ/អេដស៍

ថ្នាំ **អេហ្វាវីរេន្ស** ( **អ៊ីអេហ្វវី, អ៊ីអេហ្វហ្ស៊ី, ស៊ូស្ទីវ៉ា** ) = Efavirenz (***EFV, EFZ, Sustiva)***

**បំរាម!**



- ថ្នាំ **អេហ្វាវីរេន្ស** ជាថ្នាំ**អង់ទីរ៉េត្រូវីរ៉ាល់** /antiretroviral ( **អេ-អរ-វី**/ARV) បានផ្សំចូលគ្នាស្រេចជាមួយថ្នាំ **អេ-អរ-វី** ផ្សេងទៀត ដើម្បីប្រើប្រាស់គាំពារសុខភាពអ្នកជំងឺអេដស៍ ។
- **<u>ឥទ្ធិពលថ្នាំធ្វើទុក្ខ</u>** :- ថ្នាំ **អេ-អរ-វី** អាចធ្វើឱ្យអ្នកជំងឺវិលមុខ, ច្របូកច្របល់, អារម្មណ៍ប្រែប្រួល, និងយល់សប្តិចម្លែកៗ, ប៉ុន្តែឥទ្ធិពលថ្នាំធ្វើទុក្ខទាំងនេះនឹងបាត់ទៅវិញ ធម្មតាបន្ទាប់ពីបានប្រើវាចំនួនពីរ-បីអាទិត្យកន្លងទៅ ។ បើឥទ្ធិពលថ្នាំធ្វើទុក្ខនេះមិនបាត់ទៅវិញ ចូរទៅជួបពិភាក្សាបញ្ហានេះជាមួយបុគ្គលិកសុខាភិបាល ។ បើភ្នែកឡើងលឿង ឬ ច្របូកច្របល់មិនស្រួលខ្លួនខ្លាំង ចូរទៅរកផ្នែកវេជ្ជសាស្ត្រជួយសង្គ្រោះជាបន្ទាន់ ។
- **<u>ថ្នាំនេះតែងផលិតជា</u>** :- ថ្នាំគ្រាប់រាងមូលទ្រវែងទន់ៗ ចំណុះពី 50, 100, 200 មីលីក្រាម ឬ ជាថ្នាំគ្រាប់រឹងចំណុះ 600 មីលីក្រាម ឬ ជាថ្នាំទឹកសំរាប់ផឹក, ចំណុះ 150 មីលីក្រាម/5មីលីលីត្រក្នុងកូនដបនីមួយៗ ។





- **<u>វិធីប្រើថ្នាំនេះ</u>** :- លេប/ផឹក ចំណុះ 600 មីលីក្រាម, តែមួយដងគត់ ក្នុងមួយថ្ងៃ ។



- **<u>ឥទ្ធិពលថ្នាំនេះទាក់ទិនជាមួយថ្នាំពេទ្យផ្សេងទៀត</u>** :-
  ⇒ បើប្រើជាមួយថ្នាំ**រីហ្វាមពីស៊ីន** / rifampicin នោះវាធ្វើឱ្យប្រសិទ្ធភាពថ្នាំ**អេហ្វាវីរេន្ស /** efavirenz ថយចុះ ។ អ្នកប្រហែលជាត្រូវផឹកថ្នាំ**អ៊ីអេហ្វវី** / EFV ដែលកំណត់ដូសច្រើនជាងមុនគឺលេបចំណុះ ( 800 មីលីក្រាម ជំនួសឱ្យ 600 មីលីក្រាម ) ។



**បំរាម** :- ស្ត្រីទើបតែមានផ្ទៃពោះ 3 ខែដំបូង ហាមលេបថ្នាំ **អ៊ីអេហ្វវី** ។ វាអាចបណ្តាលឱ្យទារកខូចទ្រង់ទ្រាយពីកំណើត ។ ស្ត្រីដែលកំពុងប្រើប្រាស់ថ្នាំ **អ៊ីអេហ្វវី** ដែលនឹងអាចមានផ្ទៃពោះ ត្រូវតែប្រើប្រាស់វិធីសាស្ត្រផែនការគ្រួសារ ( វិធីការពារកុំឱ្យមានកូន ) ។

ថ្នាំ **ឡាមីវូឌីន ( 3ធីស៊ី, អេពីវីរ )** = Lamivudine (3TC, Epivir)

- ថ្នាំ **ឡាមីវូឌីន** ជាថ្នាំ**អង់ទីរ៉េត្រូវីរ៉ាល់ ( អេ-អរ-វី )** បានផ្សំចូលគ្នាស្រេចនឹងថ្នាំ**អេ-អរ-វី** ផ្សេងទៀត ដើម្បីប្រើគាំពារសុខភាពអ្នកជំងឺអេដស៍ ។ ថ្នាំនេះមានឥទ្ធិពលធ្វើទុក្ខតិចតួចតែប៉ុណ្ណោះ ។
- **<u>ថ្នាំនេះតែងផលិតជា</u>** :- ថ្នាំគ្រាប់រឹង ចំណុះ 150 មីលីក្រាម ។ ឬ ជាថ្នាំទឹកសំរាប់ផឹកចំណុះ 50មីលីក្រាម/5មីលីលីត្រក្នុងកូនដបនីមួយៗ ។



- **<u>វិធីប្រើថ្នាំនេះ</u>** :- លេប/ផឹកម្តង ចំណុះ 150 មីលីក្រាម, លេប 2 ដងក្នុងមួយថ្ងៃ ។

ថ្នាំ **នេវីរ៉ាពីន ( អ៊ិនវីភី, វីរ៉ាមូន )**= Nevirapine (NVP, Viramune)

- ថ្នាំ **នេវីរ៉ាពិន** ជាថ្នាំ**អង់ទីរ៉េត្រូវីរ៉ាល់ ( អេ-អរ-វី )** បានផ្សំចូលគ្នាស្រេចនឹងថ្នាំ**អេ-អរ-វី** ផ្សេងទៀតដើម្បីប្រើគាំពារសុខភាពជំងឺអេដស៍ ។ ថ្នាំ **អ៊ិនវីភី** ក៏ត្រូវបានប្រើទប់ស្កាត់ការចំលងវីរុសហ៊ីវពី-ម្តាយ-ទៅ-កូនក្នុងផ្ទៃនៅអំឡុងពេលមានផ្ទៃពោះ និងអំឡុងពេលកើតកូនផងដែរ ។
- **<u>ឥទ្ធិពលថ្នាំធ្វើទុក្ខ</u>** :- ចូរទៅរកពេទ្យព្យាបាលជាបន្ទាន់ សំរាប់ភ្នែកលឿង, រោលកន្ទួលស្បែក, និងអស់កំលាំងខ្លាំងរួមទាំងដកដង្ហើមស្មើរមិនដល់គ្នា, និងហូបចំណីអាហារមិនបាន ។
- **<u>ថ្នាំនេះតែងផលិតជា</u>** :- ថ្នាំគ្រាប់រឹងចំណុះ 200 មីលីក្រាម ។ ឬ ជាថ្នាំទឹកសំរាប់ផឹកចំណុះ 50មីលីក្រាម/5មីលីលីត្រ ក្នុងកូនដបនីមួយៗ ។





- **<u>វិធីប្រើថ្នាំនេះ</u>** :- ដើម្បីកាត់បន្ថយឥទ្ធិពលថ្នាំធ្វើទុក្ខ ពេលចាប់ផ្តើមប្រើថ្នាំ**អ៊ិនវីភី** ដែលជាចំណែកនៃរបបថ្នាំ**អាត**, ចូរផឹកម្តងៗពាក់កណ្តាលកំណត់ដូស ផឹកថ្នាំ**អ៊ិនវីភី** ចំណុះ 200មីលីក្រាម ក្នុងមួយថ្ងៃសំរាប់រយៈពេល 2 អាទិត្យ ។ ពីរអាទិត្យក្រោយមក, ចាប់ផឹកថ្នាំ**អ៊ិនវីភី** ម្តងចំណុះ 200 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ ។



- **<u>ឥទ្ធិពលថ្នាំនេះទាក់ទិនជាមួយថ្នាំពេទ្យផ្សេងទៀត</u>** :- បើប្រើជាមួយថ្នាំ**រីហ្វាមពីស៊ីន** / rifampicin នោះវាធ្វើឱ្យប្រសិទ្ធភាពថ្នាំ**នេវីរ៉ាពីន**/nevirapine ថយចុះ ។

ថ្នាំ **ស្តាវូឌីន (ឌី4ធី, ហ្សេរ៉ីត)** = Stavudine (d4T, Zerit)

**បំរាម!**



- ថ្នាំ **ស្តាវូឌីន** ជាថ្នាំ**អង់ទីរ៉េត្រូវីរ៉ាល់** / antiretroviral **(អេ-អរ-វ៉ី** / ARV) បានផ្សំចូលគ្នាស្រេច ជាមួយថ្នាំ **អេ-អរ-វ៉ី** ផ្សេងទៀត ដើម្បីប្រើប្រាស់ គាំពារសុខភាពអ្នកជំងឺអេដស៍ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ** :- ឈឹឈឺប។ ឬ ក្តៅរាងក្រហាយ។ក្នុងបាតដៃនិងបាតជើង ។ ចូរទៅរកការព្យាបាលជាបន្ទាន់ បើឥទ្ធិពលថ្នាំធ្វើទុក្ខខ្លាំងចំពោះអ្នកដូចជា ចង្អោរ, ក្អួត, ឈឺចាប់ខ្លាំងក្នុងពោះ, អស់កំលាំងខ្លាំងរួមជាមួយដង្ហើមដកស្ទើរមិនដល់គ្នា, ប្រែប្រួលទៅជាធាត់ ។
- **ថ្នាំនេះតែងផលិតជា** :- ថ្នាំគ្រាប់រាងទ្រវែងទន់។ ចំណុះពី 15, 20, 30, 40 មីលីក្រាម ។ ឬ ជាថ្នាំម្សៅសំរាប់លាយទឹកផឹក ចំណុះ 50 មីលីក្រាម / 5មីលីលីត្រ ។



- **វិធីប្រើថ្នាំនេះ** :- បើទំងន់ខ្លួនរបស់អ្នកលើសពី 60 គីឡូក្រាម, ចូរផឹកថ្នាំម្តង 40 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ ។ បើទំងន់ខ្លួនរបស់អ្នកក្រោម 60 គីឡូក្រាម, ចូរផឹកថ្នាំម្តង 30 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ ។



**បំរាម :-** ចំពោះបុគ្គលដែលមានទំងន់ខ្លួនតិចជាង 60 គីឡូក្រាម, ត្រូវផឹកថ្នាំដែលមានកំណត់ដូសចំណុះទាប ។

ចំពោះស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលធាត់ខ្លាំង ហាមផឹកថ្នាំ **ស្តាវូឌីន** បើសិនជាមានថ្នាំផ្សេងទៀតអាចប្រើជំនួសបាន ។ ដោយសារតែថ្នាំ**ស្តាវូឌីន** អាចបង្កឥទ្ធិពលធ្វើទុក្ខខ្លាំងក្លា អង្គការសុខភាពពិភពលោក បានផ្តល់អនុសាសន៍ថា **គួរត្រូវកាត់បន្ថយបន្តិចម្តង។ឈប់ផ្តល់វាឱ្យអ្នកជំងឺប្រើប្រាស់តទៀត តាមរយៈការបំបាត់ថ្នាំនេះចោលទាំងស្រុង ។**

ថ្នាំ**ហ្ស៊ីដូវូឌីន (អេហ្ស៊ីធី, ហ្ស៊ីឌីវី, អាហ្ស៊ីដូទីមីឌីន, រ៉េត្រូវីរ)**
Zidovudine (AZT, ZDV, Azidothymidine, Retrovir)

- ថ្នាំ **ហ្ស៊ីដូវូឌីន** ជាថ្នាំ**អង់ទីរ៉េត្រូវីរ៉ាល់** / antiretroviral **(អេ-អរ-វ៉ី** / ARV) បានផ្សំចូលគ្នាស្រេចជាមួយថ្នាំ **អេ-អរ-វ៉ី** ផ្សេងទៀត ដើម្បីប្រើប្រាស់គាំពារសុខភាពអ្នកជំងឺអេដស៍ ។ វាក៏ត្រូវបានប្រើទប់ស្កាត់ការចំលងវីរុសហ៊ីវពី-ម្តាយ-ទៅ-កូនក្នុងផ្ទៃនៅអំឡុងពេលមានផ្ទៃពោះ និង អំឡុងពេលកើតកូនផងដែរ ។
- **ឥទ្ធិពលថ្នាំធ្វើទុក្ខ** :- អស់កំលាំងខ្លាំងរួមនឹងការដង្ហើមដកស្ទើរមិនដល់គ្នា ។ ចូរទៅរកការព្យាបាលជាបន្ទាន់សំរាប់ស្បែកស្លេកស្លាំង ឬ រោគសញ្ញាផ្សេងទៀតនៃជំងឺស្លេកស្លាំង ។
- **ថ្នាំនេះតែងផលិតជា** :- ថ្នាំគ្រាប់រាងមូលទ្រវែងទន់។ ចំណុះ 100 ឬ 250 មីលីក្រាម ។ ឬ ជាថ្នាំគ្រាប់រឹងចំណុះ 300មីលីក្រាម ។ ឬ ជាថ្នាំទឹកសំរាប់ផឹក ឬ ជាថ្នាំទឹកស៊ីរ៉ូ ចំណុះ 50 មីលីក្រាម / 5 មីលីលីត្រក្នុងកូនដបនីមួយ។ ។ ឬ ជាថ្នាំសំរាប់ចាក់លាយបញ្ចូលសេរ៉ូម ចំណុះ 10 មីលីក្រាមក្នុងកូនដបចំណុះ 20 មីលីលីត្រ ។



- **វិធីប្រើថ្នាំនេះ** :- លេបម្តង 300 មីលីក្រាម, 2 ដងក្នុងមួយថ្ងៃ ។



- **ឥទ្ធិពលថ្នាំនេះទាក់ទិនជាមួយថ្នាំពេទ្យផ្សេងទៀត :-**

⇒ ជាមួយថ្នាំ **ដាបសុន** / dapsone - អាចបណ្តាលឱ្យកើតជំងឺស្លេកស្លាំង ។

⇒ ជាមួយថ្នាំ **វ៉ាល់ប្រូអ៊ីក អាស៊ីត** / valproic acid **-** ធ្វើឱ្យឥទ្ធិពលថ្នាំ **ហ្ស៊ីដូវូឌីន** កើនឡើង និងបណ្តាលឱ្យចង្អោរ, ក្អួត និងល្វិតល្វៃក្នុងខ្លួន ។

⇒ ជាមួយថ្នាំ **រីហ្វាមពីស៊ីន** / rifampicin - អាចបណ្តាលឱ្យប្រសិទ្ធភាពថ្នាំ **ហ្ស៊ីដូវូឌីន** ចុះខ្សោយ ។